# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# វិធានផ្ទៃក្នុង
# (វិសោធនកម្មលើកទី ៧)

**វិសោធនកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១**

# មាតិកា

**មាតិកា**..............................................................................................2

**បុព្វកថា**..............................................................................................8

**ជំពូក ១: បទប្បញ្ញត្តិទាក់ទងទៅនឹងវិធានផ្ទៃក្នុង**.........................................9

វិធាន ១: ការចូលជាធរមាន និង ការបកស្រាយ .........................................9

វិធាន ២: នីតិវិធីអនុវត្តសម្រាប់បញ្ហាចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង...........9

វិធាន ៣: ការធ្វើវិសោធនកម្ម........................................................9

**ជំពូក ២: ការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ**...........................................11

**ក-បទប្បញ្ញត្តិទូទៅ** .....................................................................11

វិធាន ៤: បទបញ្ជារដ្ឋបាល ...........................................................11

វិធាន ៥: សហប្រតិបត្តិការអន្តរជាតិផ្នែកតុលាការ និង ជំនួយហិរញ្ញវត្ថុ ...............11

វិធាន ៦: ភារកិច្ច និង វិន័យរបស់បុគ្គលិក .........................................12

វិធាន ៧: ការលាលែងពីមុខតំណែង ...................................................13

**ខ-ការិយាល័យរដ្ឋបាល** ..................................................................13

វិធាន ៨: ប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល ...................................13

វិធាន ៩: មុខងាររបស់ការិយាល័យរដ្ឋបាល .............................................13

វិធាន ១០: ប្រតិបត្តិការរបស់ការិយាល័យរដ្ឋបាល.......................................15

វិធាន ១១: អង្គភាពគាំពារការការពារក្តី ..............................................16

វិធាន ១២: ការរៀបចំ និងការប្រព្រឹត្តទៅនៃការចូលរួមរបស់ជនរងគ្រោះ .................19

វិធាន ១២ ស្ទួន: អង្គភាពគាំពារជនរងគ្រោះ ..........................................20

វិធាន ១២ ស្ទួនពីរ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ......................21

**គ- ការិយាល័យសហព្រះរាជអាជ្ញា**......................................................23

វិធាន ១៣: ប្រតិបត្តិការនៃការិយាល័យសហព្រះរាជអាជ្ញា...................................23

**ឃ- ការិយាល័យសហចៅក្រមស៊ើបអង្កេត**..................................................24

វិធាន ១៤: ប្រតិបត្តិការនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ............................24

**ង-នគរបាលយុត្តិធម៌ អ្នកស៊ើបអង្កេត និង ក្រឡាបញ្ជី**......................................25

វិធាន ១៥: នគរបាលយុត្តិធម៌ .........................................................25

វិធាន ១៦: អ្នកស៊ើបអង្កេត ........................................................................ 26
វិធាន ១៦ ស្ទួន: ក្រឡាបញ្ជី ........................................................................ 26
**ច-អង្គជំនុំជម្រះ** ........................................................................ 27
វិធាន ១៧: បទប្បញ្ញត្តិទូទៅ ........................................................................ 27
**ឆ-ការរៀបចំអង្គជំនុំជម្រះ** ........................................................................ 27
វិធាន ១៨: កិច្ចប្រជុំពេញអង្គ ........................................................................ 27
វិធាន ១៩: គណៈកម្មាធិការរដ្ឋបាលតុលាការ ........................................................................ 30
វិធាន ២០: គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ........................................................................ 31
**ជំពូក ៣: នីតិវិធី** ........................................................................ 31
**ក-បទប្បញ្ញត្តិទូទៅ** ........................................................................ 31
វិធាន ២១: គោលការណ៍ជាសារវ័ន្ត ........................................................................ 32
វិធាន ២២: មេធាវី ........................................................................ 33
វិធាន ២៣: គោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី... 35
វិធាន ២៣ស្ទួន: បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........................................................................ 36
វិធាន ២៣ស្ទួនពីរ: ការតំណាងដើមបណ្តឹងរដ្ឋប្បវេណី ........................................................................ 38
វិធាន ២៣ស្ទួនបី: សមាគមជនរងគ្រោះ ........................................................................ 39
វិធាន ២៣ស្ទួនបួន: បណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........................................................................ 40
វិធាន ២៤: សាក្សី ........................................................................ 41
វិធាន ២៥: ការថតសម្លេង ឬ រូបភាពក្នុងពេលសួរយកចម្លើយ ........................................................................ 42
វិធាន ២៦: ការធ្វើសក្ខីកម្មដោយផ្សាយបន្តផ្ទាល់ តាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍ .... 44
វិធាន ២៧: ជនដែលគ ឬ ថ្លង់ ........................................................................ 44
វិធាន ២៨: សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី ........................................................................ 45
វិធាន ២៩: វិធានការការពារ ........................................................................ 47
វិធាន ៣០: អ្នកបកប្រែ ........................................................................ 48
វិធាន ៣១: អ្នកជំនាញ ........................................................................ 49
វិធាន ៣២: ការពិនិត្យផ្នែកវេជ្ជសាស្ត្រដល់ជនត្រូវចោទ ឬ ជនជាប់ចោទ ........................................................................ 51
វិធាន ៣២ ស្ទួន: ការស្វែងរកមូលហេតុនៃមរណភាពនៅក្នុងអំឡុងពេលឃាត់ និងឃុំខ្លួន ............. 52

វិធាន ៣៣: សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ........ 52
វិធាន ៣៤: ការដកខ្លួន និង បណ្តឹងជិតចិត្តចំពោះចៅក្រម ........ 52
វិធាន ៣៥: ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ........ 54
វិធាន ៣៦: សក្ខីភាពក្លែងក្លាយ ........ 56
វិធាន ៣៧: ការរំខានក្នុងកិច្ចដំណើរការនីតិវិធី ........ 57
វិធាន ៣៨: កំហុសវិជ្ជាជីវៈរបស់មេធាវី ........ 58
វិធាន ៣៩: ពេលវេលាកំណត់ និងលក្ខខណ្ឌក្នុងការដាក់ឯកសារ ........ 58
វិធាន ៤០: ការចុះហត្ថលេខា ........ 60
វិធាន ៤១: ដីកាកោះ ........ 60
វិធាន ៤២: ដីកាបង្គាប់ឲ្យនាំខ្លួន ........ 61
វិធាន ៤៣: ដីកាបង្គាប់ឲ្យឃុំខ្លួន ........ 61
វិធាន ៤៤: ដីកាបង្គាប់ឲ្យចាប់ខ្លួន ........ 61
វិធាន ៤៥: ទម្រង់ការពាក់ព័ន្ធនឹងដីកាកោះ ដីកាបង្គាប់ឲ្យឃុំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន........ 61
វិធាន ៤៦: ការជូនដំណឹងអំពីដីកា........ 63
វិធាន ៤៧: ទម្រង់ការនៃការជូនដំណឹងអំពីដីកា ........ 64
វិធាន ៤៨: មោឃភាពចំពោះការមិនគោរពវិធានបញ្ញត្តិ ........ 64
**ខ-ការចោទប្រកាន់** ........ 64
វិធាន ៤៩: ការអនុវត្តបណ្តឹងអាជ្ញា ........ 64
វិធាន ៥០: ការស៊ើបអង្កេតបឋម........ 65
វិធាន ៥១: ការឃាត់ខ្លួន........ 66
វិធាន ៥២: ការហាមឃាត់មិនឲ្យស្តាប់ព័ត៌មានក្នុងពេលទំនាក់ទំនង ........ 68
វិធាន ៥៣: ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ........ 68
វិធាន ៥៤: ការផ្តល់ព័ត៌មានដល់សាធារណៈជនដោយសហព្រះរាជអាជ្ញា ........ 69
**គ-ការស៊ើបសួរ**........ 69
វិធាន ៥៥: បទប្បញ្ញត្តិទូទៅទាក់ទងទៅនឹងការស៊ើបសួរ ........ 70
វិធាន ៥៦: ការផ្តល់ព័ត៌មានដល់សាធារណៈដោយសហចៅក្រមស៊ើបអង្កេត ........ 72
វិធាន ៥៧: ការជូនដំណឹងអំពីបទចោទប្រកាន់........ 73
វិធាន ៥៨: ការសួរចម្លើយជនត្រូវចោទ ........ 73

វិធាន ៥៩: ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ..... 75
វិធាន ៦០: ការស្តាប់ចម្លើយសាក្សី ..... 76
វិធាន ៦១: ការឆែកឆេរ និងការចាប់យកវត្ថុតាង ..... 77
វិធាន ៦២: ដីកាចាត់ឲ្យស៊ើបសួរជំនួស ..... 77
វិធាន ៦៣: ការឃុំខ្លួនបណ្តោះអាសន្ន ..... 78
វិធាន ៦៤: ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ..... 81
វិធាន ៦៥: ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ..... 82
វិធាន ៦៦: ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា ..... 83
វិធាន ៦៧: ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ..... 84
វិធាន ៦៨: អានុភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ..... 85
វិធាន ៦៩: ការបញ្ជូនសំណុំរឿងក្រោយពេលមានដីកាដំណោះស្រាយ ..... 86
វិធាន ៧០ : ការបើកការស៊ើបសួរឡើងវិញ ..... 87
**ឃ-នីតិវិធីចំពោះអង្គបុរេជំនុំជម្រះ** ..... 87
វិធាន ៧១: ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ..... 87
វិធាន ៧២: ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ..... 89
វិធាន ៧៣: យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ ..... 91
វិធាន ៧៤: មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ..... 92
វិធាន ៧៥: ការដាក់បណ្តឹងឧទ្ធរណ៍ និង សារណាអំពីការធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ..... 93
វិធាន ៧៦: បណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ ..... 94
វិធាន ៧៧: នីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ និងពាក្យសុំទៅអង្គបុរេជំនុំជម្រះ ..... 95
វិធាន ៧៧ ស្ទួន: នីតិវិធីបណ្តឹងឧទ្ធរណ៍សង្ខេប ..... 99
វិធាន ៧៨: ការបោះពុម្ពផ្សាយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ..... 100
**ង-នីតិវិធីនៅអង្គជំនុំជម្រះសាលាដំបូង** ..... 100
វិធាន ៧៩: បទប្បញ្ញត្តិទូទៅ ..... 102
វិធាន៨០: ការរៀបចំសវនាការ ..... 103
វិធាន ៨០ស្ទួន: សវនាការបឋម ..... 104
វិធាន ៨១: ការចូលខ្លួនរបស់ជនជាប់ចោទ និងមេធាវីការពារក្តី ..... 104

វិធាន ៨២: ការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន និង ការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ....106
វិធាន ៨៣: និរាករណ៍ ....108
វិធាន ៨៤: ការចូលខ្លួនរបស់សាក្សី និង អ្នកជំនាញ ....108
វិធាន ៨៥: ការដឹកនាំសវនាការ ....108
វិធាន ៨៦: ការមើលសំណុំរឿង ....109
វិធាន ៨៧: វិធាននៃភស្តុតាង ....109
វិធាន ៨៨: ការបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ....111
វិធាន ៨៩: អញ្ញត្រកម្ម ....111
វិធាន ៨៩ ស្ទួន: សវនាការលើអង្គសេចក្តី ....112
វិធាន ៨៩ ស្ទួនពីរៈការបំបែកកិច្ចដំណើរការនីតិវិធី ....112
វិធាន ៩០: ការសួរចម្លើយជនជាប់ចោទ ....112
វិធាន ៩១: ការស្តាប់ចម្លើយរបស់ភាគី និង សាក្សី ....113
វិធាន ៩១ ស្ទួន: លំដាប់លំដោយនៃដំណើរការនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះ ....113
វិធាន ៩២: ការដាក់សេចក្តីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល ....113
វិធាន ៩៣: ការស៊ើបសួរបន្ថែមដោយអង្គជំនុំជម្រះសាលាដំបូង ....114
វិធាន ៩៤: សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ....114
វិធាន ៩៥: ការបន្តកិច្ចដំណើរការនីតិវិធី ....115
វិធាន ៩៦: ការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ....115
វិធាន ៩៧: កំណាត់ហេតុរបស់អង្គសវនាការ ....115
វិធាន ៩៨: សាលក្រម ....116
វិធាន ៩៩: អានុភាពនៃសាលក្រម ....117
វិធាន ១០០: ការសម្រេចលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ....118
វិធាន ១០១: ទម្រង់ការនៃសាលក្រម ....118
វិធាន ១០២: ការប្រកាសសាលក្រមនៅសវនាការសាធារណៈ ....119
វិធាន ១០៣: និរាករណ៍ ....120
**ច-នីតិវិធីនៃបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង** ....120
វិធាន ១០៤: យុត្តាធិការនៃអង្គជំនុំជម្រះតុលាការកំពូល ....121

វិធាន ១០៤ ស្ទួន: វិធានដែលអាចអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ...............121
វិធាន ១០៥: ការទទួលបណ្ដឹងសាទុក្ខ ...............121
វិធាន ១០៦: ការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និង ការដាក់សារណា ...............122
វិធាន ១០៧: រយៈពេលនៃបណ្ដឹងសាទុក្ខ ...............123
វិធាន ១០៨: នីតិវិធីនៃបណ្ដឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ...............114
វិធាន ១០៩: អំពីសវនាការលើបណ្ដឹងសាទុក្ខ ...............115
វិធាន ១១០: អានុភាពនៃបណ្ដឹងសាទុក្ខ ...............116
វិធាន ១១១: សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ...............117
វិធាន ១១២: បណ្ដឹងសើរើ ...............128
វិធាន ១១៣: ការអនុវត្តទោស និង សំណងរដ្ឋប្បវេណី ...............129
វិធាន ១១៤: អន្តរប្បញ្ញត្តិ ...............130
សទ្ទានុក្រម ...............132

# បុព្វកថា

**ដោយហេតុថា** មហាសន្និបាតអង្គការសហប្រជាជាតិ បានរំលឹកនៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ៥៧/២២៨ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០២ ថាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជា និង ច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅតែជាបញ្ហាដែលបង្កឱ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល ។

**ដោយហេតុថា** នៅក្នុងសេចក្តីសម្រេចចិត្តដដែលនេះ មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និង ប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និង សន្តិសុខ។

**ដោយហេតុថា** អាជ្ញាធរកម្ពុជា បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និង ទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភ លើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ០៦ ខែមករា ឆ្នាំ១៩៧៩។

**ដោយហេតុថា** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងនៅក្រោមច្បាប់កម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលត្រូវបានអនុម័តដោយមហាសន្និបាត និង ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា។

**អាស្រ័យហេតុនេះ** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តវិធានផ្ទៃក្នុង ដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង ដោយអនុលោមតាមមាត្រា ២០ថ្មី ២៣ថ្មី និង មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្ត ឬ ក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ។

<u>**ជំពូក ១: បទប្បញ្ញត្តិទាក់ទងនៅនឹងវិធានផ្ទៃក្នុង**</u>

**វិធាន ១: ការចូលជាធរមាន និង ការបកស្រាយ**

១. វិធានផ្ទៃក្នុងនេះត្រូវចូលជាធរមានតាមរយៈការបោះពុម្ពផ្សាយជាផ្លូវការដោយការិយាល័យរដ្ឋបាល និង ក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃ ក្រោយពីឯកសារដូចគ្នាដែលមានជាភាសាខ្មែរ អង់គ្លេស និង បារាំង ត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គ។

២. នៅក្នុងឯកសារនេះ ពាក្យសម្គាល់ភេទប្រុសក៏ត្រូវរាប់បញ្ចូលភេទស្រីដែរ ហើយឯកវចនៈក៏អាចយល់ជាពហុវចនៈដែរ ហើយក៏អនុវត្តដូចគ្នាផងដែរចំពោះករណីបញ្ច្រាសមកវិញ។ជាពិសេសលើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង។ ករណីដូចគ្នានេះដែរត្រូវយកមកអនុវត្តចំពោះសហព្រះរាជអាជ្ញា ។ បទប្បញ្ញត្តិនេះមិនមានផលប៉ះពាល់ផ្នែកវេយ្យាករណ៍ ដល់ឯកសារជាភាសារខ្មែរឡើយ។

**វិធាន ២: នីតិវិធីអនុវត្តសម្រាប់បញ្ហាចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង**

នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើប អង្កេត ឬ អង្គជំនុំជម្រះត្រូវធ្វើការ សម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និង មាត្រា ២០ថ្មី, ២៣ថ្មី, ៣៣ថ្មី ឬមាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និង ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន ។ ក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងត្រូវដាក់ជូនទៅគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

**វិធាន ៣: ការធ្វើវិសោធនកម្ម**

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. សំណើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងនេះ អាចត្រូវដាក់ជូនគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងដោយសហព្រះរាជអាជ្ញាណាម្នាក់ សហចៅក្រមស៊ើបអង្កេតណាម្នាក់ ចៅក្រមណាម្នាក់ ប្រធានអង្គភាពគាំពារការការពារក្តី អង្គភាពគាំពារជនរងគ្រោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ប្រធាន ឬ អនុប្រធានការិយាល័យរដ្ឋបាល។

២. សំណើសុំធ្វើវិសោធនកម្ម ដែលបញ្ជូនពីគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង ត្រូវដាក់ជូនកិច្ចប្រជុំពេញអង្គ ដើម្បីអនុម័តដោយស្របទៅនឹងនីតិវិធីសម្រាប់ការអនុម័តវិធានផ្ទៃក្នុងនេះ។

៣. លើកលែងតែមានការចែងផ្សេងពីនេះ វិសោធនកម្មត្រូវចូលជាធរមានភ្លាមបន្ទាប់ពីការបោះពុម្ពផ្សាយ ជាផ្លូវការដោយការិយាល័យរដ្ឋបាល និងមិនត្រូវលើសពីរយៈពេល ១០(ដប់)ថ្ងៃ ក្រោយពេលទទួលបានការអនុម័តពីកិច្ចប្រជុំពេញអង្គជាភាសាខ្មែរ អង់គ្លេស និង បារាំង។

## ជំពូក ២: ការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ

### ក-បទប្បញ្ញត្តិទូទៅ

### វិធាន ៤: បទបញ្ជារដ្ឋបាល

(វិសោធនកម្មនៅថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

បន្ទាប់ពីវិធានផ្ទៃក្នុងនេះចូលជាធរមាន ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះ ការិយាល័យរដ្ឋបាល អង្គភាពគាំពារការការពារក្តី អង្គភាពគាំពារជនរងគ្រោះ និង អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរៀបចំបទបញ្ជារដ្ឋបាលរបស់ការិយាល័យរៀងៗខ្លួន ឲ្យស្របទៅតាមវិធានផ្ទៃក្នុងនេះ ។ គណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬ តាមសំណើររបស់ការិយាល័យណាមួយដូចខាងលើអាចពិនិត្យមើលបទបញ្ជារដ្ឋបាលរបស់ការិយាល័យផ្សេងទៀតបាន នៅពេលណាដែលមានវិមតិសង្ស័យអំពីភាពសមស្របជាមួយនឹងវិធានផ្ទៃក្នុងនេះ។

### វិធាន ៥: សហប្រតិបត្តិការអន្តរជាតិផ្នែកតុលាការ និង ជំនួយហិរញ្ញវត្ថុ

១. អង្គជំនុំជម្រះវិសាមញ្ញ អាចអញ្ជើញរដ្ឋ ដែលមិនមែនជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀង ឲ្យផ្តល់ជំនួយផ្នែកតុលាការ ដោយឈរលើមូលដ្ឋាននៃការព្រមព្រៀងពិសេស ឬ ក៏ឈរលើមូលដ្ឋានសមស្របណាមួយផ្សេងទៀត។

២. ក្នុងករណីដែលរដ្ឋណាមួយខកខានមិនបានផ្តល់ជំនួយឧបត្ថម្ភផ្នែកតុលាការនោះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាចចាត់វិធានការសមស្រប តាមរយៈការិយាល័យរដ្ឋបាល ដោយរួមទាំង សំណើសុំជំនួយពីអគ្គលេខាធិការអង្គការសហប្រជាជាតិ និង/ឬ ពីរាជរដ្ឋាភិបាលកម្ពុជា។

៣. ដោយយោងទៅលើមាត្រា ៤៤(៤)ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញអាចទទួលនូវជំនួយបន្ថែមសម្រាប់ការចំណាយរបស់ខ្លួន ពីមូលនិធិស្ម័គ្រចិត្តផ្សេងទៀត ដែលចូលរួមវិភាគទានដោយរដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង បុគ្គលទាំងឡាយណាដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនីតិវិធី របស់អង្គជំនុំជម្រះវិសាមញ្ញ។

## វិធាន ៦: ភារកិច្ច និងវិន័យរបស់បុគ្គលិក

១. បុគ្គលិកទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវមានសិទ្ធិអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងពេញលេញដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង ដោយពុំមានការជ្រៀតជ្រែកពីសំណាក់ស្ថាប័នខាងក្រៅ ឬ បុគ្គលណាមួយឡើយ។

២. សហព្រះរាជអាជ្ញា និង សហព្រះរាជអាជ្ញាបម្រុងជាតិ សហចៅក្រមស៊ើបអង្កេត និងសហចៅក្រមស៊ើបអង្កេតបម្រុងជាតិ ចៅក្រម និង ចៅក្រមបម្រុងជាតិ និង ប្រធានការិយាល័យរដ្ឋបាល និង បុគ្គលិកជាតិទាំងអស់ ត្រូវទទួលបាននូវអភ័យឯកសិទ្ធិ ដូចមានចែងក្នុងមាត្រា៤២(១)ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា២០(១)នៃកិច្ចព្រមព្រៀង។ ជាពិសេស មន្ត្រីទាំងអស់នេះត្រូវបានផ្តល់អភ័យឯកសិទ្ធិឲ្យរួចផុតពីដំណើរការក្តីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬ សរសេរជាលាយលក្ខណ៍អក្សរ និង រាល់កិច្ចទាំងអស់ ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ។

៣. ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ រួមទាំងចៅក្រមបម្រុង សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ក៏ដូចជាអនុប្រធានការិយាល័យរដ្ឋបាល ត្រូវទទួលបាននូវបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ ដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង មាត្រា ១៩ នៃកិច្ចព្រមព្រៀង។ បុគ្គលិកអន្តរជាតិដទៃទៀតត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងមាត្រា ៤២(២) ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា ២០(២) នៃកិច្ចព្រមព្រៀង ។ មន្ត្រីទាំងអស់នេះ ត្រូវបានផ្តល់អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរការក្តីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬ សរសេរជាលាយល័ក្ខអក្សរ និងរាល់កិច្ចទាំងអស់ ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ។

៤. វិធាន និង បទបញ្ញាសម្រាប់បុគ្គលិកអង្គការសហប្រជាជាតិ ត្រូវយកអនុវត្តក្នុងកិច្ចដំណើរការនីតិវិធីចំពោះកំហុស ឬ ការធ្វេសប្រហែសរបស់បុគ្គលិកអន្តរជាតិទាំងអស់ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ បុគ្គលិកអន្តរជាតិ មិនត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ឬ រដ្ឋបាលតាមនីតិវិធីផ្សេងទៀត ចំពោះសកម្មភាពទាំងនេះឡើយ។

៥. អាជ្ញាធរជាតិមានសមត្ថកិច្ច ត្រូវចាត់វិធានការតាមនីតិវិធីចំពោះបុគ្គលិកជាតិ ដែលមានកំហុស ឬ ធ្វេសប្រហែសក្នុងការបំពេញភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់កម្ពុជាជាធរមាន។

### វិធាន ៧: ការលាលែងពីមុខតំណែង

១.	ចៅក្រម ឬ ព្រះរាជអាជ្ញាណាម្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញ អាចលាឈប់ពីមុខតំណែងបាន។

២.	ពាក្យលាលែងរបស់ចៅក្រមជាតិ ឬ ព្រះរាជអាជ្ញាជាតិត្រូវដាក់ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ។ ការជូនដំណឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយចៅក្រម ឬ ព្រះរាជអាជ្ញានោះ ទៅកិច្ចប្រជុំពេញអង្គ តាមរយៈប្រធាននៃកិច្ចប្រជុំពេញអង្គ។

៣.	ពាក្យលាលែងរបស់ចៅក្រមអន្តរជាតិ ឬ ព្រះរាជអាជ្ញាអន្តរជាតិត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវបញ្ជូនពាក្យលាលែងនេះទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ។ ការជូនដំណឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយចៅក្រម ឬ ព្រះរាជអាជ្ញានោះ ទៅកិច្ចប្រជុំពេញអង្គ តាមរយៈប្រធាននៃកិច្ចប្រជុំពេញអង្គ។

៤.	មាត្រា ១១ថ្មី មាត្រា ១៨ថ្មី មាត្រា២៦ និង មាត្រា៤៦ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា ៣ មាត្រា ៥ និង មាត្រា ៦ នៃកិច្ចព្រមព្រៀង ត្រូវយកមកអនុវត្តចំពោះអាសនៈ ដែលនៅទំនេររបស់មន្ត្រីតុលាការ។

## <u>ខ-ការិយាល័យរដ្ឋបាល</u>

### វិធាន ៨: ប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល

ប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល ត្រូវបានតែងតាំងដោយអនុលោមទៅតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ប្រធាន និងអនុប្រធាន ត្រូវដឹកនាំការិយាល័យរដ្ឋបាល និងតែងតាំងបុគ្គលិកតាមតម្រូវការចាំបាច់។

### វិធាន ៩: មុខងាររបស់ការិយាល័យរដ្ឋបាល

(វិសោធនកម្មនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០០៩ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)

១.	ការិយាល័យរដ្ឋបាលត្រូវជួយគាំទ្រដល់ការបំពេញការងាររបស់អង្គជំនុំជម្រះ ការិយាល័យសហ–ព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងកិច្ចប្រជុំពេញអង្គ និងត្រូវទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល និងការផ្តល់សេវាកម្មរបស់ស្ថាប័នទាំងនោះ។ ក្នុងករណីនេះ មន្ត្រីតុលាការនៃការិយាល័យ

ខាងលើ អាចលើកជាសំណើទៅកាន់ការិយាល័យរដ្ឋបាល តាមរយៈគណៈកម្មាធិការរដ្ឋបាលតុលាការ ដោយរួមបញ្ចូលទាំងវិធានការខាងវិន័យចំពោះបុគ្គលិក ដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន តាមការចាំបាច់។

២. ការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះសុវត្ថិភាពអង្គជំនុំជម្រះវិសាមញ្ញ ដោយយោងទៅលើកិច្ចព្រមព្រៀងបន្ថែមស្តីពីសុវត្ថិភាព និង សន្តិសុខរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

៣. ការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវក្នុងការផ្តល់សម្ភារៈ ការគ្រប់គ្រងអគារ គ្រឿងបរិក្ខាបច្ចេកវិទ្យាព័ត៌មាន ភស្តុភារ យានជំនិះ មធ្យោបាយធ្វើដំណើរ និង សេចក្តីត្រូវការផ្នែករូបវន្ត និង រដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយយោងទៅលើកិច្ចព្រមព្រៀងបន្ថែមស្តីពីសម្ភារៈប្រើប្រាស់ ការជួយសម្របសម្រួល និងសេវាផ្សេងៗទៀត រវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា។

៤. ដោយមិនធ្វើឲ្យប៉ះពាល់ដល់អំណាចរបស់ការិយាល័យសហព្រះរាជអាជ្ញា ឬ ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្នុងការទទួល និង ផ្តល់ឲ្យនូវព័ត៌មាន និង បង្កើតច្រកទំនាក់ទំនងក្នុងការអនុវត្តការងាររបស់ខ្លួន ការិយាល័យរដ្ឋបាលត្រូវបំពេញភារកិច្ចជាច្រកទំនាក់ទំនងផ្លូវការទាំងផ្នែកខាងក្នុង និង ខាងក្រៅរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ការិយាល័យរដ្ឋបាលត្រូវបង្កើតផ្នែកកិច្ចការសាធារណៈ ដែលត្រូវមានភារកិច្ចផ្សព្វផ្សាយ ព័ត៌មានដល់សាធារណៈជនអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេង នៅក្នុងវិធានផ្ទៃក្នុងនេះ ផ្នែកកិច្ចការសាធារណៈតាមការណែនាំរបស់ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវទទួលខុសត្រូវផងដែរ ក្នុងការកែតម្រូវនូវរាល់ព័ត៌មានមិនពិត ឬ ព័ត៌មាននាំឲ្យមានការភ័ន្តច្រឡំ ដែលបានផ្សព្វផ្សាយដល់សាធារណៈជន។

៥. ការិយាល័យរដ្ឋបាល ត្រូវថែរក្សាមូលដ្ឋានទិន្នន័យដែលមានសំណុំរឿងស៊ើបអង្កេតបឋម ការស៊ើបសួរ និងរឿងក្តីទាំងឡាយរបស់អង្គជំនុំជម្រះទាំងអស់។ នៅពេលដែលមានការស្នើសុំតាមករណីសមស្រប ការិយាល័យរដ្ឋបាលត្រូវធានាថា ឯកសារថតចម្លងទាំងឡាយ ត្រូវផ្តល់ទៅឱ្យភាគី អ្នកជំនាញ ឬ បុគ្គលណាម្នាក់ដែលទទួលបានការអនុញ្ញាតស្របតាមវិធាននេះប៉ុណ្ណោះ និងតាមការបង្គាប់ពីការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះទាំងអស់។ ព័ត៌មាននៅក្នុង

មូលដ្ឋានទិន្នន័យ ត្រូវផ្តល់ទៅឱ្យសាធារណៈជនបាន ប៉ុន្តែត្រូវសមស្របទៅតាមខ្លឹមសារនៃសេចក្តីណែនាំអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ចំពោះករណីនេះ។ អាស្រ័យទៅតាមសំណើរបស់ក្រឡាបញ្ជី ការិយាល័យរដ្ឋបាល ត្រូវជួយដល់ក្រឡាបញ្ជីក្នុងការចាត់ចែងផ្ញើដីកាកោះ និងជូនដំណឹងអំពីដីកាផ្សេងៗ។

៦. តាមចំណាត់របស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមការសមស្រប ការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវក្នុងការការពារថែរក្សាទុក និងរក្សាសុវត្ថិភាពដល់ភស្តុតាងដែលរួមមានវត្ថុតាង ចម្លើយ និង ឯកសារទាំងឡាយ ដែលប្រមូលបានក្នុងពេលស៊ើបអង្កេតបឋម ពេលស៊ើបសួរ ពេលជំនុំជម្រះ នៅអង្គជំនុំជម្រះសាលាដំបូង និង នៅអង្គជំនុំជម្រះតុលាការកំពូល។

៧. ការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលការបណ្តុះបណ្តាលដល់បុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ និងជួយគាំទ្រដល់ការបណ្តុះបណ្តាលរបស់អង្គភាពយុត្តាធិការតាមតម្រូវការ។

## វិធាន ១០: ប្រតិបត្តិការរបស់ការិយាល័យរដ្ឋបាល

**(វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. ក្នុងការតាក់តែង និងកែប្រែបទបញ្ជារដ្ឋបាលរបស់ខ្លួន ការិយាល័យរដ្ឋបាលត្រូវធ្វើការពិភាក្សាជាមួយអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតអំពីបញ្ហាទាំងឡាយណាដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការរបស់អង្គជំនុំជម្រះ ឬ ការិយាល័យទាំងនេះ។ បទបញ្ជារដ្ឋបាលនេះត្រូវទទួលការអនុម័តយល់ព្រម ដោយប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល។

២. ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល អាចរាយការណ៍ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរជូនទៅសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអំពីបញ្ហាដែលកើតមានឡើងជាក់ស្តែងណាមួយធ្វើឱ្យប៉ះពាល់ ឬ អាចធ្វើឱ្យប៉ះពាល់ដល់ការបំពេញភារកិច្ច ដូចជាការអនុវត្តន៍សេចក្តីសម្រេចរបស់តុលាការជាអាទិ៍ និងជូនព័ត៌មានដល់ភាគីពាក់ព័ន្ធ ប្រសិនបើចាំបាច់។

៣. ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ដោយគិតពិចារណាដល់ការធានាការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និងដោយពិគ្រោះយោបល់ជាមួយប្រធានអង្គភាពគាំពារការការពារក្តី សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះត្រូវធ្វើការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្កើត

យន្តការដែលធានាថា ការិយាល័យរដ្ឋបាលត្រូវបានទទួលព័ត៌មានគ្រប់គ្រាន់អំពីល័ក្ខខ័ណ្ឌនៃការឃុំខ្លួន ដែលស្របទៅនឹងកិច្ចព្រមព្រៀង និងដែលត្រូវគោរពតាមច្បាប់កម្ពុជា និងបទដ្ឋានអប្បបរិមានៃបទវិន័យសម្រាប់គ្រប់គ្រងជនជាប់ឃុំ និងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការគាំពារដល់ទណ្ឌិត។

៤. ក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ ត្រូវទំនាក់ទំនងជាមួយការិយាល័យរដ្ឋបាលដើម្បីធានាថា ឯកសារច្បាប់ដើមនៃសំណុំរឿង និងឯកសារសំណុំរឿងជាអេឡិចត្រូនិក ត្រូវបានរក្សាទុកដោយការិយាល័យរដ្ឋបាល។ ឯកសារច្បាប់ដើមនៃសំណុំរឿងទាំងអស់ ត្រូវរក្សាទុកនៅក្នុងបន្ទប់ដែលមានបរិយាកាសស្ថិតក្រោមការត្រួតពិនិត្យ នៅកន្លែងណាមួយរបស់អង្គជំនុំជម្រះដែលមានលក្ខខណ្ឌសុវត្ថិភាពគ្រប់គ្រាន់។

### វិធាន ១១: អង្គភាពគាំពារការការពារក្តី

(វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)

១. ការិយាល័យរដ្ឋបាល ត្រូវបង្កើតអង្គភាពគាំពារការការពារក្តី ដែលមានស្វ័យភាពតែលើបញ្ហាសំខាន់ក្នុងការការពារក្តីប៉ុណ្ណោះ ដូចមានចែងក្នុងវិធាននេះ ។ អង្គភាពនេះត្រូវដឹកនាំដោយប្រធានមួយរូប រួមជាមួយ និង អនុប្រធានជាតិមួយរូប និង អន្តរជាតិមួយរូប និង បុគ្គលិកមួយចំនួនទៀត តាមការចាំបាច់។

២. អង្គភាពនេះត្រូវបំពេញមុខងាររបស់ខ្លួន ដូចខាងក្រោម ៖

ក-អនុម័តបទបញ្ជារដ្ឋបាលស្របទៅនឹងវិធាន ៤ នៃវិធានផ្ទៃក្នុងនេះ ក្រោយពេលពិគ្រោះយោបល់រវាងប្រធានអង្គភាពនេះ ជាមួយនឹងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន ៖

១) លក្ខណៈវិនិច្ឆ័យ និងនីតិវិធីក្នុងការចុះឈ្មោះមេធាវី និងបុគ្គលិកដទៃទៀតទៅក្នុងបញ្ជីដូចមានក្នុងចំណុច (ឃ) និង (ឈ) ខាងក្រោម ដោយស្របទៅនឹងអនុវិធាន ៤ ។

២) នីតិវិធីក្នុងការចាត់តាំងមេធាវីការពារក្តី និង

៣) លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជនក្រីក្រ និង ប្រាក់កម្រៃរបស់មេធាវីការពារក្តី។

ខ-ទទួលពិនិត្យផ្ទៀងផ្ទាត់ និងបកប្រែពាក្យសុំរបស់មេធាវីបរទេស ដើម្បីការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងបញ្ជូនពាក្យសុំ ដែលមានលក្ខណៈគ្រប់គ្រាន់ ទៅគណៈមេធាវីនៃ

ព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះឈ្មោះស្របទៅតាមនីតិវិធី ដែលបានកំណត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអង្គភាពគាំពារការការពារក្តី។

គ-រក្សាបញ្ជីដូចជាៈ

១) បញ្ជីឈ្មោះមេធាវីជាតិ ដែលចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង
២) បញ្ជីឈ្មោះមេធាវីបរទេស ដែលទទួលការអនុញ្ញាត ដោយគណៈមេធាវីរបស់រដ្ឋណាមួយ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ហើយដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងក្នុងចំណុច (ខ)ខាងលើ។

ឃ-រៀបចំ និងថែរក្សាអនុបញ្ជីដូចខាងក្រោម ក្រោយពេលពិគ្រោះយោបល់រវាងប្រធានអង្គភាពគាំពារការការពារក្តី ជាមួយនឹងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ៖

១) បញ្ជីឈ្មោះមេធាវីជាតិ ដែលចុះឈ្មោះនៅគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់អង្គភាពគាំពារការការពារក្តី ដូចមានចែងក្នុងបទបញ្ជារដ្ឋបាល ដើម្បីការពារជនក្រីក្រនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។
២)បញ្ជីឈ្មោះមេធាវីបរទេសដែលទទួលការអនុញ្ញាតដោយគណៈមេធាវីរបស់រដ្ឋណាមួយ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ហើយដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង ឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់អង្គភាពគាំពារការការពារក្តី ដើម្បីការពារជនក្រីក្រនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាល។

ង-ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប បង្ហាញបញ្ជីឈ្មោះមេធាវី ដូចមានចែងក្នុងអនុវិធាន ២ ចំណុច (គ) និង (ឃ) ទៅដល់បុគ្គលដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ស្របតាមវិធានផ្ទៃក្នុងនេះ។
ច-ត្រូវផ្តល់ព័ត៌មានស្តីពីមេធាវីដូចមានចែងក្នុងអនុវិធាន ២ ចំណុច (គ) និង (ឃ) ដល់បុគ្គលដែល

មានសិទ្ធិទទួលបានមេធាវីការពារស្ថិតនៅក្នុងវិធានផ្ទៃក្នុងនេះ នៅពេលមានសំណើសុំព័ត៌មានបន្ថែម។

ឆ-ធ្វើកិច្ចសន្យាជាមួយមេធាវីការពារក្តី ដែលការពារពរាល់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ដែលក្រីក្រ ឬបុគ្គលដទៃទៀតដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ស្របតាមវិធានផ្ទៃក្នុងនេះ។

ជ-ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ ដូចមានចែងក្នុងចំណុច (ឆ)ខាងលើ និងអនុញ្ញាតឲ្យផ្តល់ប្រាក់កម្រៃស្របទៅតាមលទ្ធផលការងារ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី។

ឈ-ផ្តល់ឲ្យមេធាវីនូវបញ្ជីបុគ្គលិកជាតិ និងអន្តរជាតិដែលមានសមត្ថភាពជួយដល់ក្រុមការពារក្តីសម្រាប់ជនក្រីក្រ។

ញ-ផ្តល់ជំនួយផ្នែកច្បាប់ជាមូលដ្ឋាន និងជួយគាំពារលើការស្រាវជ្រាវផ្នែកច្បាប់ និងការស្រាវជ្រាវ និង ផ្តល់ឯកសារដល់មេធាវី ដែលមកការពារចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

ដ-រៀបចំការបណ្តុះបណ្តាលដល់មេធាវី ដោយពិគ្រោះយោបល់ និង សហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

៣. នីតិវិធីចុះឈ្មោះមេធាវីបរទេសនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារកូនក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានភាពយុត្តិធម៌ តម្លាភាព និងឆាប់រហ័ស។

៤. លក្ខណៈវិនិច្ឆ័យក្នុងការចុះឈ្មោះមេធាវីក្នុងបញ្ជីនៅក្នុងអង្គភាពគាំពារការការពារក្តី ដើម្បីការពារជនក្រីក្រ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងក្នុងអនុវិធាន ២(ឃ)ខាងលើ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោមៈ

ក-នីតិវិធីសំរាប់បញ្ចូលមេធាវីទៅក្នុងបញ្ជីនោះត្រូវមានភាពយុត្តិធម៌ តម្លាភាព និងឆាប់រហ័ស។

ខ-មេធាវីដែលបានដាក់ពាក្យសុំ គឺជាជនមិនធ្លាប់ជាប់ទោសពីបទព្រហ្មទណ្ឌ ឬទទួលទោសខាងផ្នែកវិន័យមិនឲ្យការពារក្តីដោយគណៈមេធាវីរបស់ខ្លួន ។

គ-មេធាវីអន្តរជាតិ ដែលបានដាក់ពាក្យសុំ ត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

១) ត្រូវតែនៅក្នុងពេលបច្ចុប្បន្នជាសមាជិក ដែលមានកេរ្តិ៍ឈ្មោះល្អនៃគណៈមេធាវី ដែលត្រូវបាន ទទួលស្គាល់នៅក្នុងរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ។

២) មានសញ្ញាប័ត្រផ្នែកច្បាប់ ឬ គុណសម្បត្តិផ្នែកច្បាប់ ឬ វិជ្ជាជីវៈដែលមានតំលៃស្មើ ។

៣) មានបទពិសោធន៍ការងារជាមេធាវី ចៅក្រម ឬ ព្រះរាជអាជ្ញា ឬ ក្នុងមុខងារផ្សេងទៀតយ៉ាងតិច១០(ដប់)ឆ្នាំ ក្នុងរឿងក្តីព្រហ្មទណ្ឌ។

៤) មានសមត្ថភាពខាងផ្នែកនីតិវិធី និង ច្បាប់ព្រហ្មទណ្ឌជាតិ ឬ អន្តរជាតិ ។ និង

៥) ចេះភាសាខ្មែរ អង់គ្លេស ឬ បារាំង ស្ទាត់ជំនាញ ។

ឃ-មេធាវីជាតិ ដែលបានដាក់ពាក្យសុំ ត្រូវគោរពត្រឹមតែតាមល័ក្ខខ័ណ្ឌដូចខាងក្រោមប៉ុណ្ណោះ ៖

១) ជាសមាជិករបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

២) មានសមត្ថភាពខាងផ្នែកនីតិវិធី និង ច្បាប់ព្រហ្មទណ្ឌជាតិ ឬ អន្តរជាតិ ។

៥. មេធាវី ឬ ជំនួយការរបស់ខ្លួន ដែលពាក្យសុំចុះឈ្មោះរបស់ពួកគេ សម្រាប់ការពារជនក្រីក្រ ដូចមានចែង នៅក្នុងអនុវិធាន ២ ចំណុច(ឃ) និង (ឈ) ខាងលើ ត្រូវបានបដិសេធ ឬ មិនត្រូវបានពិនិត្យក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យដោយអង្គភាពគាំពារការការពារក្តី ឬ ត្រូវបានលុបឈ្មោះចេញពីបញ្ជី អាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងពីសេចក្តីសម្រេចរបស់ប្រធានអង្គភាពគាំពារការការពារក្តី ឬ ក្រោយរយៈពេល ៣០ (សាមសិប)ថ្ងៃកន្លងផុត តាមករណីសមស្រប។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវតវ៉ា។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រភាគច្រើនតាមការកំណត់បានទេ នោះសេចក្តីសម្រេចរបស់ប្រធានអង្គភាពគាំពារការការពារក្តី ត្រូវតម្កល់ទុកជាបានការ ហើយនៅក្នុងករណីដែលពាក្យសុំនោះមិនត្រូវបានពិនិត្យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ត្រូវចាត់ទុកថាបានសម្រេចឲ្យចុះឈ្មោះក្នុងបញ្ជី។

៦. ប្រធានអង្គភាពគាំពារការការពារក្តី ត្រូវសម្រេចអំពីជនណាមួយជាជនក្រីក្រ និងការចាត់តាំងមេធាវីការពារជនក្រីក្រ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលកំណត់នៅក្នុងបទបញ្ជារដ្ឋបាលនៃអង្គភាពគាំពារការការពារក្តី។ សេចក្តីសម្រេចនេះបើកផ្លូវប្តឹងតវ៉ាទៅ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដោយយោងទៅតាមករណី ដែលជននោះត្រូវចូលបង្ហាញខ្លួនក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬ របស់អង្គជំនុំជម្រះ ក្នុងករណីនេះបិទផ្លូវប្តឹងតវ៉ា។

## វិធាន ១២: ការរៀបចំ និងការប្រព្រឹត្តទៅនៃការចូលរួមរបស់ជនរងគ្រោះ

(វិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ និង**វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

ការិយាល័យរដ្ឋបាលត្រូវបង្កើតអង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើម

បណ្តឹងរដ្ឋប្បវេណី ។ អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានស្វ័យភាពពាក់ពន្ធ័នឹងការងារសំខាន់ៗដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។ ការិយាល័យរដ្ឋបាលអាចចុះកិច្ចសន្យាជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ការិយាល័យរដ្ឋបាលក៏ផ្តល់ផងដែរនូវការគាំពារផ្នែករដ្ឋបាលដែលចាំបាច់ដល់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងគ្រប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។

## វិធាន ១២ *ស្ទួន*: អង្គភាពគាំពារជនរងគ្រោះ

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. អង្គភាពគាំពារជនរងគ្រោះត្រូវ៖

ក- ជួយសម្រួលដល់ជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹង ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហព្រះរាជអាជ្ញា ។

ខ- ជួយសម្រួលដល់ជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហចៅក្រមស៊ើបអង្កេត។

គ-រក្សាបញ្ជីឈ្មោះមេធាវីជាតិ និងអន្តរជាតិដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងធ្វើជាតំណាងឲ្យជនរងគ្រោះ ឲ្យអ្នកប្តឹង ឬ ឲ្យសមាគមជនរងគ្រោះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ស្របតាមវិធាន១១ និង២២(១)(ខ) ។

ឃ- គ្រប់គ្រងពាក្យសុំចុះឈ្មោះ ក្នុងបញ្ជីរបស់សមាគមជនរងគ្រោះ ដែលបានទទួលការយល់ព្រមឲ្យបំពេញកិច្ចក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ២៣*ស្ទួន៣* និងថែរក្សាបញ្ជីឈ្មោះសមាគមជនរងគ្រោះដែលបានទទួលការយល់ព្រមរួចហើយ។

ង- ផ្តល់ព័ត៌មានទូទៅដល់ជនរងគ្រោះ និងជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី។

ច-ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ ក្នុងករណីសមស្រប បង្ហាញនូវបញ្ជីឈ្មោះដូចរៀបរាប់ខាងលើ និងពត៌មានអំពីមេធាវី និងសមាគមជនរងគ្រោះ ខាងលើដល់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី និងជួយសម្រួលដល់ការតំណាងតាមផ្លូវច្បាប់ដូចដែលមានចែងក្នុងវិធាន២៣។

ឆ- ជួយសម្រួល និងគាំពារដល់ការចូលរួមនៅក្នុងនីតិវិធីតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យបណ្តឹង។

ជ- នៅពេលសមស្រប ដោយមានការពិគ្រោះយោបល់ជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹង រដ្ឋប្បវេណី និងផ្នែកកិច្ចការសាធារណៈ ទទួលបន្ទុកសកម្មភាពផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធទៅនឹង ជនរងគ្រោះ ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី និង

ឈ-អនុម័តបទបញ្ជារដ្ឋបាលដែលចាំបាច់ដើម្បីធ្វើឱ្យវិធានផ្ទៃក្នុងនេះ អនុវត្តយ៉ាងមានប្រសិទ្ធភាព។

២. ដោយសហការជាមួយសហមេធាវីនាំមុខ និងក្នុងករណីសមស្រប ដោយសម្របសម្រួលជាមួយអង្គការក្នុង និងក្រៅរដ្ឋាភិបាល អង្គភាពគាំពារជនរងគ្រោះ ត្រូវខំប្រឹងខ្នះខ្នែងធ្វើការកំណត់ បង្កើត និងបន្ទាប់មកអនុវត្តគម្រោងដែលមានចែងក្នុងវិធាន ២៣ *ស្ទួនបួន*(៣)(ខ)។

៣. អង្គភាពគាំពារជនរងគ្រោះ ត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើការរៀបចំ និងអនុវត្តកម្មវិធី ព្រមទាំងវិធានការនានាដែលមិនពាក់ពន្ធ័នឹងបច្ចេកទេសតុលាការ ដើម្បីផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះឱ្យកាន់តែទូលំទូលាយ។ ក្នុងករណីដែលសមស្រប កម្មវិធីខាងលើនេះអាចត្រូវបានរៀបចំ និងអនុវត្តដោយមានកិច្ចសហការជាមួយអង្គការក្នុងនិងក្រៅរដ្ឋាភិបាល ដែលស្ថិតនៅក្រៅអង្គជំនុំជម្រះវិសាមញ្ញ ។

## វិធាន ១២ *ស្ទួនពីរ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី*

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ **និងវិសោធនកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១**)

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធានាឱ្យមានប្រសិទ្ធិភាពអំពីការរៀបចំ ការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឱ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់និងតម្រូវការឱ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក។

២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធអំណាច តាមវិធានផ្ទៃក្នុងនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានកាតព្វកិច្ចលើកកំពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវនិងមានប្រសិទ្ធិភាព ។

៣. ជាដំបូង ហើយសំខាន់បំផុត សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវស្វែងរកទស្សនៈផ្សេងៗ ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិង ព្យាយាមសម្របសម្រួលឱ្យអស់ពីលទ្ធភាពដើម្បីឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទ ក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាល

ជំនុំជម្រះ ។ ក្នុងគោលបំណងនេះ នីតិវិធីផ្ទៃក្នុងត្រូវបង្កើតឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការពិគ្រោះពិភាក្សាជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

៤. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរួមមាន មេធាវីជាតិ និងមេធាវីអន្តរជាតិ ដែលត្រូវបានជ្រើសរើស និង ផ្តល់មូលនិធិដោយ អង្គជំនុំជម្រះវិសាមញ្ញ និងត្រូវបានគាំពារដោយបុគ្គលិកមួយចំនួនទៀតតាមការចាំបាច់។ មុខងាររបស់ពួកគាត់ត្រូវចាប់ផ្តើមនៅពេលដែលអង្គជំនុំជម្រះសាលាដំបូង បានទទួលសំណុំរឿង។ កិច្ចទាំងឡាយត្រូវធ្វើឡើងរួមគ្នា លើកលែងតែនៅពេលដែលមានការប្រគល់សិទ្ធិឲ្យទៅនរណាម្នាក់ ក្នុងចំណោមពួកគាត់ តាមរយៈសេចក្តីសម្រេចរួមជាលាយលក្ខណ៍អក្សរ ដើម្បីបំពេញកិច្ច នោះរៀងៗខ្លួន។ ប្រសិនបើ សហមេធាវីនាំមុខទាំងពីរ មិនអាចបំពេញមុខងាររបស់ខ្លួនបានជាបណ្តោះអាសន្ន ដោយសារកាលៈទេសៈពិសេស និងមិនអាចប៉ាន់ស្មានបាន ការិយាល័យរដ្ឋបាល ដោយពិគ្រោះយោបល់ជាមួយសហមេធាវីនាំមុខ បើអាចធ្វើទៅបានត្រូវចាត់តាំងយ៉ាងហោចណាស់មេធាវីមួយរូប ដើម្បីបំពេញតួនាទីទាំងនេះ រហូតដល់ពេលដែលសហមេធាវីនាំមុខណាមួយ អាចបន្តមុខងាររបស់ខ្លួនបាន។

៥. មុខងារសំខាន់ៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរួមបញ្ចូលទាំងៈ

ក. ការតំណាងឲ្យផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ ដូចដែលបានចែងនៅក្នុងវិធាន ២៣(១) និង (២) នៃវិធានផ្ទៃក្នុង ។

ខ. ការទទួលខុសត្រូវជាចុងក្រោយទៅកាន់តុលាការ សំរាប់ការផ្តល់ការអះអាង និងយុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការអំពីផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយនោះ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ។

៦. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវប្រឹងប្រែងឲ្យអស់លទ្ធភាពដើម្បីផ្តល់ការគាំទ្រដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតំណាងផលប្រយោជន៍ឲ្យបណ្តុំនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ។ ការគាំទ្រដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចរួមបញ្ចូលទាំងការដាក់សារណាដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សី និងកិច្ចនីតិវិធីផ្សេងៗទៀត។ ដោយអនុលោមតាម វិធាន ១២ ស្ទួនពីរ (៥) (ខ) ការគាំទ្រនេះត្រូវមានការព្រមព្រៀងគ្នារវាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើម

បណ្តឹងរដ្ឋប្បវេណីដែលពាក់ពន្ធ័។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើការសម្រប សម្រួលសកម្មភាពទាំងឡាយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមវិធីផ្តល់ការគាំទ្រនេះ ។

## គ- ការិយាល័យសហព្រះរាជអាជ្ញា

## វិធាន ១៣: ប្រតិបត្តិការនៃការិយាល័យសហព្រះរាជអាជ្ញា

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. ការិយាល័យសហព្រះរាជអាជ្ញា ត្រូវធ្វើសកម្មភាពដោយឯករាជ្យនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ។ សមាសភាពរបស់ការិយាល័យនេះ រួមមានសហព្រះរាជអាជ្ញា និង មន្ត្រីដទៃទៀតតាមការចាំបាច់ ដោយរាប់បញ្ចូលទាំងក្រឡាបញ្ជីម្នាក់យ៉ាងតិច ។ ដើម្បីអនុវត្តតាមស្មារតីនៃមាត្រា ២២ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ សហព្រះរាជអាជ្ញា អាចជ្រើសរើសព្រះរាជអាជ្ញារង ពីក្នុងចំណោមសហ-ព្រះរាជអាជ្ញារង និងជំនួយការសហព្រះរាជអាជ្ញា ។ ក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ត្រូវរក្សាឯកសារស៊ើបអង្កេតបឋម និងបំពេញសកម្មភាពដទៃទៀតតាមតម្រូវការរបស់សហព្រះរាជអាជ្ញា ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ។

២. ក្នុងការតាក់តែង ឬ ការកែប្រែបទបញ្ជារដ្ឋបាលនៃការិយាល័យរបស់ខ្លួន សហព្រះរាជអាជ្ញាត្រូវធ្វើការពិគ្រោះយោបល់ជាមួយអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលអំពីបញ្ហានានា ដែលអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរការរបស់អង្គជំនុំជម្រះ ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ ការិយាល័យរដ្ឋបាល ។ បទបញ្ជារដ្ឋបាលនេះ ត្រូវអនុម័តយល់ព្រមដោយសហព្រះរាជអាជ្ញាទាំងពីរ ។

៣. វៀរលែងតែសកម្មភាពទាំងឡាយដែលត្រូវធ្វើរួមគ្នា ក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញាអាចផ្ទេរអំណាចទៅឲ្យព្រះរាជអាជ្ញាណាមួយក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប តាមរយៈសេចក្តីសម្រេចរួមគ្នាជាលាយលក្ខណ៍អក្សរដើម្បីឲ្យបំពេញកិច្ចតែម្នាក់ឯងបាន។

៤. វៀរលែងតែកិច្ចការណាដែលច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនេះតម្រូវឲ្យសហព្រះរាជអាជ្ញាអនុវត្តដោយខ្លួនឯងផ្ទាល់ សហព្រះរាជអាជ្ញាអាចផ្ទេរភារកិច្ច

របស់ខ្លួនដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ដូចខាងក្រោម ៖

ក-នៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម ៖ ផ្ទេរភារកិច្ចទៅឲ្យអ្នកស៊ើបអង្កេត លើកលែងតែក្នុងករណីដែលត្រូវអនុវត្តវិធានការបង្ខំ ឬ ទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌។

ខ-នៅគ្រប់ពេលវេលាទាំងអស់: ផ្ទេរភារកិច្ចទៅឲ្យព្រះរាជអាជ្ញារង។

គ-ក្នុងករណីដែលផ្ទេរភារកិច្ចដោយផ្ទាល់មាត់ សហព្រះរាជអាជ្ញាត្រូវប្រគល់លិខិតជាលាយលក្ខណ៍អក្សរ ផ្ទេរភារកិច្ចក្នុងរយៈពេល ៤៨ (សែសិបប្រាំបី)ម៉ោង ក្រោយពេលផ្ទេរភារកិច្ចដោយផ្ទាល់មាត់។

៥. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា នីតិវិធីដែលមានចែងក្នុងវិធាន ៧១ ត្រូវយកមកអនុវត្ត។

៦. សេចក្តីសម្រេចទាំងឡាយរបស់សហព្រះរាជអាជ្ញា បិទផ្លូវប្តឹងតវ៉ា ។

**<u>ឃ- ការិយាល័យសហចៅក្រមស៊ើបអង្កេត</u>**

## វិធាន ១៤: ប្រតិបត្តិការនៃការិយាល័យសហចៅក្រមស៊ើបអង្កេត

**(វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបង្កើតជាការិយាល័យមួយឯករាជ្យ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ សមាសភាពការិយាល័យនេះ រួមមានសហចៅក្រមស៊ើបអង្កេត និងមន្ត្រីជំនួយ តាមការចាំបាច់។

២. សហចៅក្រមស៊ើបអង្កេតនីមួយៗ ត្រូវមានក្រឡាបញ្ជីមួយរូប។ ក្រឡាបញ្ជី ត្រូវរក្សាឯកសារស៊ើបសួរ និងទទួលរ៉ាប់រងនូវកិច្ចការដទៃទៀត តាមតម្រូវការរបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ។

៣. ក្នុងការរៀបចំ និង ការកែប្រែបទបញ្ជារដ្ឋបាលនៃការិយាល័យរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការពិគ្រោះយោបល់ជាមួយអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលអំពីបញ្ហានានាដែលអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរការរបស់អង្គជំនុំជម្រះឬការិយាល័យទាំងនោះ។ បទបញ្ជារដ្ឋបាលនេះត្រូវអនុម័តដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ។

៤. វៀរលែងតែសកម្មភាពណា ដែលតម្រូវឲ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង វិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ច ទៅឲ្យសហចៅក្រមស៊ើបអង្កេត ណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យបំពេញកិច្ចតែម្នាក់ឯងបាន។

៥. វៀរលែងតែកិច្ចការណា ដែលតម្រូវឲ្យអនុវត្តដោយខ្លួនឯងផ្ទាល់ ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ចរបស់ខ្លួនតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសទៅឲ្យអ្នកស៊ើបអង្កេតរបស់ខ្លួន លើកលែងតែក្នុងករណីដែលត្រូវអនុវត្តវិធានការបង្ខំ ឬ ផ្ទេរភារកិច្ច ទៅឲ្យនគរបាលយុត្តិធម៌។

៦. ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបានអវត្តមាន កិច្ចដែលត្រូវបំពេញដោយផ្ទាល់ដោយសហចៅក្រមស៊ើបអង្កេតនោះ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ អាចអនុវត្តបានតាមមធ្យោបាយពីចម្ងាយ។

៧. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត នីតិវិធីដែលមានចែងក្នុងវិធាន ៧២ ត្រូវយកមកអនុវត្ត។

## ខ-នគរបាលយុត្តិធម៌ អ្នកស៊ើបអង្កេត និង ក្រឡាបញ្ជី

### វិធាន ១៥: នគរបាលយុត្តិធម៌

១. នគរបាលយុត្តិធម៌ គឺជាមន្ត្រីជំនួយរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ មន្ត្រីទាំងនេះអនុវត្តការស៊ើបអង្កេត នៅទូទាំងប្រទេសកម្ពុជា ក្រោមការណែនាំតែពីសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ តាមករណីសមស្រប ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។ នៅក្នុងការបំពេញមុខងាររបស់ខ្លួន នគរបាលយុត្តិធម៌ មិនត្រូវស្វែងរក ឬ ទទួលបញ្ជាពីជនណាដទៃទៀតឡើយ។

២. សហព្រះរាជអាជ្ញាត្រូវដឹកនាំ និង សម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌រហូតដល់ការស៊ើបសួរ ត្រូវបានចាប់ផ្តើមដំណើរការ ។ នៅពេលការស៊ើបសួរចាប់ផ្តើមដំណើរការ នគរបាលយុត្តិធម៌ត្រូវបំពេញភារកិច្ច របស់ខ្លួនតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត។

៣. ក្នុងអំឡុងពេលនៃការស៊ើបសួរបន្ថែម ដែលបង្គាប់ឡើងដោយអង្គជំនុំជម្រះ នគរបាលយុត្តិធម៌

ត្រូវបំពេញ ភារកិច្ចតាមការណែនាំរបស់អង្គជំនុំជម្រះ។

៤. សហព្រះរាជអាជ្ញា ត្រូវមានសិទ្ធិអំណាចបញ្ជូនករណីកំហុសវិជ្ជាជីវៈ របស់នគរបាលយុត្តិធម៌ទៅអាជ្ញាធរកម្ពុជា ដែលមានសមត្ថកិច្ច។

### វិធាន ១៦: អ្នកស៊ើបអង្កេត

(វិសោធនកម្មថ្ងៃទី ៦ ខែមិនា ឆ្នាំ ២០០៩)

ដើម្បីអនុវត្តមុខងាររបស់ខ្លួន នៅក្នុងក្របខ័ណ្ឌនៃអង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ មន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកស៊ើបអង្កេត ដោយការិយាល័យសហព្រះរាជអាជ្ញា ឬ ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវតែមានការផ្តល់នីតិសម្បទាដោយក្រសួងយុត្តិធម៌ ។ ក្នុងន័យនេះ ការិយាល័យរដ្ឋបាលត្រូវបញ្ជូនបញ្ជីឈ្មោះអ្នកស៊ើបអង្កេត ជាបន្ទាន់ទៅក្រសួងយុត្តិធម៌ ដើម្បីផ្តល់នីតិសម្បទា។ អ្នកស៊ើបអង្កេតដែលទទួលបាននីតិសម្បទាត្រឹមត្រូវហើយ ត្រូវស្បថនៅចំពោះមុខអង្គជំនុំជម្រះណាមួយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

### វិធាន ១៦ ស្ទួន ក្រឡាបញ្ជី

(អនុម័តថ្ងៃទី០១ ខែកុម្ភៈឆ្នាំ ២០០៨)

ដើម្បីអនុវត្តមុខងាររបស់ខ្លួននៅក្នុង អ.វ.ត.ក ដូចដែលបានចែងក្នុងវិធានផ្ទៃក្នុងនេះ មន្ត្រី អ.វ.ត.ក ដែលត្រូវបំពេញមុខងារជាក្រឡាបញ្ជី ត្រូវទទួលនីតិសម្បទាពីក្រសួងយុត្តិធម៌ ។ ដើម្បីបំពេញតាមតំរូវការនេះ ការិយាល័យរដ្ឋបាលត្រូវបញ្ជូនបញ្ជីឈ្មោះក្រឡាបញ្ជី ជាបន្ទាន់ទៅក្រសួងយុត្តិធម៌ដើម្បីផ្តល់នីតិសម្បទា។

## ច-អង្គជំនុំជម្រះ

### វិធាន ១៧: បទប្បញ្ញត្តិទូទៅ

**(វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. អង្គជំនុំជម្រះត្រូវបង្កើតឡើងជាអង្គភាពឯករាជ្យ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះនីមួយៗ រួមមានចៅក្រម ចៅក្រមបម្រុង ក្រឡាបញ្ជី និងបុគ្គលិកមួយចំនួន តាមតម្រូវការ។

២. ប្រសិនបើចៅក្រមណាម្នាក់ មិនអាចបន្តចូលរួមក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល បទប្បញ្ញត្តិនៃវិធាន ៧៧ វិធាន ៧៩ និង វិធាន ១០៨ ត្រូវយកមកអនុវត្តតាមករណីសមស្រប។

៣. អង្គជំនុំជម្រះត្រូវមានក្រឡាបញ្ជីជាជំនួយការ ដែលត្រូវមានភារកិច្ចរក្សាទុកឯកសារសំណុំរឿងផ្សេងៗនៃដំណើរការរឿងក្តី និងបំពេញសកម្មភាពតាមការណែនាំរបស់អង្គជំនុំជម្រះ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

៤. ក្នុងការរៀបចំ ឬ ការកែប្រែបទបញ្ជារដ្ឋបាលរបស់ខ្លួន អង្គជំនុំជម្រះត្រូវធ្វើការពិគ្រោះយោបល់ជាមួយ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ព្រមទាំងប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល អំពីបញ្ហានានា ដែលអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរការរបស់ការិយាល័យទាំងនេះ ។ បទបញ្ជារដ្ឋបាលនេះត្រូវអនុម័តដោយសម្លេងភាគច្រើនលើសលុបនៃចៅក្រមរបស់អង្គជំនុំជម្រះនីមួយៗ។

## <u>ឆ-ការរៀបចំអង្គជំនុំជម្រះ</u>

### វិធាន ១៨: កិច្ចប្រជុំពេញអង្គ

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០០៩)

១. សហចៅក្រមស៊ើបអង្កេត និងចៅក្រមនៃអង្គជំនុំជម្រះ ក៏ដូចជាចៅក្រមបម្រុង សហព្រះរាជអាជ្ញា និង សហព្រះរាជអាជ្ញាបម្រុង ប្រធានអង្គភាពគាំពារការការពារក្តី ប្រធានអង្គភាពគាំពារជនរងគ្រោះ និង ប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល អាចចូលរួមបានទាំងអស់គ្នា នៅក្នុងកិច្ចប្រជុំពេញអង្គ។

២. ប្រធានអង្គជំនុំជម្រះតុលាការកំពូល ត្រូវធ្វើជាប្រធានដឹកនាំកិច្ចប្រជុំពេញអង្គ ឬ ដឹកនាំដោយចៅក្រមណាម្នាក់ ដែលប្រធានបានចាត់តាំងឲ្យជំនួស ក្នុងករណីដែលប្រធានអវត្តមាន។

៣. វិធានផ្ទៃក្នុងនេះត្រូវអនុម័តតាមនីតិវិធី ដូចខាងក្រោម ៖

ក-ដោយទទួលស្គាល់អំពីឋានៈពិសេសរបស់ព្រះរាជអាជ្ញាជាចៅក្រមដែរ ស្របទៅតាមច្បាប់កម្ពុជា សហព្រះរាជអាជ្ញា ត្រូវមានសិទ្ធិបោះឆ្នោតលើវិធានមួយចំនួន ដែលពាក់ព័ន្ធទៅនឹងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញដែលមានចែងនៅក្នុងជំពូក ១ និង ២ នៃវិធានផ្ទៃក្នុងនេះ។ ការ

អនុម័តត្រូវធ្វើឡើងដោយការបោះឆ្នោតយកសម្លេងភាគច្រើនលើសលុបយ៉ាងតិច ១៥(ដប់ប្រាំ) លើ ២១(ម្ភៃមួយ)នៃសម្លេងរបស់ចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់ដែលមានសិទ្ធិបោះឆ្នោត។

ខ-មានតែសហចៅក្រមស៊ើបអង្កេត និង ចៅក្រមនៃអង្គជំនុំជម្រះប៉ុណ្ណោះ ដែលត្រូវបោះឆ្នោតអនុម័តលើជំពូក ៣ នៃវិធានផ្ទៃក្នុងនេះ។ ការអនុម័តត្រូវធ្វើឡើង ដោយការបោះឆ្នោតយកសម្លេងភាគច្រើនលើសលុបយ៉ាងតិច ១៤ (ដប់បួន)លើ ១៩ (ដប់ប្រាំបួន) សម្លេងរបស់ចៅក្រមទាំងអស់ដែល មានសិទ្ធិបោះឆ្នោត។

គ-សម្លេងភាគច្រើនលើសលុបខាងលើ ត្រូវតែគណនាម្តងទៀតទៅតាមការប្រែប្រួល នៃចំនួនសរុបរបស់ចៅក្រម ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំពេញអង្គ។

ឃ-អ្នកចូលរួមដទៃទៀតនៅក្នុងកិច្ចប្រជុំពេញអង្គដូចជាចៅក្រមបម្រុង និង ព្រះរាជអាជ្ញាបម្រុង អាច ចូលរួមបានក្នុងឋានៈជាអ្នកពិគ្រោះយោបល់ប៉ុណ្ណោះ។

៤. មានតែសហចៅក្រមស៊ើបអង្កេត និង ចៅក្រមជម្រះក្តីទាំងអស់ប៉ុណ្ណោះ ទើបមានសិទ្ធិបោះឆ្នោតលើ សេចក្តីសម្រេចណាមួយផ្សេងទៀតនៅក្នុងកិច្ចប្រជុំពេញអង្គ ។ ការអនុម័តសេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយ សម្លេងគាំទ្រភាគច្រើនលើសលុប ដូចមានចែងក្នុងអនុវិធាន ៣ (ខ) និង (គ)។

៥. នៅពេលដែលចៅក្រមណាម្នាក់មិនអាចចូលរួមបាន ការបោះឆ្នោតអាចធ្វើឡើងបាន តាមរយៈអ្នកទទួលសិទ្ធិប្រទាន ដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរ ក្នុងចំណោមចៅក្រម និង ចៅក្រមបម្រុង ។ នៅពេលដែល ព្រះរាជអាជ្ញាមិនអាចចូលរួមបាន ការបោះឆ្នោតអាចធ្វើឡើងបាន តាមរយៈអ្នកទទួលសិទ្ធិប្រទាន ដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរក្នុងចំណោមព្រះរាជអាជ្ញា ព្រះរាជ-អាជ្ញាបម្រុង និងចៅក្រម ។ គ្មានមន្ត្រីតុលាការណាម្នាក់អាចទទួលសិទ្ធិប្រទានលើសពីម្នាក់បានឡើយ។

៦. កិច្ចប្រជុំពេញអង្គសាមញ្ញត្រូវកោះប្រជុំយ៉ាងយូរបំផុតក្នុងរៀងរាល់ ៦(ប្រាំមួយ)ខែម្តង ដើម្បីបំពេញមុខងារដូចខាងក្រោម ៖

ក- ពិនិត្យមើលឡើងវិញ និង ធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង បើចាំបាច់។

ខ- ពិនិត្យមើលឡើងវិញ និង ធ្វើវិសោធនកម្មលើសេចក្តីណែនាំអនុវត្តដែលបានអនុម័តរួចហើយ ដោយគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង ក្នុងករណីចាំបាច់។

គ- អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ ដែលស្នើឡើងដោយប្រធាន និង អនុប្រធាន

ការិយាល័យរដ្ឋបាល ដើម្បីផ្ញើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

ឃ- ធ្វើការសម្រេចអំពីបញ្ហាពាក់ព័ន្ធទៅនឹងដំណើរការការងារផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញ ទៅតាមសំណើរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ។

ង-អនុវត្តមុខងារដទៃទៀត ដែលមានចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ កិច្ចព្រមព្រៀង ឬ ក្នុងវិធានផ្ទៃក្នុងនេះ។

៧. កិច្ចប្រជុំពេញអង្គសាមញ្ញត្រូវកោះប្រជុំ ដោយប្រធានរបស់កិច្ចប្រជុំពេញអង្គ តាមរយៈការិយាល័យរដ្ឋបាល ។ ករណីបន្ទាន់ និង ដោយយោងទៅលើតម្រូវការផ្នែកថវិកា កិច្ចប្រជុំពេញអង្គវិសាមញ្ញមួយអាចត្រូវរៀបចំធ្វើឡើង ដោយប្រធានរបស់កិច្ចប្រជុំពេញអង្គ តាមគំនិតផ្ដួចផ្ដើមផ្ទាល់ខ្លួន ឬ តាមសំណើភាគច្រើនលើសលុប របស់ចៅក្រមទាំងអស់ដែលមានសិទ្ធិបោះឆ្នោត។

៨. កិច្ចប្រជុំពេញអង្គអាចធ្វើទៅបាន លុះត្រាតែមានកូរ៉ុមភាគច្រើនលើសលុបនៃចៅក្រមទាំងអស់ដែលមានសិទ្ធិបោះឆ្នោត ដោយយោងទៅតាមអនុវិធាន ៣ (ខ) និង (គ) ទោះបីតាមរយៈការចូលរួមដោយផ្ទាល់ខ្លួន អ្នកទទួលសិទ្ធិប្រទាន ឬ មធ្យោបាយពីចម្ងាយក៏ដោយ។

៩. កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើការ និង សេចក្ដីសម្រេចរបស់កិច្ចប្រជុំពេញអង្គជាភាសាខ្មែរ អង់គ្លេស និងបារាំង ត្រូវធ្វើឡើងដោយលេខាធិការដ្ឋាន ។ តាមសំណើរបស់ប្រធានកិច្ចប្រជុំពេញអង្គ សមាជិកនៃលេខាធិការដ្ឋានរួមមានមន្ត្រីដែលផ្ដល់មកពីអង្គជំនុំជម្រះ ឬ/និងការិយាល័យសហព្រះរាជអាជ្ញា ឬ/និង ការិយាល័យសហចៅក្រមស៊ើបអង្កេត តាមករណីចាំបាច់ និង សមស្រប ។

១០. កិច្ចប្រជុំពេញអង្គត្រូវធ្វើជាសម្ងាត់ លើកលែងតែកិច្ចប្រជុំពេញអង្គ សម្រេចផ្សេងពីនេះ ។ កិច្ចប្រជុំពេញអង្គ អាចអនុញ្ញាតឲ្យអ្នកជំនាញខាងក្រៅ ចូលរួមទាំងស្រុង ឬ មួយផ្នែកក្នុងកិច្ចប្រជុំពេញអង្គ។ ការិយាល័យរដ្ឋបាលត្រូវផ្ដល់បុគ្គលិកជំនួយជាចាំបាច់។

### *វិធាន ១៩: គណៈកម្មាធិការរដ្ឋបាលតុលាការ*

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និង ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១. សមាសភាពរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ត្រូវមានចៅក្រមជាតិចំនួន ៣(បី)រូប ដែលចៅក្រមមួយរូបជាប្រធាន និងចៅក្រមអន្តរជាតិចំនួន ២(ពីរ)រូប ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយ

កិច្ចប្រជុំពេញអង្គ។ សមាជិកជំនួសជាតិមួយរូប និង អន្តរជាតិមួយរូប របស់គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើស នៅក្នុងកិច្ចប្រជុំពេញអង្គ ដើម្បីជំនួសសមាជិកដែលអវត្តមាន ទៅតាមតម្រូវការ។ សហព្រះរាជអាជ្ញាទាំងពីររូប និងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការក្នុងឋានៈជាអ្នកពិគ្រោះយោបល់បាន។ នៅពេលណាដែលសមាជិក ឬ សមាជិកជំនួសណាម្នាក់របស់គណៈកម្មាធិការផ្តល់ព័ត៌មាន ដល់កិច្ចប្រជុំពេញអង្គថា ខ្លួនមិនអាច ឬ មានបំណងមិនចង់ធ្វើជាសមាជិករបស់គណៈកម្មាធិការតទៅទៀតទេ កិច្ចប្រជុំពេញអង្គត្រូវប្រជុំបោះឆ្នោតជ្រើសរើសសមាជិកថ្មីណាម្នាក់មកជំនួស។

២. គណៈកម្មាធិការត្រូវផ្តល់ប្រឹក្សា និង ណែនាំដល់ការិយាល័យរដ្ឋបាលអំពីសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងការគាំទ្រផ្នែករដ្ឋបាល និង តុលាការដល់ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះ ដោយរួមទាំងការរៀបចំ និង ការអនុវត្តថវិកា។

៣. គណៈកម្មាធិការត្រូវជួបប្រជុំគ្នាម្តងក្នុងមួយខែ ឬ ដោយគំនិតផ្តួចផ្តើមរបស់ប្រធាន ។ កិច្ចប្រជុំនេះត្រូវធ្វើជាសម្ងាត់ ។ ការចូលរួមពីចម្ងាយអាចរៀបចំធ្វើឡើងបាន តាមការចាំបាច់។

៤. គណៈកម្មាធិការត្រូវបំពេញកិច្ចការដទៃទៀត ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

៥. គណៈកម្មាធិការត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ ។ តាមសំណើរបស់ប្រធានគណៈកម្មាធិការ សមាជិកនៃលេខាធិការដ្ឋានរួមមាន មន្ត្រីដែលផ្តល់មកពីអង្គជំនុំជម្រះ ឬ/និង ការិយាល័យសហព្រះរាជអាជ្ញា ឬ/និង ការិយាល័យសហចៅក្រមស៊ើបអង្កេត តាមករណីចាំបាច់ និង សមស្រប ។ ដើម្បីសម្រេចការងាររបស់ខ្លួន គណៈកម្មាធិការរដ្ឋបាលតុលាការ អាចយកអ្នកជំនាញមកជួយ ដែលជាបន្ទុករបស់អង្គជំនុំជម្រះវិសាមញ្ញ។ ការិយាល័យរដ្ឋបាលត្រូវផ្តល់បុគ្គលិកជំនួយជាចាំបាច់។

## វិធាន ២០: គណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ និងថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. សមាសភាពរបស់គណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង ត្រូវមានចៅក្រមជាតិចំនួន ៥ (ប្រាំ)រូប ដោយមានចៅក្រម ១(មួយ)រូប ធ្វើជាប្រធាន និងចៅក្រមអន្តរជាតិចំនួន ៤(បួន)រូប សមាជិកទាំងអស់ត្រូវបោះឆ្នោតជ្រើសរើសដោយកិច្ចប្រជុំពេញអង្គ ។ សមាជិកជំនួសជាតិមួយរូប និង អន្តរជាតិមួយរូបរបស់គណៈកម្មាធិការនេះ ត្រូវបោះឆ្នោតជ្រើសរើសនៅក្នុងកិច្ចប្រជុំពេញអង្គ ដើម្បីជំនួសសមាជិក ដែល

អវត្តមានទៅតាមតម្រូវការ។ នៅពេលណាដែលសមាជិក ឬសមាជិកជំនួសណាម្នាក់របស់គណៈកម្មាធិការជូនដំណឹងដល់កិច្ចប្រជុំពេញអង្គថា ខ្លួនមិនអាចធ្វើ ឬ លាឈប់ ជាសមាជិករបស់គណៈកម្មាធិការតទៅទៀត កិច្ចប្រជុំពេញអង្គត្រូវប្រជុំបោះឆ្នោតជ្រើសរើសសមាជិកថ្មីណាម្នាក់មកជំនួស។

២. គណៈកម្មាធិការត្រូវទទួល និង ពិចារណាលើសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងនេះ និង រៀបចំសេចក្តីព្រាងស្នើសុំធ្វើវិសោធនកម្ម សម្រាប់ដាក់ជូនកិច្ចប្រជុំពេញអង្គ ។ ក្នុងគោលដៅនេះ គណៈកម្មាធិការត្រូវជួបប្រជុំ តាមការចាំបាច់ តាមគំនិតផ្តួចផ្តើមរបស់ប្រធាន ។ កិច្ចប្រជុំនេះត្រូវធ្វើជាសម្ងាត់។

៣. គណៈកម្មាធិការត្រូវអនុម័តសេចក្តីណែនាំអនុវត្ត ស្តីពីការប្រព្រឹត្តទៅរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយដែលសេចក្តីណែនាំអនុវត្តនេះ ត្រូវពិនិត្យមើលឡើងវិញតាមក្រោយដោយកិច្ចប្រជុំពេញអង្គ ។ ក្នុងគោលដៅនេះ គណៈកម្មាធិការត្រូវជួបប្រជុំតាមការចាំបាច់ ដោយការផ្តួចផ្តើមគំនិតរបស់ប្រធាន ឬ តាមសំណើរបស់ចៅក្រមមួយរូប សហចៅក្រមស៊ើបអង្កេតមួយរូប សហព្រះរាជអាជ្ញាមួយរូប ប្រធានអង្គភាពគាំពារការការពារក្តី ប្រធានអង្គភាពគាំពារជនរងគ្រោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងប្រធាន ឬ អនុប្រធានការិយាល័យរដ្ឋបាល។

៤. គណៈកម្មាធិការត្រូវបំពេញកិច្ចការដទៃទៀត ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

៥. ការចូលរួមប្រជុំក្នុងគណៈកម្មាធិការនេះពីចម្ងាយ អាចរៀបចំធ្វើឡើងបាន តាមការចាំបាច់។

៦. គណៈកម្មាធិការត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ ។ តាមសំណើរបស់ប្រធានគណៈកម្មា-ធិការ សមាជិកនៃលេខាធិការដ្ឋានរួមមាន មន្ត្រីដែលផ្តល់មកពីអង្គជំនុំជម្រះ ឬ/និង ការិយាល័យសហព្រះ-រាជអាជ្ញា ឬ/និង ការិយាល័យសហចៅក្រមស៊ើបអង្កេត តាមករណីចាំបាច់ និង សមស្រប ។ ដើម្បីសម្រេចការងាររបស់ខ្លួន គណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង អាចយកអ្នកជំនាញមកជួយ ដែលជាបន្ទុករបស់អង្គជំនុំជម្រះវិសាមញ្ញ។ ការិយាល័យរដ្ឋបាលត្រូវផ្តល់បុគ្គលិកជំនួយជាចាំបាច់។

## ជំពូក ៣: នីតិវិធី

### ក-បទប្បញ្ញត្តិទូទៅ

### វិធាន ២១: គោលការណ៍ជាសារវ័ន្ត

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត

និងបទបញ្ញារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

ខ-បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និង ត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។

គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាល ទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

២. វិធានការចាប់បង្ខំទាំងឡាយណាចំពោះបុគ្គលណាម្នាក់ត្រូវធ្វើឡើងដោយ ឬ ស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ វិធានការនេះត្រូវតែកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឲ្យបានពេញលេញ។

៣. គ្មានទម្រង់ណាមួយនៃការជំរុញទឹកចិត្ត ការបង្ខំលើរាងកាយ ឬ ការគំរាមកំហែង ត្រូវបានយកទៅអនុវត្ត ក្នុងពេលធ្វើសម្ភាសន៍ ចំពោះអ្នកដែលត្រូវបានសួរយកចម្លើយ ឬ អ្នកដទៃទៀតឡើយ។ ប្រសិនបើទម្រង់ណាមួយនៃស្ថានភាពទាំងនេះត្រូវបានប្រើប្រាស់នោះចម្លើយ ឬ កំណត់ហេតុមិនត្រូវ

ចាត់ទុកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះឡើយ ហើយអ្នកទទួលខុសត្រូវចំពោះករណីនេះត្រូវដាក់វិន័យសមស្របទៅនឹងកំហុសដោយ អនុលោមតាមវិធាន ៣៥ ដល់វិធាន ៣៨។

៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

**វិធាន ២២: មេធាវី**

**(វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. ជនណាដែលមានសិទ្ធិទទួលបានមេធាវីស្ថិតនៅក្រោមវិធានផ្ទៃក្នុងនេះ ត្រូវមានសិទ្ធិទទួលបានជំនួយពីមេធាវីជាតិ ឬ មេធាវីអន្តរជាតិដោយសហការជាមួយមេធាវីជាតិ ទៅតាមការជ្រើសរើសដោយផ្ទាល់ខ្លួនរបស់ពួកគេ តាមបែបបទដូចខាងក្រោម:

ក-ជនដែលមានលទ្ធភាពបង់ប្រាក់កម្រៃដល់មេធាវី ត្រូវមានសិទ្ធិជ្រើសរើសដោយសេរីពីក្នុងចំណោមមេធាវីជាតិ និងអន្តរជាតិដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីសម្របសម្រួលដល់ការជ្រើសរើសនេះ ជនទាំងនេះត្រូវទទួលបាននូវបញ្ជីឈ្មោះមេធាវី ដែលមានសិទ្ធិការពារក្តី ដូចមានចែងក្នុងវិធាន១១.២(គ) ឬ វិធាន១២*ស្ទួន*(១)(គ) សម្រាប់មេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរៀងៗខ្លួន។

ខ-ជនក្រីក្រដែលមានសិទ្ធិទទួលបានការតំណាង ឬ ជំនួយតាមផ្លូវច្បាប់ក្រោមវិធានទាំងនេះ ត្រូវមានសិទ្ធិជ្រើសរើស ដោយសេរីពីក្នុងចំណោមមេធាវីជាតិ និង អន្តរជាតិដែលមានក្នុងបញ្ជីដូចមានចែងក្នុងវិធាន១១.២ (ឃ) សម្រាប់មេធាវីការពារក្តី ឬ ក្រោមវិធាន១២ស្ទួន សម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

គ-មេធាវីអន្តរជាតិ ត្រូវធ្វើការដោយរួមជាមួយមេធាវីជាតិ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

ឃ-ការបញ្ចូលឈ្មោះក្នុងបញ្ជីអង្គភាពគាំពារការការពារក្តី មិនត្រូវបានអនុញ្ញាតឲ្យមេធាវីអន្តរជាតិនោះ ប្រកបវិជ្ជាជីវៈផ្នែកច្បាប់ផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

ង-នៅពេលដែលជនណាម្នាក់ចង់បានមេធាវីអន្តរជាតិ ដែលមិនមានឈ្មោះក្នុងបញ្ជីមេធាវី ដូចមានចែងក្នុងវិធាន ១១.២ (គ) ឬ វិធាន១២*ស្ទួន*(១)(គ) មេធាវីនោះ ត្រូវបំពេញសំណុំបែបបទជាដំបូង ដើម្បីការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងក្នុងវិធាន ១១(២)។

ច-មេធាវីអន្តរជាតិណា ដែលពាក្យសុំចុះឈ្មោះរបស់ខ្លួន នៅគណៈមេធាវីនៃព្រះរាជាណាចក្រ

កម្ពុជាក្នុងគោលបំណងធ្វើជាតំណាងដោយអណត្តិនៅចំពោះមុខអ.វ.ត.កត្រូវបានបដិសេធ ឬ មិនត្រូវបានពិនិត្យក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃទទួលពាក្យដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាពីអង្គភាពគាំពារជនរងគ្រោះ ឬ អង្គភាពគាំពារការការពារក្តី ក្នុងករណីកើតឡើងបែបនេះ អាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលសេចក្តីជូនដំណឹងពីសេចក្តីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬ ក្រោយរយៈពេល ៣០(សាមសិប)ថ្ងៃកន្លងផុត។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវតវ៉ា។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រភាគច្រើនតាមការកំណត់បានទេ នោះសេចក្តីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ទុកជាបានការ។ ហើយបើក្នុងករណីដែលពាក្យសុំនោះមិនត្រូវបានពិនិត្យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃទេ ត្រូវចាត់ទុកថាបានអនុញ្ញាតឲ្យចុះឈ្មោះក្នុងបញ្ជីមេធាវី ។

២. នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បទប្បញ្ញត្តិដូចខាងក្រោមត្រូវយកមកអនុវត្តៈ

ក-មេធាវីជាតិត្រូវស្នើឲ្យទទួលស្គាល់មេធាវីអន្តរជាតិ នៅពេលដែលមេធាវីអន្តរជាតិនោះបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខអង្គភាពតុលាការនីមួយៗរបស់អង្គជំនុំជម្រះវិសាមញ្ញ។ បន្ទាប់ពីត្រូវបានទទួលស្គាល់រួចហើយ មេធាវីអន្តរជាតិរូបនេះត្រូវទទួលបានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

ខ-ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី មេធាវីជាតិមានសិទ្ធិនិយាយមុន ។

៣. រាល់ការទំនាក់ទំនងទាំងអស់រវាងមេធាវី និងកូនក្តីរបស់ពួកគេ ត្រូវរក្សាការសម្ងាត់ ហើយមិនត្រូវមានការលួចស្តាប់ ឬ ថត ឬ ថតចម្លងដោយជនផ្សេងឡើយ។ មេធាវីទាំងអស់ អាចទទួលបានច្បាប់ចម្លងនៃសំណុំរឿង ឬ កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី និងយកឯកសារនេះ រួមជាមួយឯកសារដែលពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួន។ យោងតាមអនុវិធាន២ខាងលើ មេធាវីរបស់ជនដែលស្ថិតក្នុងការឃុំឃាំង អាចទំនាក់ទំនងជាមួយកូនក្តីរបស់ខ្លួនដោយសេរី ដោយគោរពទៅតាមការដាក់កំហិតចាំបាច់នានារបស់រដ្ឋបាលនៃមន្ទីរឃុំឃាំង។

៤. នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពី

ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវ។

៥. មេធាវីជាតិ និងអន្តរជាតិមានសិទ្ធិជ្រើសរើសក្រុមអ្នកច្បាប់ ដើម្បីជួយបំពេញកិច្ចការរបស់ពួកគេ ។ ប៉ុន្តែមេធាវីការពារក្តីសម្រាប់ជនក្រីក្រ ត្រូវជ្រើសរើសក្នុងចំណោមបុគ្គលិកជាតិ និងអន្តរជាតិដែលមានឈ្មោះក្នុងបញ្ជី ដូចមានចែងក្នុងវិធាន ១១.២ (ឈ)។ នៅពេលណាដែលមេធាវីការពារក្តីសម្រាប់ជនក្រីក្រ ចង់ជ្រើសរើសបុគ្គលិកដែលមិនមានឈ្មោះក្នុងបញ្ជីដូចមានចែងក្នុង វិធាន ១១.២ (ឈ) បុគ្គលនោះត្រូវតែបំពេញសំណុំបែបបទជាដំបូងសិន ដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជី។

## វិធាន ២៣: គោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ និង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ និង ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី ៖

ក-ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង

ខ- ទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាន២៣ *ស្ទួនបួន*។

២. សិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងដោយគ្មានការរើសអើងចំពោះលក្ខណៈវិនិច្ឆ័យ ដូចជាលំនៅដ្ឋានបច្ចុប្បន្ន ឬ សញ្ជាតិឡើយ។

៣. ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមជាលក្ខណៈបុគ្គល នៅក្នុងដំណាក់កាលមុនជំនុំជម្រះ។ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរួមបញ្ចូលក្រុមតែមួយដែលផលប្រយោជន៍របស់ពួកគាត់ត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងវិធាន ១២ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។ សហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវជំនួយដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដូចមានចែងនៅក្នុងវិធាន ១២ *ស្ទួនពីរ* (៣) នៃវិធានផ្ទៃក្នុង។ សហ

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ការទាមទាររួមតែមួយប៉ុណ្ណោះនូវសំណង ផ្លូវចិត្តនិងសមូហភាព។

៤. ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានគេសាកសួរដូចជាសាក្សីធម្មតាក្នុងរឿងក្តីតែមួយនេះបានទេ ហើយស្របតាមវិធាន៦២ ដែលទាក់ទងនឹងដីកាចាត់ឲ្យស៊ើបសួរជំនួស អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះដោយស្ថិតក្រោមលក្ខខ័ណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬ ជនជាប់ចោទដែរ។

## វិធាន ២៣ *ស្ទួន*. បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវៈ

ក - បង្ហាញពីអត្តសញ្ញាណអោយបានច្បាស់លាស់

ខ-បង្ហាញ ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្តនិងសមូហភាព ។

នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

២. ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ (១៥) ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរ តាមផ្លូវតុលាការដោយអនុលោមតាមវិធាន៦៦(១)។ អនុលោមតាមបទប្បញ្ញត្តិ ស្តីពីវិធានការការពារជនរងគ្រោះ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើកផ្លូវឲ្យប្តឹងឧទ្ធរណ៍សង្ខេប ទៅអង្គបុរេជំនុំជម្រះដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុង

សេចក្ដីណែនាំអនុវត្ត។ បណ្ដឹងឧទ្ធរណ៍សង្ខេបនេះ មិនផ្អាកដំណើរការនីតិវិធីទេ។ លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណីបាន។

៣. នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក។ ដីកានេះត្រូវបើកផ្លូវប្ដឹងឧទ្ធរណ៍សង្ខេប ដោយភាគី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដូចដែលមានចែងក្នុងវិធាន ៧៧ ស្ទួន ។ បណ្ដឹងឧទ្ធរណ៍សង្ខេបនេះមិនផ្អាកដំណើរការនីតិវិធីទេ។ រាល់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ តាមរយៈការប្ដឹងឧទ្ធរណ៍សង្ខេបដូចមានចែងនៅក្នុងវិធាននេះ ត្រូវបង្កើតជាក្រុមរួមបញ្ចូលគ្នាតែមួយ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ អនុលោមតាមវិធាន ២៣(៥) នៃវិធានផ្ទៃក្នុង។ នៅពេលដែលអង្គបុរេជំនុំជម្រះប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់បុគ្គលណាម្នាក់មិនអាចទទួលយកបាន ក្រោយពេលអង្គជំនុំជម្រះសាលាដំបូង បានទទួលសំណុំរឿង បុគ្គលនោះនឹងត្រូវដកចេញពីក្រុមនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នាតែមួយនោះ។

៤. គ្រប់ពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យ ពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្ដឹងជាមួយនឹងវិធានផ្ទៃក្នុងនេះ ។ ជាពិសេសពាក្យបណ្ដឹងត្រូវផ្ដល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្ដុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬ ការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវចោទប្រកាន់ ។ ពាក្យបណ្ដឹងត្រូវតែមានការបញ្ជាក់ ឲ្យបានត្រឹមត្រូវអំពីលំនៅដ្ឋានរបស់ជនរងគ្រោះ ការិយាល័យចុះបញ្ជីរបស់សមាគមជនរងគ្រោះដែលខ្លួនជាសមាជិក ឬ អាសយដ្ឋានរបស់មេធាវី ដើម្បីងាយស្រួលដល់ការបញ្ជូន និង ការជូនដំណឹង ។ នៅពេលដែលអាស័យដ្ឋាននេះស្ថិតនៅក្រៅប្រទេសកម្ពុជា អ្នកប្ដឹងត្រូវតែផ្ដល់អាស័យដ្ឋានមួយនៅក្នុង ប្រទេសកម្ពុជា។

៥. នៅគ្រប់ពេលទាំងអស់នៃដំណាក់កាលមុនជំនុំជម្រះ ដើមបណ្ដឹងរដ្ឋប្បវេណីអាចលះបង់សិទ្ធិ ដោយច្បាស់លាស់ នូវការទាមទារសំណងការខូចខាត និងបោះបង់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួនបាន ។ ការលះបង់សិទ្ធិ ឬ បោះបង់ពាក្យសុំនេះមិនអាច បញ្ឈប់ ឬ ផ្អាកបណ្ដឹងអាជ្ញាបានទេ។ នៅគ្រប់ពេលទាំងអស់ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗអាចដកខ្លួនចេញ

ពីក្រុមនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នាតែមួយនោះបាន ។

៦. ក្នុងករណីដែលជនត្រូវចោទ ឬ ជនជាប់ចោទទទួលមរណភាព ដំណើរការនីតិវិធីបណ្តឹងរដ្ឋប្បវេណី នៅមុខ អ.វ.ត.ក ចំពោះជនត្រូវចោទ ឬ ជនជាប់ចោទរូបនោះ នឹងត្រូវបញ្ចប់ ។

## វិធាន ២៣ *ស្ទួនពីរ*: ការតំណាងដើមបណ្តឹងរដ្ឋប្បវេណី

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ **និងវិសោធនកម្មថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. ចាប់ពីពេលចេញដីកាដំណោះស្រាយតទៅ ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយត្រូវតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប នៅគ្រប់ពេលទាំងអស់ ។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសមស្របនានាសម្រាប់គោលបំណងនេះ តាមពេលវេលាសមរម្យដែលអាចអនុវត្តបាន ប៉ុន្តែយ៉ាងយូរបំផុត នៅពេលចេញដីកាដំណោះស្រាយ។ ក្នុងករណីដែលលែងមានមេធាវីតំណាង ហើយបើដើមបណ្តឹងរដ្ឋប្បវេណីមានបំណងបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវរកមេធាវីផ្សេងមកជំនួស។ ក្នុងករណីចាំបាច់ អង្គភាពតុលាការដែលពាក់ពន្ធ័ អាចណែនាំដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលរួមជាមួយក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលមានស្រាប់។

២. នៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយមេធាវី សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានអនុវត្តតាមរយៈមេធាវីនោះ។ អនុវិធាននេះ មិនត្រូវយកមកអនុវត្តទេ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានគេស្តាប់ចម្លើយតាមវិធាន ៥៩ និងវិធាន ៩១(១)។

៣. ដើមបណ្តឹងរដ្ឋប្បវេណី អាចបង្កើតជាក្រុម និងជ្រើសរើសមេធាវីឲ្យធ្វើជាតំណាងក្រុមជារួម ចេញពីបញ្ជីដែលរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ ។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចរៀបចំឲ្យមានតំណាងរួមដូចខាងក្រោម៖

ក-ក្នុងករណីដែលតម្រូវឲ្យមានផលប្រយោជន៍នៃយុត្តិធម៌ សហចៅក្រមស៊ើបអង្កេត អាចតម្រូវអោយដើមបណ្តឹងរដ្ឋប្បវេណី បង្កើតជាក្រុមដើម្បីជ្រើសរើសមេធាវីម្នាក់ ឬ ច្រើននាក់ធ្វើជាតំណាងរួមក្នុងរយៈពេលកំណត់ណាមួយ។

ខ-នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាច ចងក្រងដើមបណ្តឹងរដ្ឋប្បវេណីជាក្រុម ឬ ចាត់ពួកគេឲ្យចូលក្នុងក្រុមដែលមានស្រាប់ និង/ ឬ ចាត់តាំង

មេធាវីរួមមួយរូបសម្រាប់ក្រុមនេះ បន្ទាប់ពីពិគ្រោះយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ។

គ-សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អង្គភាពគាំពារជនរងគ្រោះ ត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បីធានាថា ក្នុងការជ្រើសរើសមេធាវីតំណាងឱ្យក្រុមផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗត្រូវបានគោរព និងទំនាស់ផលប្រយោជន៍ដទៃទៀត ក៏ត្រូវបានចៀសវាង។

ឃ-គ្រប់ពេលវេលាទាំងអស់ ដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យសុំដោយមានបញ្ជាក់ពីមូលហេតុទៅសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ឱ្យពិចារណាឡើងវិញអំពីការចាត់តាំងមេធាវីរបស់ពួកគេ ដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ និង

ង-ដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្វះលទ្ធភាពបង់ប្រាក់កម្រៃដល់មេធាវី ដែលតំណាងរួមឱ្យក្រុមដែលចាត់តាំងដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាចស្វែងរកជំនួយពីការិយាល័យរដ្ឋបាល។

**វិធាន ២៣ ស្ទួនបី: សមាគមជនរងគ្រោះ**

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. ក្រុមជនរងគ្រោះអាចចូលជាសមាជិកសមាគមជនរងគ្រោះណាមួយ ដើម្បីរៀបចំពាក្យបណ្តឹងសុំតាំងខ្លួនជាដើមរដ្ឋប្បវេណីរបស់ខ្លួន ដូចខាងក្រោម:

ក-ដើម្បីជួយសម្រួល ឱ្យមានការរៀបចំពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួមគ្នា អង្គភាពគាំពារជនរងគ្រោះ អាចផ្តល់ឱ្យជនរងគ្រោះ នូវបញ្ជីឈ្មោះសមាគមជនរងគ្រោះ ដោយស្ថិតនៅក្រោមការឃ្លាំមើល របស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះសាលាដំបូង។

ខ-ដើម្បីអាចបញ្ចូលទៅក្នុងបញ្ជីបាន សមាគមជនរងគ្រោះត្រូវផ្តល់ឱ្យ អង្គភាពគាំពារជនរងគ្រោះ នូវឯកសារដែលបង្ហាញថាសមាគមនេះបានចុះបញ្ជីត្រឹមត្រូវ ឬ បានបង្កើតឡើងនៅក្នុងប្រទេសដែលសមាគមបានធ្វើសកម្មភាព និង បានទទួលអនុញ្ញាតឱ្យធ្វើសកម្មភាពក្នុងនាមសមាជិកខ្លួន ដូចមានចែងក្នុងសេចក្តីណែនាំអនុវត្ត ។ ករណីដែលថា សមាគមជនរងគ្រោះមួយតំណាងឱ្យជនរងគ្រោះដែលមានអាស័យដ្ឋាននៅឯបរទេស នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញមិនត្រូវបកស្រាយថា ជាការធ្វើសកម្មភាពក្នុងប្រទេសកម្ពុជា ដើម្បីទទួលបាននូវការយល់ព្រមអនុលោមតាមអនុវិធាននេះឡើយ។

គ-ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាសមាជិករបស់សមាគមជនរងគ្រោះមួយ ត្រូវតែតំណាងដោយមេធាវីរបស់សមាគមនោះ ហើយការកោះឲ្យចូលខ្លួន និងការជូនដំណឹងដល់សមាជិកសមាគមត្រូវធ្វើឡើងតាមរយៈសមាគម។

ឃ-ករណីដែលថា ជនរងគ្រោះខ្លះ ដែលជ្រើសរើសការធ្វើពាក្យបណ្តឹងរបស់ខ្លួនតាមរយៈសមាគមជនរងគ្រោះនោះ មិនត្រូវមានផលប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះដទៃទៀតទេ ក្នុងការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីតែមួយ។

ង-រាល់សមាគមជនរងគ្រោះ ដែលពាក្យសុំចុះឈ្មោះក្នុងបញ្ជីខាងលើត្រូវបានបដិសេធ ឬ មិនត្រូវបានពិនិត្យក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យដោយអង្គភាពគាំពារជនរងគ្រោះ ឬ ត្រូវបានលុបឈ្មោះចេញពីបញ្ជី អាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងពីសេចក្តីសម្រេចរបស់ប្រធានអង្គភាពគាំពារជនរងគ្រោះ ឬ ក្រោយរយៈពេល៣០ (សាមសិប) ថ្ងៃកន្លងផុត តាមករណីសមស្រប។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្តឹងតវ៉ា។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរកសម្លេងគាំទ្រភាគច្រើនតាមការកំណត់បានទេនោះសេចក្តីសម្រេចរបស់ប្រធានអង្គភាពគាំពារជនរងគ្រោះត្រូវតម្កល់ទុកជាបានការ។ ប៉ុន្តែក្នុងករណីដែលពាក្យសុំនោះ មិនត្រូវបានពិនិត្យក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃទេ ត្រូវចាត់ទុកថា អង្គបុរេជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យចុះឈ្មោះក្នុងបញ្ជី។

## វិធាន ២៣ *ស្ទួនបួន*: បណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនចាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ តាមគោលបំណងនៃ វិធានទាំងនេះ សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានការទាំងឡាយដែល:

ក)ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស និង

ខ)ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងការខូចខាតនេះ។

ផលប្រយោជន៍ទាំងនេះ មិនត្រូវមានទម្រង់នៃសំណងជាប្រាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

២.	សំណាងត្រូវតែស្នើឡើងជាសេចក្តីសន្និដ្ឋានរួមតែមួយ ដែលសេចក្តីសន្និដ្ឋាននេះ អាចធ្វើការទាមទារសំណាងមួយចំនួនមានកំណត់។ សេចក្តីសន្និដ្ឋាននេះត្រូវផ្តល់នូវ៖

ក)ការពិពណ៌នាអំពីសំណាងដែលត្រូវទាមទារ។

ខ)ទឡ្ហីករណ៍សមហេតុផលដូចជា ការលើកពីការខូចខាតដែលពួកគេទទួលរង និងក្នុងករណីដែលអាចអនុវត្តបាន បញ្ជាក់អំពីក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមរួមដែលពួកគេជាប់ពាក់ព័ន្ធ។

គ)ទម្រង់នៃការអនុវត្តជាក់លាក់តែមួយលើសំណាងនីមួយៗ ដែលមានចែងក្នុងវិធាន ២៣*ស្ទួនបួន* (៣)(ក), (ខ) ដែលទាមទារ។

៣.	នៅពេលសម្រេចអំពីបែបបទនៃការអនុវត្តសំណាង ពាក់ពន្ធ័នឹងសំណាងនីមួយៗ អង្គជំនុំជម្រះអាច៖

ក) បង្គាប់ថា សោហ៊ុយនៃសំណាងត្រូវតែជាបន្ទុករបស់ពិរុទ្ធជន ឬ

ខ) ទទួលស្គាល់នូវគម្រោងជាក់លាក់ដែលមានលក្ខណៈសមស្របឆ្លើយតបទៅនឹងសំណាងដែលទាមទារដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយអាចអនុវត្តបាន។ គម្រោងបែបនេះនឹងត្រូវបានគេបង្កើតឡើង ឬ បង្ហាញច្បាស់លាស់ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ ហើយបានធានានូវការផ្តល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅ។

**វិធាន ២៤**: **សាក្សី**

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១.	មុនពេលត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត ឬ ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ សាក្សីម្នាក់ៗ ត្រូវធ្វើសម្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត។

២.	សាក្សីដូចរៀបរាប់ខាងក្រោមត្រូវឆ្លើយដោយមិនចាំបាច់ធ្វើសម្បថ ៖

ក-ឪពុក ម្តាយ និង បុព្វញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។

ខ-កូនស្រី កូនប្រុស និង បច្ឆាញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

គ-បងប្អូនប្រុសស្រីរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

ឃ-បងប្អូនថ្លៃប្រុសស្រីរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

ង-សហព័ទ្ធរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ទោះបីពួកជាបានលែងលះគ្នាហើយ ក៏ដោយ និង

ច-ក្មេងដែលមានអាយុតិចជាង ១៤ (ដប់បួន)ឆ្នាំ។

៣. សហចៅក្រមស៊ើបអង្កេត ត្រូវសាកសួរសាក្សីទាំងអស់ដើម្បីឲ្យដឹងថាតើសាក្សីទាំងនោះមានទំនាក់ទំនងញាតិយ៉ាងណាជាមួយជនត្រូវចោទ ឬ ជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដូចមានចែងក្នុងអនុវិធាន២ខាងលើ។ ទាក់ទិនទៅនឹងសាក្សីទាំងអស់ ប្រធានអង្គជំនុំជម្រះសាលាដំបូង ត្រូវកំណត់ថាតើសាក្សីទាំងនោះមានទំនាក់ទំនងញាតិយ៉ាងណាជាមួយជនជាប់ចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ដូចមានចែងក្នុងអនុវិធាន២ខាងលើ។

៤. សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះមិនត្រូវកោះហៅក្នុងនាមជាសាក្សីទេ ចំពោះបុគ្គលណាដែល មានភស្ដុតាងបង្ហាញថា មានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទឧក្រិដ្ឋ លើកលែងតែបទ-ប្បញ្ញត្តិដែលមានចែងក្នុងវិធាន ២៨។

### វិធាន ២៥: ការថតសម្លេង ឬ រូបភាពក្នុងពេលសួរយកចម្លើយ

(វិសោធនកម្ម ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០០៨)

១. ក្នុងគ្រប់កាលៈទេសៈដែលអាចធ្វើទៅបាន នៅពេលសហព្រះរាជអាជ្ញា ឬ សហចៅក្រម-ស៊ើបអង្កេត សួរយកចម្លើយពីជនសង្ស័យ ឬជនត្រូវចោទ ត្រូវតែថតយកសម្លេង ឬ ថតរូបភាពបន្ថែមពីលើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយនេះ ។ ការថតយកសម្លេង ឬ ថតយករូបភាពនៃការសួរចម្លើយ ត្រូវតែអនុវត្តទៅតាមនីតិវិធីដូចខាងក្រោម:

ក-ជនដែលត្រូវគេសួរយកចម្លើយ ត្រូវបានជូនព័ត៌មានជាភាសាដែលគាត់យល់ និង និយាយបានដោយពេញលេញ ហើយជនដែលត្រូវគេសួរយកចម្លើយត្រូវបានគេប្រាប់ឲ្យដឹងថា ការសួរចម្លើយនឹងត្រូវថតយកសម្លេង ឬ រូបភាព ហើយការជំទាស់ណាមួយរបស់បុគ្គលដែលពាក់ព័ន្ធ ត្រូវចុះនិទ្ទេសនៅក្នុងសំណុំរឿង។

ខ-ការបោះបង់សិទ្ធិមានវត្តមានមេធាវីក្នុងពេលសួរចម្លើយ ត្រូវថតយកសម្លេង ឬ រូបភាព។

គ-ក្នុងករណីមានការអាក់ខានក្នុងពេលសួរយកចម្លើយ ហេតុការណ៍ និងពេលវេលានៃការអាក់ខាននោះ ត្រូវកត់ត្រាទុកមុនពេលការថតសម្លេង និង រូបភាពត្រូវបានបញ្ចប់ រួមជាមួយនឹងពេលវេលាដែលត្រូវសួរចម្លើយបន្តផងដែរ។

ឃ-នៅពេលបញ្ចប់ការសួរយកចម្លើយ ជនដែលត្រូវបានគេសួរ ត្រូវបានផ្ដល់ឱកាសឲ្យធ្វើការបញ្ជាក់ឡើងវិញនូវចំណុចដែលខ្លួនបាននិយាយ និងបន្ថែមចំណុចណាផ្សេងទៀតដែលខ្លួនចង់

បន្ថែម ។ ពេលវេលានៃការបញ្ចប់ការសួរយកចម្លើយត្រូវចុះក្នុងកំណត់ហេតុ។

ង-ឯកសារថតចម្លងមួយច្បាប់ ឬ ប្រសិនបើឧបករណ៍ថតច្រើនដទៃទៀត ត្រូវបានប្រើប្រាស់ ឯកសារដែលជាច្បាប់ដើមមួយច្បាប់ ត្រូវប្រគល់ទៅឲ្យជនដែលត្រូវបានសួរយកចម្លើយ។

ច-ឯកសារច្បាប់ដើម ឬ ឯកសារច្បាប់ដើមណាមួយក្នុងចំណោមឯកសារច្បាប់ដើមដទៃទៀត ត្រូវបិទស្លាកបោះត្រា នៅចំពោះមុខជនដែលត្រូវបានសួរយកចម្លើយ និងមេធាវីរបស់គេ ប្រសិនបើមានវត្តមាន ហើយនៅខាងក្រោមគឺហត្ថលេខារបស់សហព្រះរាជអាជ្ញា ឬ សហចៅក្រម-ស៊ើបអង្កេត និងជនដែលត្រូវបានសួរយកចម្លើយ និង មេធាវីរបស់ពួកគេ ប្រសិនបើមានវត្តមាន។

ឆ-ឯកសារថតយកសំលេង ឬ រូបភាពទាំងនេះអាចត្រូវប្រើក្នុងករណីមានការប្រកែកជំទាស់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុសួរយកចម្លើយជាលាយលក្ខណ៍អក្សរ ។ និង

ជ-ច្បាប់ចម្លងនៃការថតយកសំលេង ឬ រូបភាព ត្រូវផ្តល់ឲ្យសហព្រះរាជអាជ្ញា និង ភាគីផ្សេងទៀតតាមរយៈមេធាវីរបស់គេ តាមការស្នើសុំ។

២. ការសួរយកចម្លើយអាចត្រូវបានធ្វើឡើងដោយមិនចាំបាច់មានការថតសម្លេង ឬ ថតជារូបភាព នៅពេលណាដែលកាលៈទេសៈរារាំងចំពោះការថតនេះ។ក្នុងករណីនេះ មូលហេតុដែលមិនអាចធ្វើការថតបានក្នុងពេលសួរយកចម្លើយ ត្រូវចុះក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ ហើយជនដែលត្រូវបានសួរយកចម្លើយ ត្រូវទទួលបាននូវឯកសារថតចម្លងមួយច្បាប់នៃចម្លើយរបស់ខ្លួន។ ចម្លើយទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុសួរយកចម្លើយ និងបើអាចធ្វើទៅបាន ត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដែលត្រូវបានស្តាប់ចម្លើយ ឬ សួរចម្លើយ។

៣. នៅពេលណាជនត្រូវបានសួរយកចម្លើយ បដិសេធក្នុងការចុះហត្ថលេខាលើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយ ការបដិសេធនេះត្រូវចុះនិទ្ទេសដាក់ក្នុងសំណុំរឿង រួមជាមួយមូលហេតុនៃការបដិសេធនេះផង បើអាចដឹង។

៤. សហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត អាចជ្រើសយកនីតិវិធីដែលមានចែងនៅក្នុងវិធាននេះ នៅពេលធ្វើការសួរយកចម្លើយជនដទៃទៀត ក្រៅពីជនដែលមានរៀបរាប់ខាងលើ ជាពិសេសនៅពេលដែលការប្រើប្រាស់នីតិវិធីបែបនេះអាចជួយកាត់បន្ថយភាពភ័យខ្លាចរបស់ជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ ឬ អំពើហឹង្សាផ្នែកយ៉េនឌ័រ កុមារ ជនចាស់ជរា និង ជនពិការ ក្នុងការផ្តល់ភស្តុតាង។

៥. អង្គជំនុំជម្រះអាចចេញបញ្ជាផងដែរឲ្យអនុវត្តនីតិវិធីដែលមានចែងក្នុងវិធាននេះ ចំពោះការសួរយក

ចម្លើយបុគ្គលទាំងឡាយណា ដែលមកបង្ហាញខ្លួនចំពោះអង្គជំនុំជម្រះវិសាមញ្ញ។

## វិធាន ២៦: ការធ្វើសក្ខីកម្មដោយផ្សាយបន្តផ្ទាល់ តាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍

១. សក្ខីកម្មរបស់សាក្សី ឬ អ្នកជំនាញនៅក្នុងអំឡុងពេលស៊ើបសួរ ឬ ការជំនុំជម្រះត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសាក្សីធ្វើសក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍ ក្នុងករណីដែលបច្ចេកវិទ្យាបែបនេះអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ និង ភាគីសាកសួរសាក្សីបាន នៅពេលដែលសាក្សីត្រូវឡើងធ្វើសក្ខីកម្ម ។ បច្ចេកវិទ្យានេះមិនត្រូវអនុញ្ញាតឲ្យប្រើទេ ប្រសិនបើធ្វើឲ្យមានអន្តរាយធ្ងន់ធ្ងរ ឬ មិនស្របទៅនឹងសិទ្ធិការពារខ្លួន។

២. នៅក្នុងករណីផ្សេងទៀត ការស្តាប់ចម្លើយសាក្សីក្រោមវិធាននេះ ត្រូវតែអនុវត្តឲ្យស្របទៅតាមវិធានផ្ទៃក្នុងនេះ។

## វិធាន ២៧: ជនដែលគ ឬ ថ្លង់

នៅពេលសួរយកចម្លើយជនដែលគ ឬ ថ្លង់ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ត្រូវសរសេរសំណួរជាលាយលក្ខណ៍អក្សរសម្រាប់ឲ្យជននោះអាន និង ធ្វើការឆ្លើយសំណួរជាលាយលក្ខណ៍អក្សរ ។ ក្នុងករណីដែលជនគ ឬ ថ្លង់នោះជាអនក្ខរជន ក្រឡាបញ្ជីត្រូវស្វែងរកជនដែលអាចធ្វើការទំនាក់ទំនងយ៉ាងត្រឹមត្រូវជាមួយជនគ ឬ ថ្លង់នោះ។ ជនដែលជួយក្នុងការធ្វើទំនាក់ទំនងនោះ ត្រូវធ្វើសច្ចាប្រណិធានតាមនីតិវិធី ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ ។

## វិធាន ២៨: សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី

១. សាក្សីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬ ធ្វើអំណះអំណាងណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីនេះ ត្រូវយកមកអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី ដូចជាការអង្កេតបឋមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ការស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និង ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ។

២.	ប្រសិនបើសាក្សីមិនត្រូវបានជូនដំណឹងអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងទេ សហព្រះរាជ-អាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវជូនដំណឹងអំពីសិទ្ធិនេះដល់សាក្សី មុនពេលស្តាប់ចម្លើយ ឬ ធ្វើសក្ខីកម្ម។

៣.	នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះតម្រូវឲ្យសាក្សីឆ្លើយសំណួរមួយ ឬ ច្រើន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចធានាចំពោះសាក្សីនោះជាមុន ប្រសិនបើអាចធ្វើបានថាភស្តុ-តាង ដែលជាចម្លើយតបនឹងសំណួរ ៖

ក-ត្រូវរក្សាជាការសម្ងាត់ និង មិនត្រូវបើកចំហរដល់សាធារណៈជន និង/ឬ

ខ-មិនត្រូវបានប្រើប្រាស់ដោយផ្ទាល់ ឬ ដោយប្រយោលប្រឆាំងនឹងសាក្សីនោះ នៅក្នុងការចោទប្រកាន់ បន្តបន្ទាប់ទៀតដែលធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញឡើយ។

៤.	មុនពេលផ្តល់ការធានាបែបនេះ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវសួរយោបល់ពីសហ-ព្រះរាជអាជ្ញាដើម្បីកំណត់ថា តើការធានានេះគួរត្រូវផ្តល់ជូនដល់សាក្សីនោះឬទេ។

៥.	ក្នុងការកំណត់ថា តើត្រូវឲ្យសាក្សីឆ្លើយទៅនឹងសំណួរ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវពិចារណាទៅលើ ៖

ក-សារៈសំខាន់នៃភស្តុតាងដែលអាចស្មានទុកជាមុន។

ខ-ថាតើសាក្សីនោះជាអ្នកដែលអាចផ្តល់ភស្តុតាងដែលមានលក្ខណៈពិសេសតែមួយគត់នោះ ឬ យ៉ាងណា។

គ-លក្ខណៈនៃពិរុទ្ធភាពដែលអាចចោទប្រកាន់ទៅលើសាក្សីនោះ ប្រសិនអាចដឹង។ និង

ឃ-ភាពគ្រប់គ្រាន់នៃវិធានការការពារដល់សាក្សី ក្នុងកាលៈទេសៈពិសេស។

៦.	ប្រសិនបើសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ យល់ឃើញថា មិនអាចផ្តល់នូវការធានាសមស្រប ដល់សាក្សីនោះ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះមិនត្រូវតម្រូវឲ្យសាក្សីឆ្លើយទៅនឹងសំណួរនោះទេ ប៉ុន្តែ អាចបន្តសួរសាក្សីលើសំណួរផ្សេងដទៃទៀតបាន។

៧.	ដើម្បីឲ្យការធានាមានប្រសិទ្ធភាព សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្របអាច ៖

ក-បង្គាប់ថា ការផ្តល់ភស្តុតាងរបស់សាក្សីត្រូវធ្វើឡើងដោយសម្ងាត់។

ខ-បង្គាប់ថា អត្តសញ្ញាណរបស់សាក្សី និងខ្លឹមសារនៃភស្តុតាង មិនត្រូវបើកចំហរឱ្យដឹងតាមគ្រប់រូបភាពទាំងអស់ ហើយត្រូវចែងថា ការល្មើសមិនគោរពតាមការបញ្ជានេះត្រូវទទួលទណ្ឌកម្ម ដូចដែលមាន ចែងក្នុងវិធាន ៣៥ និង ៣៨។

គ-ណែនាំជាពិសេសដល់ភាគី និងតំណាងស្របច្បាប់របស់ភាគី អំពីផលវិបាកនៃការមិនគោរពតាមការបង្គាប់ដូចមានចែងក្នុងវិធាននេះ។

ឃ-ចេញបង្គាប់ឲ្យបោះត្រាលើឯកសារកំណត់ហេតុនៃដំណើរការនីតិវិធី និង

ង-ប្រើប្រាស់វិធានការការពារ ដូចមានក្នុងវិធាន ២៩ ដើម្បីធានាថា អត្តសញ្ញាណរបស់សាក្សី និិង ខ្លឹមសារ នៃភស្តុតាងមិនត្រូវបានបើកចំហរ។

៨. នៅពេលដែលភាគីណាមួយដឹងថា ការធ្វើសក្ខីកម្មរបស់សាក្សីណាម្នាក់អាចបណ្តាលឲ្យមានបញ្ហាពាក់ព័ន្ធ ទៅនឹងការដាក់ពិរុទ្ធលើខ្លួនឯង ឬ ក៏នៅពេលណាដែលសាក្សីលើកឡើងនូវបញ្ហានេះដោយខ្លួនឯង នោះភាគីត្រូវស្នើឲ្យធ្វើសវនាការដោយសម្ងាត់ និងជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះអំពីបញ្ហានេះ មុនពេលការធ្វើសក្ខីកម្មលើសាក្សីនោះ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់វិធានការដូចមានចែង ក្នុងអនុវិធាន ៧ នៃវិធាននេះ សម្រាប់ផ្នែកណាមួយ ឬទាំងអស់នៃការធ្វើសក្ខីកម្មរបស់សាក្សីនោះ។

៩. ប្រសិនបើបញ្ហាណាមួយនៃការដាក់ពិរុទ្ធលើខ្លួនឯងកើតឡើង ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវផ្អាកការធ្វើសក្ខីកម្មរបស់សាក្សីបណ្តោះអាសន្ន និង ត្រូវផ្តល់មេធាវីមួយរូបទៅឲ្យសាក្សីនោះ លើកលែងតែសាក្សីបដិសេធនូវសិទ្ធិនេះ ។ ការបដិសេធនូវសិទ្ធិនេះត្រូវចុះក្នុងកំណត់ហេតុ ដូចមានចែងនៅក្នុងវិធាន ២៥។

## វិធាន ២៩: វិធានការការពារ

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ និង ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ និង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាអំពីកិច្ចការពារដល់អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដូចមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែមស្តីពីសន្តិសុខ និង សុវត្ថិភាព និងនៅក្នុងសេចក្តីណែនាំអនុវត្តដទៃទៀត។

២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះចេញបទបញ្ជាអ្វីមួយ ឬ នៅពេលការិយាល័យដទៃទៀតនៃអង្គជំនុំជម្រះវិសាមញ្ញបំពេញមុខងាររបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គ-ជំនុំជម្រះ ឬ ការិយាល័យនោះ ត្រូវគិតពិចារណាដល់សេចក្តីត្រូវការរបស់ជនរងគ្រោះ និង សាក្សី ។ ជាពិសេសនៅពេលណាដែលការិយាល័យទាំងនោះ ត្រូវធ្វើការទំនាក់ទំនងជាមួយ អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។ ការិយាល័យទាំងនោះ អាចធ្វើការទំនាក់ទំនងជាមួយមេធាវីរបស់ពួកគេ ឬ ជាមួយសមាគមរបស់ជនរងគ្រោះ នៅពេលដែលការទំនាក់ទំនងដោយផ្ទាល់ អាចបណ្តាលឲ្យបុគ្គលទាំងនេះមានគ្រោះថ្នាក់ដល់ជីវិត ឬ ដល់សុខមាលភាពរបស់ពួកគាត់ ។

៣. តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬ តាមពាក្យសុំ និងក្រោយពេលពិគ្រោះយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ ឬ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់វិធានការសមស្រប ដើម្បីការពារ អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលមកបង្ហាញខ្លួន ប្រសិនបើការបង្ហាញខ្លួននោះអាចធ្វើឲ្យអាយុជីវិត សុខមាលភាព ឬ ក្រុមគ្រួសារ ឬ ញាតិជិតស្និទ្ធរបស់ពួកគេ ត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចេញដីកាបែបនេះ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ក្នុងករណីដែលមានការបង្ហាញអំពីហានិភ័យបែបនេះនៅក្នុងសំណុំរឿង ។ វិធានការការពារសម្រាប់ ត្រូវស្នើសុំយ៉ាងយូរ ១៥ថ្ងៃ ក្រោយពីដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ។ នៅដំណាក់កាលជំនុំជម្រះ វិធានការការពារសម្រាប់សាក្សី ត្រូវស្នើសុំ យ៉ាងយូរត្រឹមថ្ងៃដាក់បញ្ជីឈ្មោះសាក្សី ដូចដែលមានចែងក្នុងវិធាន៨០។ ក្នុងករណីពិសេស អង្គជំនុំជម្រះអាចពិចារណាលើពាក្យសុំដែលដាក់យឺតបាន ។

៤. ក្នុងបរិបទនេះ សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះ អាចចេញសេចក្តីបង្គាប់ដោយមានសំអាងហេតុ ចាត់វិធានការដើម្បីការពារអត្តសញ្ញាណជនទាំងនោះ ដូចជា:

ក-កំណត់យកអាស័យដ្ឋានរបស់មេធាវីរបស់ពួកគេ ឬ របស់សមាគមនជនរងគ្រោះរបស់ពួកគេ ឬ របស់អង្គជំនុំជម្រះវិសាមញ្ញ ជាអាស័យដ្ឋានទំនាក់ទំនងរបស់ពួកគេ តាមករណីសមស្រប។

ខ-ប្រើរហស្សនាមនៅពេលនិយាយសំដៅទៅរកជនត្រូវការពារនោះ។

គ-អនុញ្ញាតឲ្យធ្វើកំណត់ហេតុសួរយកចម្លើយរបស់ជននោះដោយមិនចាំបាច់សរសេរអត្តសញ្ញាណរបស់ជននោះនៅក្នុងសំណុំរឿង ។

ឃ-នៅពេលណាជនត្រូវចោទ ឬ ជនសង្ស័យស្នើឲ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឲ្យមានការចូលរួមពីចម្ងាយ ឬ បំផ្លែងសម្លេងដើម ឬ បិទ

បាំងភិនភាគរបស់ជននោះ។

ង-ជាករណីលើកលែងចំពោះគោលការណ៍សវនាការជាសាធារណៈ អង្គជំនុំជម្រះអាចរៀបចំផ្នែកដំណើរការនីតិវិធីណាមួយជាសម្ងាត់ ឬ អនុញ្ញាតឲ្យបង្ហាញភស្តុតាងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬ ក៏ប្រើប្រាស់មធ្យោបាយពិសេសៗដទៃទៀត។

៥. ក្នុងករណីនេះពាក្យសុំ និងអត្តសញ្ញាណរបស់ជននេះ ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយឡែកពីសំណុំរឿង ។ បុគ្គលណាដែលទម្លាយប្រាប់ឲ្យដឹងអំពីអត្តសញ្ញាណ ឬ អាសយដ្ឋានរបស់បុគ្គលណាម្នាក់ដែលទទួលប្រយោជន៍ពីបទប្បញ្ញត្តិនៃវិធាននេះ អាចទទួលទណ្ឌកម្មតាមច្បាប់កម្ពុជាជាធរមាន។

៦. គ្មានការផ្តន្ទាទោសណាមួយ ដែលអាចធ្វើឡើងចំពោះជនជាប់ចោទ ដោយផ្អែកត្រឹមតែលើមូលដ្ឋាននៃការផ្តល់ចម្លើយ ស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវិធាន២៩ (៤) (គ)ខាងលើនេះប៉ុណ្ណោះបានទេ។

៧. ក្នុងករណីចាំបាច់ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបង្គាប់ឲ្យមានការធានាសមស្របតាមផ្លូវតុលាការ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ និង/ឬ ការការពារជារូបវ័ន្តដល់ជនរងគ្រោះ ឬ សាក្សី ដោយឲ្យស្ថិតនៅក្នុងលំនៅដ្ឋានសុវត្ថិភាព ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ នៅឯបរទេស។

៨. សេចក្តីសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងអនុវិធាន៤នៃវិធាននេះ ត្រូវបានបើកផ្លូវឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដូចដែលបានចែងក្នុងវិធាន៧៤ សេចក្តីសម្រេចដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបើកផ្លូវឲ្យប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូលដូចមានចែងក្នុងវិធាន ១០៤(៤)។

៩. បណ្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចទាក់ទងនឹងវិធានការការពារ ដែលមានចែងក្នុងវិធាននេះ មិនត្រូវមានអានុភាពព្យួរការអនុវត្តន៍ឡើយ លើកលែងតែបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដកហូតវិធានការនេះ។

## វិធាន ៣០: អ្នកបកប្រែ

ក្នុងករណីចាំបាច់ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះត្រូវប្រើប្រាស់អ្នកបកប្រែ។ សាក្សី ឬ ភាគីអាចស្នើសុំអ្នកបកប្រែបានផងដែរ នៅពេលចាំបាច់ ។ អ្នកបកប្រែទាំងអស់

ត្រូវស្បថ ស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងបកប្រែឲ្យបានទៀងត្រង់ រក្សាការសម្ងាត់ និង ខិតខំឲ្យអស់ពីសមត្ថភាពរបស់ខ្លួន។ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសចេញពីក្នុងចំណោមចៅក្រម សហព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ អ្នកស៊ើបអង្កេត ភាគី ឬ សាក្សីនៃអង្គជំនុំជម្រះវិសាមញ្ញឡើយ។

### វិធាន ៣១: អ្នកជំនាញ

**(វិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចស្វែងរកជំនួយជាមតិយោបល់ពីអ្នកជំនាញអំពីបញ្ហា ដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ដល់ការស៊ើបសួរ និង កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ។

២. អ្នកជំនាញដែលយល់ព្រមចំពោះការចាត់តាំង ត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថា នឹងផ្តល់ជំនួយ ដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព។

៣. អ្នកជំនាញត្រូវតែងតាំងដោយដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ ដីកានេះ ត្រូវមានចែងឲ្យច្បាស់អំពីភារកិច្ច និង ថេរវេលាបំពេញការងារ ។ ប្រសិនបើចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ អ្នកជំនាញ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវផ្តល់ផ្នែកណាមួយ ឬ ទាំងអស់នៃភស្តុតាងដែលមានក្នុង សំណុំរឿងទៅឲ្យអ្នកជំនាញ លើកលែងតែការផ្តល់ឲ្យនោះ នាំឲ្យមានគ្រោះថ្នាក់ដល់ជនរងគ្រោះ ឬ សាក្សី ឬ ផ្ទុយទៅនឹងវិធានការការពារដែលមានចែងក្នុងវិធាន ២៩ ។ ប៉ុន្តែនៅពេលណាទទួលបានការអនុញ្ញាតឲ្យពិនិត្យភស្តុតាង អ្នកជំនាញត្រូវបានអនុញ្ញាតឲ្យហែកស្លាកត្រាដែលបិទនៅលើភស្តុតាងប្រសិនបើមាន ។ ប្រសិនបើការធ្វើកោសល្យវិច័យរបស់អ្នកជំនាញ តម្រូវឲ្យមានការកែប្រែ ឬ ធ្វើឲ្យខូចខាតដល់ភស្តុតាង អ្នកជំនាញត្រូវជូនព័ត៌មាន ដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ និងត្រូវសុំការអនុញ្ញាតដើម្បីបំពេញកិច្ចការនេះ។

៤. អ្នកជំនាញត្រូវបំពេញបេសកកម្មរបស់ខ្លួន ក្រោមការឃ្លាំមើលរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ។ អ្នកជំនាញត្រូវជូនព័ត៌មានជាប្រចាំដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអំពីវឌ្ឍនភាព នៃបេសកកម្មរបស់ខ្លួន ជាពិសេសអំពីការលំបាកណាមួយដែលខ្លួនជួបប្រទះ។

៥. ប្រសិនបើអ្នកជំនាញមិនគោរពតាមរយៈពេល ដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គ-ជំនុំជម្រះ នោះសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់តាំងអ្នកជំនាញថ្មីមកជំនួសអ្នកជំនាញនោះ ឬ បើចាំបាច់ ពន្យាររយៈពេលបេសកកម្មរបស់អ្នកជំនាញនោះ។

៦. ប្រសិនបើជាការចាំបាច់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចចូលរួមស្តាប់ចម្លើយសាក្សី ឬ ជនត្រូវចោទ ឬ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសួរយកចម្លើយដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ ក្នុងករណីចាំបាច់ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យអ្នកជំនាញធ្វើសម្ភាសន៍ដោយផ្ទាល់ជាមួយសាក្សី ជនត្រូវចោទ ឬ ជនជាប់ចោទ នៅចំពោះមុខមេធាវីរបស់ពួកគេ។ ប៉ុន្តែក្នុងករណីដែលអ្នកជំនាញជាគ្រូពេទ្យ ដែលត្រូវចាត់តាំងឲ្យពិនិត្យជនត្រូវចោទ ឬ ជនជាប់ចោទ ការពិនិត្យផ្នែកវេជ្ជសាស្ត្រនេះអាចធ្វើបានដោយគ្មានវត្តមានមេធាវី។

៧. អ្នកជំនាញត្រូវធ្វើរបាយការណ៍ នៅពេលដែលប្រតិបត្តិការកោសល្យវិច័យត្រូវបានបញ្ចប់ ។ របាយការណ៍នេះ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីប្រតិបត្តិការ និង សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ដោយមានចុះកាលបរិច្ឆេទ និងហត្ថលេខាផងដែរ ។ ប្រសិនបើអ្នកជំនាញធ្វើឲ្យខូចស្លាកត្រាបិទ នៅលើភស្តុតាងក្នុងពេលធ្វើកោសល្យវិច័យ អ្នកជំនាញនោះ ត្រូវចុះនិទ្ទេសអំពីហេតុការណ៍នេះនៅក្នុងរបាយការណ៍។

៨. អ្នកជំនាញត្រូវប្រគល់របាយការណ៍ និង ប្រគល់ភស្តុតាងទាំងអស់ ដែលខ្លួនបានទទួលក្នុងពេលបំពេញ បេសកកម្មរបស់ខ្លួនទៅឲ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ។ សហចៅក្រម-ស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ត្រូវដាក់បញ្ចូលរបាយការណ៍នេះទៅក្នុងសំណុំរឿង ឬ កំណត់ហេតុនៃដំណើរការនីតិវិធី។ ប្រសិនបើស្លាកត្រាបិទ នៅលើភស្តុតាងត្រូវបានបំបែក សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវបិទស្លាកត្រាជាថ្មីលើវត្ថុតាងនោះ ហើយត្រូវចុះនិទ្ទេសអំពីបញ្ហានេះនៅក្នុងសំណុំរឿង។ ប្រសិនបើការធ្វើកោសល្យវិច័យរបស់អ្នកជំនាញធ្វើឲ្យមានការកែប្រែ ឬ ខូចខាតដល់វត្ថុតាង អ្នកជំនាញត្រូវពិពណ៌នាអំពីការកែប្រែ ឬ ខូចខាតនេះនៅក្នុងរបាយការណ៍។

៩. ប្រសិនបើកាលៈទេសៈតម្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់តាំងអ្នកជំនាញមួយចំនួនតាមការចាំបាច់ ឲ្យបំពេញបេសកកម្មធ្វើកោសល្យវិច័យ។ ក្នុងករណីនេះ ប្រសិនបើអ្នកជំនាញទាំងនោះមាន យោបល់ផ្សេងៗគ្នាចំពោះបេសកកម្មនោះ អ្នកជំនាញម្នាក់ៗត្រូវសរសេរអំពីគំនិតយោបល់ផ្ទាល់ខ្លួន នៅក្នុងរបាយការណ៍ដោយឡែករៀងៗខ្លួន ដោយបញ្ជាក់អំពីមូលហេតុនៃការខ្វែងគំនិតជាមួយ

អ្នកជំនាញដទៃទៀត។

១០. សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬ មេធាវីរបស់ពួកគេ ឬ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប ចាត់តាំងអ្នកជំនាញថ្មីបន្ថែមទៀត ដើម្បីធ្វើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលធ្វើរួចហើយ និងមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន។ សំណើនេះត្រូវធ្វើជាលាយល័ក្ខអក្សរ និង មានបញ្ជាក់មូលហេតុ ។ សំណើនេះត្រូវសម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន និង មុនពេលបញ្ចប់ការស៊ើបសួរ ឬ កិច្ចដំណើរការនីតិវិធី។ នៅពេលដែលសហចៅក្រមស៊ើបអង្កេត បដិសេធមិនព្រមធ្វើតាមសំណើ ដីកាបដិសេធនេះអាចត្រូវប្ដឹងឧទ្ធរណ៍ទៅ អង្គបុរេជំនុំជម្រះ។

១១. អង្គជំនុំជម្រះវិសាមញ្ញ ត្រូវផ្តល់សោហ៊ុយចំពោះការធ្វើកោសល្យវិច័យដល់អ្នកជំនាញ ដែលចាត់តាំងដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ទៅតាមអត្រាដែលរៀបចំឡើងដោយការិយាល័យរដ្ឋបាល។

### វិធាន ៣២: ការពិនិត្យផ្នែកវេជ្ជសាស្ត្រដល់ជនត្រូវចោទ ឬ ជនជាប់ចោទ

ក្នុងគោលបំណងដើម្បីបញ្ជាក់ថា ជនត្រូវចោទ ឬ ជនជាប់ចោទមានសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តអាចចូលរួមក្នុងការជម្រះក្តី ឬ ក៏ដោយសារមូលហេតុផ្សេងទៀត ឬ តាមសំណើរបស់ភាគីណាមួយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនត្រូវចោទ ឬ ជនជាប់ចោទទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រវិកលចរិក ចិត្តសាស្ត្រ ដោយអ្នកជំនាញ។ មូលហេតុនៃការចេញសេចក្តីបង្គាប់បែបនេះ និង របាយកាណ៍របស់អ្នកជំនាញ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

### វិធាន ៣២*ស្ទួន*: ការស្វែងរកមូលហេតុនៃមរណភាពនៅក្នុងអំឡុងពេលឃាត់ និង ឃុំខ្លួន

(អនុម័តថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១. នៅពេលដែលមានជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ ទទួលមរណភាពនៅក្នុង និងនៅក្រៅមន្ទីរឃុំឃាំង អ.វ.ត.ក រួមទាំងនៅក្នុងមន្ទីរពេទ្យ សហព្រះរាជអាជ្ញាត្រូវចាប់ផ្តើមធ្វើការស្វែងរកមូលហេតុនៃការស្លាប់នេះ ដោយបង្គាប់ឲ្យមានការធ្វើកោសល្យវិច័យលើសាកសពនោះ និងមានរបាយការណ៍ជាតិពុលបន្ថែមលើការសាកសួរនានារបស់សហព្រះរាជអាជ្ញា ដែលយល់ឃើញថាចាំបាច់សម្រាប់កំណត់

អំពីមូលហេតុនៃមរណភាពនោះ ។ នៅក្នុងករណីដែលរកឃើញថាមូលហេតុនៃការស្លាប់មិនមែនដោយមូលហេតុធម្មជាតិ សហព្រះរាជអាជ្ញាត្រូវផ្ទេរសំណុំរឿងនេះ ទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចនៅក្នុងប្រព័ន្ធតុលាការជាតិ ។

២. គ្រួសារសាកសពអាចជ្រើសរើសអ្នកជំនាញ អោយចូលសង្កេតការណ៍នៃការធ្វើកោសលវិច័យសាកសពនោះបាន ដោយចំណាយជាបន្ទុកផ្ទាល់ខ្លួន ។

## វិធាន ៣៣: សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី

១. នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យអង្គការ ឬ បុគ្គលណាមួយដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាឲ្យដាក់សារណានេះ ប្រសិនបើត្រូវធ្វើ។

២. សារណាដែលធ្វើឡើងក្រោមវិធាននេះ ត្រូវប្រគល់ទៅឲ្យក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធ។ ក្រឡាបញ្ជីត្រូវប្រគល់ឯកសារថតចម្លងមួយច្បាប់ទៅឲ្យសហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីដទៃទៀត ដើម្បីមានឱកាសធ្វើការឆ្លើយតប។

## វិធាន ៣៤: ការដកខ្លួន និង បណ្តឹងជំទាស់ចិត្តចំពោះចៅក្រម

**(វិសោធនកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១)**

១. ចៅក្រមអាចដកខ្លួនឯងចេញពីករណីណាមួយ ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលំអៀង។ សហចៅក្រមស៊ើបអង្កេតណាម្នាក់ដែលដកខ្លួនចេញពីការងារ ត្រូវផ្តល់ព័ត៌មានទៅដល់ប្រធានអង្គបុរេជំនុំជម្រះ។ បើជាចៅក្រមជម្រះក្តី ត្រូវផ្តល់ព័ត៌មានទៅដល់អង្គជំនុំជម្រះដែលខ្លួនស្ថិតនៅ។ ចៅក្រមដែលកំពុងមានបញ្ហាត្រូវឈប់ចូលរួមជាបន្ទាន់ ក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ។

២. ភាគីអាចធ្វើបណ្តឹងជំទាស់ចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់

មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលំអៀង។

៣. ភាគីដែលធ្វើបណ្តឹងជំទាស់ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និង ត្រូវមានភស្តុ-តាងបញ្ជាក់ផងដែរ ។ ពាក្យបណ្តឹងត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ។

៤. ពាក្យបណ្តឹងជំទាស់ដែលអាចទទួលយកបានត្រូវតែធ្វើឡើងដើម្បី ៖

ក-ប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេត មុនពេលមានដីកាដំណោះស្រាយ

ខ-ប្រឆាំងនឹងចៅក្រមរបស់អង្គបុរេជំនុំជម្រះ មុនពេលធ្វើសេចក្តីសម្រេចទៅលើរឿងក្តីណាមួយ

គ-ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះយ៉ាងយូរបំផុតត្រឹមពេលសវនាការបឋម ឬ ពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលជំនុំជម្រះ ឬ កាលណាភាគីមិនបានដឹង នៅមុនពេលជំនុំជម្រះ នៅមុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនោះ ឬ

ឃ-ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងមុនពេលធ្វើបណ្តឹងសាទុក្ខ នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ ឬ ពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលនីតិវិធីបណ្តឹងសាទុក្ខ ឬ បញ្ហាដែលភាគីមិនបានដឹងនៅមុនពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ មុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខនោះ។

៥. ពាក្យបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះ ។ ក្នុងករណីផ្សេងទៀត ពាក្យបណ្តឹងជំទាស់ត្រូវដាក់ជូនទៅអង្គជំនុំជម្រះណាមួយ ដែលចៅក្រមនោះស្ថិតនៅ ។ ចៅក្រមដែលកំពុងមានបញ្ហា អាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់ ។ ប៉ុន្តែចៅក្រមនោះ អាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន នៅគ្រប់ពេលវេលាក្នុងដំណើរការនីតិវិធី។

៦. ចៅក្រមពេញសិទ្ធិ អាចត្រូវជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះនោះបាន សម្រាប់តែករណីនៃបណ្តឹងជំទាស់នោះប៉ុណ្ណោះ ។ ប្រសិនបើមានពាក្យបណ្តឹងជំទាស់ច្រើន ដែលមិនអាចរៀបចំ

អង្គជំនុំជម្រះ ដើម្បីសម្រេចលើពាក្យបណ្តឹងទាំងនោះបានទេ គណៈកម្មាធិការរដ្ឋបាលតុលាការ ត្រូវជ្រើសរើសចៅក្រមបន្ថែមពីក្នុងចំណោមចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ។

៧. ចៅក្រមដែលត្រូវបានគេប្តឹងជំទាស់ប្រឆាំងនឹងខ្លួន មានសិទ្ធិដាក់សារណាទៅអង្គជំនុំជម្រះតាមរយៈប្រធានរបស់ខ្លួន ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ គិតចាប់ពីថ្ងៃដែលគាត់បានទទួលពាក្យបណ្តឹង ។ ពាក្យបណ្តឹងជំទាស់ ព្រមទាំងសារណារបស់ចៅក្រមដែលត្រូវគេប្តឹងជំទាស់ ត្រូវយកមកពិចារណាដោយអង្គ-ជំនុំជម្រះ ដែលត្រូវបោះឆ្នោត និង ធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបញ្ហានេះ ដោយពុំមានវត្តមានរបស់ចៅក្រម ដែលត្រូវបានគេប្តឹង និង ដើមបណ្តឹង។

៨. ក្នុងករណីចាំបាច់ ការពិភាក្សាសម្រេចលើបណ្តឹងជំទាស់ អាចធ្វើឡើងតាមមធ្យោបាយពីចម្ងាយ ។ សេចក្តីសម្រេចទាំងនេះត្រូវធ្វើតាមដីកាសម្រេច និងមិនអាចប្តឹងតវ៉ាបានឡើយ។ ដីកានេះត្រូវជូនដំណឹងទៅភាគី និង ចៅក្រមដែលត្រូវគេប្តឹងជំទាស់ដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ។

៩. កិច្ចដែលបានបំពេញដោយចៅក្រមដែលត្រូវគេប្តឹងជំទាស់ មុនពេលមានសេចក្តីសម្រេចលើពាក្យបណ្តឹងជំទាស់នោះត្រូវចាត់ទុកថាមានសុពលភាព ។

១០. ប្រសិនបើអង្គជំនុំជម្រះសម្រេចសេចក្តី ដកហូតសិទ្ធិពីចៅក្រមណាម្នាក់ ចៅក្រមបម្រុងនឹងត្រូវតែងតាំងជំនួសកន្លែងដែលទំនេរនោះ ។ កាលបើគ្មានចៅក្រមបម្រុងគ្រប់គ្រាន់ដើម្បីរៀបចំក្រុមប្រឹក្សាជំនុំជម្រះ ដោយហេតុថាមានបណ្តឹងជំទាស់ច្រើន ចៅក្រមថ្មីអាចត្រូវតែងតាំងបន្ថែមដូចមានចែងក្នុងមាត្រា ១០ ថ្មី និង ១១ ថ្មី នៃច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង មាត្រា ៣ នៃកិច្ចព្រមព្រៀង។ នៅពេលដែលពាក្យបណ្តឹងជំទាស់ ត្រូវបានបដិសេធចោលនោះ គ្មានពាក្យបណ្តឹងណាមួយផ្សេងទៀត អាចទទួលយកបាន-ដោយផ្អែកលើមូលហេតុដដែលដូចគ្នាទៅនឹងពាក្យបណ្តឹងមុននោះទេ លើកលែងតែមូលហេតុនោះបានកើតឡើងម្តងទៀត បន្ទាប់ពីមានសេចក្តីសម្រេចលើពាក្យបណ្តឹងលើកទី ១។

១១. ប្រសិនបើអង្គជំនុំជម្រះមិនអាចរកសម្លេងគាំទ្រ ភាគច្រើនតាមតម្រូវការបានទេ សេចក្តីសម្រេចនោះត្រូវចាត់ថាបានបដិសេធបណ្តឹងជំទាស់។

### វិធាន ៣៥: ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់

ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម:

ក-ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

ខ-ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្តីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្តី ឬ មិនផ្តល់ឯកសារ ឬ ភស្តុតាងផ្សេងទៀតឱ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

គ-បំផ្លាញ ឬ កែក្លែងតាមមធ្យោបាយណាក៏ដោយលើឯកសារ វត្ថុតាង ឬ ភស្តុតាងដទៃទៀតដែលស្ថិតក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ឃ-គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬ ផ្តល់សំណូក ឬ ក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬ លើ អ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្តល់ បានផ្តល់ ឬ អាចផ្តល់ភស្តុតាងដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

ង-គំរាមកំហែង បំភិតបំភ័យ ឬសូកសំណូក ឬ ស្វែងរកវិធីគាបសង្កត់លើបុគ្គលដទៃទៀតក្នុងបំណងទប់ស្កាត់បុគ្គលនោះមិនឱ្យអនុវត្តតាមដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

ច-ជួយដោយចេតនា ដើម្បីឱ្យជនត្រូវចោទ ឬ ជនជាប់ចោទរត់គេចពីអំណាចយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ឬ

ឆ-ញុះញង់ ឬ ប៉ុនប៉ងប្រព្រឹត្តិអំពើណាមួយដូចមានចែងខាងលើ។

២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់ បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច ៖

ក-ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។

ខ-ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ។ឬ

គ-បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច របស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហប្រជាជាតិ។

៣.	ជនទាំងឡាយណាដែលពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាននេះត្រូវទទួលបានជំនួយផ្នែកច្បាប់ ប្រសិនបើគាត់បំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងនៅក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តីដែលមានចែងនៅក្នុងវិធាន ១១។

៤.	ច្បាប់កម្ពុជាជាធរមានត្រូវអនុវត្តចំពោះករណីទណ្ឌកម្មនីមួយៗ លើបុគ្គលណាម្នាក់ ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើណាមួយ ដូចមានចែងក្នុងអនុវិធាន ១។

៥.	ប្រសិនបើរកឃើញថា មេធាវីណាម្នាក់បានប្រព្រឹត្តអំពើណាមួយដូចមានចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលរកឃើញកំហុសនោះ អាចកំណត់ថាការប្រព្រឹត្តអំពើនេះគឺជាកំហុសវិជ្ជាជីវៈរបស់មេធាវី ដូចមានចែងក្នុងវិធាន ៣៨។

៦.	រាល់សេចក្តីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬ ប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល តាមករណីសមស្រប។ចំពោះបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងចំពោះមុខអង្គបុរេជំនុំជម្រះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវដាក់ពាក្យប្តឹង ឧទ្ធរណ៍ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច ឬការជូនដំណឹងអំពីសេចក្តីសម្រេចនោះ តាមករណីសមស្រប។ ចំពោះបណ្តឹងសាទុក្ខដែលធ្វើឡើងចំពោះមុខអង្គជំនុំជ្រះតុលាការកំពូល ម្ចាស់បណ្តឹងសាទុក្ខត្រូវធ្វើឡើងដោយអនុលោមទៅតាមនីតិវិធី និងរយៈពេលកំណត់ដូចមានចែងក្នុង វិធាន ១០៥ អនុវិធាន ២ និងវិធាន ១០៧ អនុវិធាន ១។

### វិធាន ៣៦: សក្ខីភាពក្លែងក្លាយ

១.	តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬ តាមសំណើរបស់ភាគី សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាចរំលឹកដល់សាក្សីអំពីភារកិច្ចរបស់ពួកគេឲ្យឆ្លើយការពិត និងផលវិបាកដែលកើតចេញពីការខកខានមិនបានអនុវត្តភារកិច្ចនេះ។

២.	ប្រសិនបើសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះមានមូលដ្ឋានច្បាស់លាស់ជឿថា សាក្សីណាមួយមានចេតនាពិតប្រាកដក្នុងការធ្វើសក្ខីភាពក្លែងក្លាយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចអនុវត្តតាមនីតិវិធីជាធរមាន ដែលមានចែងក្នុងវិធាន ៣៥(២) ខាងលើ។

៣.	ច្បាប់កម្ពុជាជាធរមានត្រូវអនុវត្តចំពោះករណីទណ្ឌកម្មនីមួយៗលើការធ្វើសក្ខីភាពក្លែងក្លាយ។

## វិធាន ៣៧: ការរំខានក្នុងកិច្ចដំណើរការនីតិវិធី

១. នៅពេលណាដែលអង្គជំនុំជម្រះយល់ឃើញថា ជនណាម្នាក់អុកឡុករំខានដល់កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះជាដំបូងត្រូវចេញសេចក្តីព្រមានមួយ។ ក្នុងករណីមានការបន្តការរំខានទៀត អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនដែលរំខាននោះចាកចេញ ឬ បណ្តេញចេញពីបន្ទប់សវនាការ ឬ អគាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយក្នុងករណីនៅតែប្រព្រឹត្តកំហុសធ្ងន់ទៀត អាចបង្គាប់មិនឲ្យជននោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់។

២. ប្រសិនបើជនជាប់ចោទរំខានដល់កិច្ចដំណើរការនីតិវិធីនៅចំពោះអង្គជំនុំជម្រះ អង្គជំនុំជម្រះអាចបង្គាប់ឲ្យនាំជនជាប់ចោទចេញពីបន្ទប់សវនាការទៅកន្លែងណាមួយ ដែលជននោះអាចសង្កេតមើលដំណើរការសវនាការបានតាមរយៈទូរទស្សន៍តាមដែលអាចធ្វើទៅបាន ។ ក្នុងករណីនេះ ជនជាប់ចោទអាចទាក់ទងជាមួយមេធាវីរបស់ខ្លួនបានគ្រប់ពេលវេលាតាមរយៈទូរស័ព្ទ ។ អង្គជំនុំជម្រះអាចបង្គាប់ឲ្យផ្អាកការផ្សាយដល់សាធារណៈជន អំពីកិច្ចដំណើរការសវនាការ និងអាចចាត់វិធានការដទៃទៀតដែលយល់ឃើញថាចាំបាច់ដល់កិច្ចដំណើរការនីតិវិធីជម្រះក្តី ប្រកបដោយភាពត្រឹមត្រូវ និងឆាប់រហ័ស។

៣. ប្រសិនបើការអាក់ខានសវនាការ កើតឡើងដោយការបដិសេធដោយចេតនាគិតទុកជាមុនមិនធ្វើតាមការណែនាំដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះ ហើយការណែនាំនោះមានអមដោយការព្រមានដាក់ទណ្ឌកម្មក្នុងករណីកំហុសធ្ងន់ អង្គជំនុំជម្រះដែលប្រឈមមុខនឹងបញ្ហានេះអាចបង្គាប់ហាមឃាត់ មិនឲ្យជននោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតែក្នុងអំឡុងពេលនោះ បើយល់ឃើញថាសមស្រប។ ប្រសិនបើការរំខាននេះមានលក្ខណៈធ្ងន់ធ្ងរ អង្គជំនុំជម្រះអាចចាត់វិធានការសមស្រប ដូចមានចែងក្នុងអនុវិធាន ៥ នៃវិធាន នេះ។

៤. ប្រសិនបើជនដែលធ្វើឲ្យអាក់ខានដល់កិច្ចដំណើរការនីតិវិធីនេះ ជាបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះអង្គជំនុំជម្រះដែលប្រឈមមុខនឹងបញ្ហានេះ អាចបង្គាប់បណ្តេញជននោះចេញពីការបំពេញមុខងាររបស់ខ្លួន សម្រាប់តែរយៈពេលណាមួយដែលយល់ឃើញថាសមស្រប ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងជាបន្ទាន់ដល់ប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល។

៥. ច្បាប់កម្ពុជាជាធរមាន ត្រូវអនុវត្តចំពោះករណីទណ្ឌកម្មនីមួយៗលើការរំខានដល់កិច្ចដំណើរការនីតិវិធី។

៦.	បុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវបានផ្តល់ឱកាសឲ្យបញ្ចេញយោបល់មុនពេលប្រកាសដាក់ទណ្ឌកម្មមកលើខ្លួន។

### វិធាន ៣៨: កំហុសវិជ្ជាជីវៈរបស់មេធាវី

១.	សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬ បដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬ ផ្ទុយទៅនឹងមាត្រា ២១-៣ នៃកិច្ចព្រមព្រៀង។

២.	សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។

៣.	មេធាវីបរទេសដែលបំពេញវិជ្ជាជីវៈនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវទទួលរងការដាក់វិន័យ ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់គណៈមេធាវី ។បណ្តឹងឧទ្ធរណ៍នេះត្រូវព្យួរការអនុវត្តសេចក្តីសម្រេច លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចផ្សេង។សេចក្តីសម្រេចរបស់អង្គ-បុរេជំនុំជម្រះបិទផ្លូវប្តឹងតវ៉ា។

៤.	នៅពេលដែលទទួលបានលទ្ធផលនៃការដាក់វិន័យនេះ មេធាវីដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវី ដើម្បីការពារក្តីនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ ត្រូវប្រគល់សម្ភារៈទាក់ទងទៅនឹងរឿងក្តីទាំងអស់ទៅអង្គភាពពាក់ព័ន្ធនៃការិយាល័យរដ្ឋបាល ដើម្បីធានាដល់និរន្តភាពក្នុងការការពារក្តី។

### វិធាន ៣៩: ពេលវេលាកំណត់ និងលក្ខខណ្ឌក្នុងការដាក់ឯកសារ

(វិសោធនកម្ម ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩)

១.	គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងក្នុងច្បាប់ជាធរមាន វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង សេចក្តីសម្រេចរបស់ចៅក្រម តាមករណីសមស្របណាមួយត្រូវតែគោរព ។ ក្នុងករណីនេះ ការមិនបានគោរពតាមកាលកំណត់ គឺនាំឲ្យកិច្ចដែលបានធ្វើនោះត្រូវចាត់ទុកជាអសុពលភាព។

២. លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង និង ស្របតាមសេចក្តីណែនាំអនុវត្ត ចៅក្រម អាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬ បណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនោះ ជាពិសេសក្នុងករណីដែលជនត្រូវចោទ ឬ ជនជាប់ចោទ ស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន។

៣. គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ ត្រូវផុតកំណត់នៅថ្ងៃចុងក្រោយវេលាម៉ោង ២៤:០០ នៅកម្ពុជាលើកលែងតែមានចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ ។ កាលបើពេលវេលាកំណត់ត្រូវផុតរលត់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យជាតិរបស់កម្ពុជា ពេលវេលាកំណត់ត្រូវបន្តជាស្វ័យប្រវត្តិទៅថ្ងៃធ្វើការបន្ទាប់។

៤. តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចៈ

ក-ពន្យាពេលវេលាកំណត់ ដែលខ្លួនបានកំណត់ ។

ខ-ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល។

៥. ចំពោះការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ឬ រវាងសហព្រះរាជអាជ្ញាដែលត្រូវបានដាក់ចូលក្នុងកំណត់ហេតុ ដូចមានក្នុងវិធាន ៧១ ឬ ៧២ នោះការអនុវត្តចំពោះពេលវេលាកំណត់ ត្រូវពន្យាពេលរហូតដល់មានការព្រមព្រៀងណាមួយត្រូវបានសម្រេចឡើង ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ត្រូវបានផុតរលត់ ឬ អង្គបុរេជំនុំជម្រះបានទទួលយកករណីនៃការខ្វែងយោបល់គ្នានោះមកជំនុំជម្រះ ហើយបានបញ្ចប់ការពិចារណា ដោះស្រាយលើបញ្ហានេះ។

៦. ឯកសារទាំងអស់ដូចជាពាក្យបណ្តឹង សំណើ និង ពាក្យសុំដែលដាក់មកអង្គជំនុំជម្រះវិសាមញ្ញ ត្រូវដាក់ជូនទៅក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គ-ជំនុំជម្រះ ទៅតាមករណីនីមួយៗ ស្របតាមច្បាប់កម្ពុជាជាធរមាន វិធានផ្ទៃក្នុងនេះ សេចក្តីណែនាំអនុវត្ត

និង សេចក្តីសម្រេចរបស់ចៅក្រម តាមករណីសមស្រប។

### វិធាន ៤០: ការចុះហត្ថលេខា

គ្រប់ករណីទាំងអស់ដែលតម្រូវឲ្យមានការចុះហត្ថលេខា ស្របតាមវិធានផ្ទៃក្នុងនេះការចុះហត្ថលេខាអាចត្រូវបានជំនួសដោយការផ្តិតម្រាមដៃវិញ ក្នុងករណីដែលបុគ្គលនោះ មិនអាចចុះហត្ថលេខាបាន។

### វិធាន ៤១: ដីកាកោះ

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. ដីកាកោះគឺជាការបង្គាប់ដល់បុគ្គលណាម្នាក់ ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដីកានេះអាចអនុវត្តចំពោះជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ហើយត្រូវមានចុះនិទ្ទេសរបស់បុគ្គល ដែលត្រូវកោះហៅនោះផង។

២. លើកលែងតែករណីដែលមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង រយៈពេលអប្បរមារវាងការប្រគល់ដីកានេះ និងថ្ងៃកំណត់ឲ្យចូលមកបង្ហាញខ្លួននៅចំពោះអង្គជំនុំជម្រះវិសាមញ្ញត្រូវមានរយៈពេល ៥ (ប្រាំ)ថ្ងៃ ។ ប៉ុន្តែនៅពេលដែលដីកានេះធ្វើឡើងសម្រាប់ជនជាប់ឃុំនោះ ឬ នៅពេលដែលអ្នកស៊ើបអង្កេត ឬ សហចៅក្រមស៊ើបអង្កេត ស្តាប់ចម្លើយសាក្សីដោយចុះទៅដល់ទីកន្លែង ឬ ក្នុងកាលៈទេសៈពិសេស ពេលវេលាកំណត់នេះមិនត្រូវអនុវត្តឡើយ។

៣. ដីកាកោះទាំងអស់ ត្រូវបញ្ជូនតាមអាស័យដ្ឋានចុងក្រោយបង្អស់ដោយក្រឡាបញ្ជី នគរបាលយុត្តិធម៌ ឬ មន្ត្រីដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះវិសាមញ្ញ តាមមធ្យោបាយណាមួយសមស្រប ។ ជនជាប់ឃុំត្រូវបានកោះហៅតាមរយៈប្រធានមន្ទីរឃុំឃាំង ។ ការបញ្ជូនដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវសរសេរចូលក្នុងរបាយការណ៍ដោយបញ្ជាក់អំពីមធ្យោបាយបង្គាប់ឲ្យចូលខ្លួន កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែង រួមទាំងកាលៈទេសៈ ពាក់ព័ន្ធដទៃទៀត ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីដែលបំពេញកិច្ចការនោះ និង ដាក់ចូលក្នុងសំណុំរឿង។

៤. បុគ្គលដែលទទួលភារៈជាអ្នកប្រគល់ដីកាទៅឲ្យជនណាម្នាក់ ត្រូវអនុវត្តទៅតាមភារកិច្ចរបស់ខ្លួន និងខិតខំឲ្យអស់ពីលទ្ធភាពដើម្បីប្រគល់ដីកា និង ទទួលបានមកវិញនូវសេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកា ។ សេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកានេះ ត្រូវដាក់ភ្ជាប់ទៅនឹងរបាយការណ៍នៃការ

បំពេញកិច្ចការ។

៥. ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានកោះហៅតាមរយៈសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**វិធាន ៤២: ដីកាបង្គាប់ឲ្យនាំខ្លួន**

ដីកាបង្គាប់ឲ្យនាំខ្លួនអាចធ្វើឡើងចំពោះជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ ទោះបីជាជននោះនៅក្នុង ឬ ក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។ ប្រសិនបើចាំបាច់ ដីកានេះអាចធ្វើឡើងជាលក្ខណៈអន្តរជាតិ ដោយមានយន្តការគាំទ្រមួយដ៏មានប្រសិទ្ធភាព។

**វិធាន ៤៣: ដីកាបង្គាប់ឲ្យឃុំខ្លួន**

សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាចចេញដីកាបង្គាប់ឲ្យឃុំខ្លួន បញ្ជាដល់ប្រធានមន្ទីរឃុំឃាំង របស់អង្គជំនុំជម្រះវិសាមញ្ញបាន នៅពេលដែលមានដីកាសម្រេច ឬ សេចក្ដីសម្រេចឃុំខ្លួនបណ្ដោះអាសន្នមួយត្រូវ បានធ្វើឡើងចំពោះបុគ្គលដដែលនោះរួចហើយ។

**វិធាន ៤៤: ដីកាបង្គាប់ឲ្យចាប់ខ្លួន**

១. ដីកាបង្គាប់ឲ្យចាប់ខ្លួន អាចធ្វើឡើងចំពោះជនត្រូវចោទ ឬជនជាប់ចោទដែលបានគេចខ្លួន មិនដឹងជាស្ថិតនៅកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើចាំបាច់ ដីកានេះអាចធ្វើឡើងជាលក្ខណៈអន្តរជាតិ ដោយមានយន្តការគាំទ្រមួយដ៏មានប្រសិទ្ធភាព។ សហព្រះរាជអាជ្ញា ត្រូវទទួលបន្ទុកផ្សព្វផ្សាយ ដីកាបង្គាប់ឲ្យចាប់ខ្លួន។

២. មុនពេលចេញដីកាបង្គាប់ឲ្យចាប់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវសួរយោបល់ពីសហព្រះរាជអាជ្ញា។ ដីកានេះត្រូវមានសំអាងហេតុ។

**វិធាន ៤៥: ទម្រង់ការពាក់ព័ន្ធនឹងដីកាកោះ ដីកាបង្គាប់ឲ្យឃុំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន**

១. រាល់ដីកាកោះ ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវមានចុះកាលបរិច្ឆេទ ហត្ថលេខា និងប្រថាប់ត្រាដោយអង្គភាពចេញដីកានោះ និង ត្រូវមានព័ត៌មានដូចខាងក្រោម:

ក-ឈ្មោះ និង ប្រសិនបើដឹង ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើត អាសយដ្ឋាន និង ព័ត៌មានដទៃទៀតដែល ពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គលនោះ

ខ-យោងតាមដីកា និង ការចោទប្រកាន់ដែលពាក់ព័ន្ធ

គ-អង្គភាពរបស់អង្គជំនុំជម្រះវិសាមញ្ញដែលចេញដីកា

ឃ-ទីកន្លែង ពេលវេលា និងកាលបរិច្ឆេទសវនាការ តាមករណីសមស្របនីមួយៗ និង

ង-បញ្ជាក់ថា បុគ្គលនោះមានសិទ្ធិទទួលបាននូវជំនួយផ្នែកច្បាប់ និង សិទ្ធិត្រូវបានការពារដទៃទៀត ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

២. រាល់ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួននិង ដីកាបង្គាប់ឱ្យចាប់ខ្លួនទាំងអស់ ត្រូវអនុវត្តដោយនគរបាលយុត្តិធម៌។ ដីកាដើមត្រូវប្រគល់ឱ្យភ្លាមដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានភារកិច្ចត្រូវទទួលអនុវត្តដីកានេះ។ ក្នុងករណីបន្ទាន់ ត្រូវជូនដំណឹងអំពីដីកានេះទៅដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ហើយដីកាដើមត្រូវប្រគល់ឱ្យនគរបាលយុត្តិធម៌ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង។

៣. មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលក្នុងលំនៅដ្ឋានរបស់បុគ្គលនោះបានទេ មុនពេលម៉ោង ៦:០០ នាទីព្រឹក ឬក្រោយម៉ោង ១៨:០០ នាទី ល្ងាច។ នគរបាលយុត្តិធម៌ ត្រូវផ្តល់ព័ត៌មានដល់សហចៅក្រម-ស៊ើបអង្កេត ឬ អង្គជំនុំជម្រះអំពីបញ្ហាលំបាក ដែលខ្លួនជួបប្រទះក្នុងការបំពេញមុខងាររបស់ខ្លួន។

៤. ដោយយោងទៅតាមកាលៈទេសៈ នៅពេលដែលចាប់ជននោះបានហើយ តែមិនអាចនាំខ្លួនបានភ្លាមៗមក កាន់អង្គភាពដែលចេញដីកា ដីកាបង្គាប់ឱ្យចាប់ខ្លួននេះមានអានុភាពបង្គាប់ដល់មន្ទីរឃុំឃាំង ឬមណ្ឌលឃុំខ្លួនឱ្យដាក់ ជននោះក្នុងមន្ទីរឃុំឃាំងសិន ហើយត្រូវនាំជននោះភ្លាមតាម ដែលអាចទៅបានមកចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ ក្នុងករណីនេះ ត្រូវអនុវត្តវិធាន៥១ ដោយចាត់ទុកថានីតិវិធីអនុវត្តចំពោះ សហព្រះរាជអាជ្ញាដូចមានចែងក្នុងវិធានខាងដើមនេះ ត្រូវអនុវត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នជននោះ ដូចមានចែងក្នុងវិធាន ៦៣។

៥. នៅពេលដែលជនណាម្នាក់ត្រូវបានចាប់ខ្លួន ដោយដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវជាប់ពន្ធនាគាររយៈពេលនៃការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារត្រូវគិតបញ្ចូលផងដែរ នូវរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន។

៦. ប្រធានមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវរក្សាទុកនូវរាល់ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ ឱ្យចាប់ខ្លួនទាំងអស់មួយច្បាប់ដែលជាច្បាប់ថតចម្លង ដោយមានសេចក្តីបញ្ជាក់។

**វិធាន ៤៦: ការជូនដំណឹងអំពីដីកា**

១. រាល់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវជូនដំណឹងដល់ភាគី និង ឬ មេធាវីរបស់ ភាគីដោយផ្ទាល់មាត់ ឬ ផ្ញើទៅអាសយដ្ឋានចុងក្រោយរបស់គេ បើអាចដឹងដោយក្រឡាបញ្ជី នគរបាលយុត្តិធម៌ ឬ មន្ត្រីទទួលការចាត់តាំង ដោយអង្គជំនុំជម្រះវិសាមញ្ញ តាមមធ្យោបាយសមស្រប។ ជនដែលជាប់ឃុំ ត្រូវជូនដំណឹងដោយផ្ទាល់មាត់ ឬ តាមរយៈប្រធានមន្ទីរឃុំឃាំង។

២. កាលណាការជូនដំណឹងធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រាទុកអំពីកាលបរិច្ឆេទនៅលើ រឹមទំព័រនៃដីកា ហើយបុគ្គលដែលត្រូវទទួលដំណឹងនេះត្រូវចុះហត្ថលេខាលើដីកា ។ ក្នុងករណីផ្សេងពីនេះ ការជូនដំណឹងត្រូវធ្វើឡើងដោយមានការកត់ត្រា នៅក្នុងរបាយកាណ៍ជាលាយល័ក្ខអក្សរ ដោយបញ្ជាក់អំពី មធ្យោបាយ ដែលបានប្រើក្នុងការជូនដំណឹងនេះ ពេលវេលា ថ្ងៃខែឆ្នាំ ទីកន្លែង និង កាលៈទេសៈដទៃទៀត។ របាយការណ៍នេះ ត្រូវចុះហត្ថលេខាដោយមន្ត្រីបំពេញកិច្ចការនេះ និង ត្រូវដាក់ចូលទៅក្នុងសំណុំរឿង។

៣. បុគ្គលដែលទទួលភារៈជាអ្នកប្រគល់ដីកាត្រូវអនុវត្តទៅតាមភារកិច្ចរបស់ខ្លួន និង ខិតខំឱ្យអស់ពី លទ្ធភាព ដើម្បីប្រគល់ដីកា និង ទទួលបានមកវិញនូវសេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកា ។ សេចក្តីបញ្ជាក់ទទួល ស្គាល់ថាបានទទួលដីកានេះ ត្រូវដាក់ភ្ជាប់ទៅនឹងរបាយការណ៍នៃការបំពេញកិច្ចការ។

៤. ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាន ជូនដំណឹងបន្ថែមពីដីកាផ្សេងៗ។

**វិធាន ៤៧: ទម្រង់ការនៃការជូនដំណឹងអំពីដីកា**

ការជូនដំណឹងអំពីដីកាត្រូវមានព័ត៌មានយ៉ាងតិចបំផុត ដូចខាងក្រោម:

ក-ឈ្មោះ ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត និងអាស័យដ្ឋានរបស់បុគ្គលដែលត្រូវជូនដំណឹងនោះ

ខ-យោងទៅលើដីកាពាក់ព័ន្ធ និង

គ-អង្គភាពរបស់អង្គជំនុំជម្រះវិសាមញ្ញដែលចេញដីកា។

**វិធាន ៤៨: មោឃភាពចំពោះការមិនគោរពវិធានបញ្ញត្តិ**

កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។

**<u>ខ-ការចោទប្រកាន់</u>**

**វិធាន ៤៩: ការអនុវត្តបណ្តឹងអាជ្ញា**

១. ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយណា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ អាចធ្វើឡើងបានតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសម្រេចចិត្តដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹងក៏ដោយ។

២. សហព្រះរាជអាជ្ញាត្រូវទទួល និង ពិចារណាលើរាល់ពាក្យបណ្តឹងជាលាយល័ក្ខអក្សរ ឬព័ត៌មានទាំងឡាយណា ដែលចោទប្រកាន់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ពាក្យបណ្តឹង ឬព័ត៌មានទាំងនេះ អាចត្រូវបានប្តឹងទៅសហព្រះរាជអាជ្ញា ដោយបុគ្គលណាម្នាក់ អង្គការ ឬ តាមប្រភពផ្សេងទៀត ជាជនដែលបានដឹងឮ ឬ ជាជនរងគ្រោះនៃបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ឬ ជាជនដែលបានដឹងអំពីបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់នោះ ។

៣. ពាក្យបណ្តឹងដែលមានចែងក្នុងវិធាននេះអាចត្រូវរៀបចំធ្វើ និង/ឬ ប្តឹងក្នុងនាមជនរងគ្រោះ ដោយមេធាវី ឬ សមាគមជនរងគ្រោះ ។ ឯកសារចម្លងនៃពាក្យបណ្តឹងទាំងនេះ ត្រូវរក្សាទុកក្នុងការិយាល័យរដ្ឋបាល និង អាចបកប្រែជាភាសាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ តាមតម្រូវការ។

៤. ពាក្យបណ្តឹងទាំងនេះមិនអាចជាប្រភពផ្តើមធ្វើការចោទប្រកាន់ ជាស្វ័យប្រវត្តិអំពីបទឧក្រិដ្ឋបានទេ ហើយសហព្រះរាជអាជ្ញាត្រូវធ្វើការសម្រេចដោយឆន្ទានុសិទ្ធិ ថាតើត្រូវតម្កល់បណ្តឹងទុកឥតចាត់ការ ឬ បញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេតបឋមកំពុងដំណើរការ ឬ បើកការស៊ើបអង្កេតបឋមថ្មី ឬ បញ្ជូនពាក្យបណ្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញា ត្រូវជូនដំណឹងអំពីការសម្រេចដល់អ្នកប្តឹងជាបន្ទាន់ តាមដែលអាចធ្វើទៅបាន និង ក្នុងគ្រប់ករណីទាំងអស់ មិនត្រូវលើសពីរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃចុះពាក្យបណ្តឹង។

៥. សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់សហព្រះរាជអាជ្ញា មិនមានអានុភាពអាជ្ញាអស់ជំនុំ

ទេ ។ សហព្រះរាជអាជ្ញា អាចកែប្រែការសម្រេចចិត្តរបស់ខ្លួនគ្រប់ពេលបាន ក្នុងករណីនេះត្រូវជូនដំណឹងដល់អ្នកប្តឹងពី សេចក្តីសម្រេចនេះឲ្យបានឆាប់តាមដែលអាចធ្វើបាន និង ក្នុងគ្រប់ករណីទាំងអស់ មិនត្រូវលើសរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច។

**វិធាន ៥០: ការស៊ើបអង្កេតបឋម**

១. សហព្រះរាជអាជ្ញា អាចដឹកនាំការស៊ើបអង្កេតបឋម ដើម្បីកំណត់ភស្តុតាង ដែលបង្ហាញអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ និង កំណត់អត្តសញ្ញាណជនសង្ស័យ និង សាក្សីសំខាន់ ៗ។

២. ការស៊ើបអង្កេតបឋម អាចអនុវត្តបានដោយនគរបាលយុត្តិធម៌ ឬ ដោយអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ តាមសំណើរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ អ្នកស៊ើបអង្កេតទាំងនោះអាចធ្វើការឆែកឆេរ និងប្រមូលភស្តុតាងពាក់ព័ន្ធ រួមទាំងឯកសារ។ ការឆែកឆេរនេះមិនអាចផ្តើមធ្វើមុនម៉ោង ០៦ៈ០០ព្រឹក និងក្រោយម៉ោង ១៨ៈ០០ល្ងាច និង បន្ទាប់ពីបានទទួលការបង្គាប់ជាលាយលក្ខណ៍អក្សរពី សហព្រះរាជអាជ្ញា និង ការយល់ព្រមពីម្ចាស់ ឬ អ្នកកាន់កាប់ទីតាំងនោះ។ ការយល់ព្រមនេះ ត្រូវសរសេរដោយដៃ ឬ ប្រសិនបើម្ចាស់ ឬអ្នកកាន់កាប់លំនៅដ្ឋាននោះមិនអាចសរសេរអក្សរបាន នោះមន្ត្រីនគរបាលយុត្តិធម៌ ឬ អ្នកស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុអំពីហេតុការណ៍នេះនៅក្នុងរបាយការណ៍របស់ខ្លួន។

៣. ប្រសិនបើម្ចាស់ ឬ អ្នកកាន់កាប់ទីកន្លែងនោះអវត្តមាន ឬ បដិសេធមិនឲ្យចូល សហព្រះរាជអាជ្ញាអាចស្នើទៅប្រធានអង្គបុរេជំនុំជម្រះដើម្បីសុំការអនុញ្ញាតដឹកនាំធ្វើការឆែកឆេរ។ សេចក្តីសម្រេចដែលមានសំអាងហេតុរបស់ប្រធាន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដាក់បញ្ចូលទៅក្នុងសំណុំរឿង។ក្នុងករណីបន្ទាន់ និងពិតជាមិនអាចមានលទ្ធភាពផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ប្រធានអង្គបុរេជំនុំជម្រះអាចផ្តល់ការអនុញ្ញាតដោយផ្ទាល់មាត់បាន ប៉ុន្តែត្រូវធ្វើជាលាយលក្ខណ៍អក្សរវិញក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ។ ការឆែកឆេរ ត្រូវធ្វើឡើងនៅចំពោះមុខម្ចាស់កម្មសិទ្ធិ ឬ អ្នកកាន់កាប់ទីកន្លែង ប្រសិនបើគ្មានម្ចាស់ ឬ អ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលជ្រើសរើសដោយសហព្រះរាជអាជ្ញា។ សាក្សីទាំងនោះ មិនត្រូវជាអ្នកស៊ើបអង្កេត ឬជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចូលរួមក្នុងកិច្ចប្រតិបត្តិការឆែកឆេរនោះបានឡើយ។

៤.	តាមសំណើរបស់សហព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ ឬ អ្នកស៊ើបអង្កេតអាចកោះ និង សួរយកចម្លើយជនណាម្នាក់ ដែលអាចផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងករណីកំពុងស៊ើបអង្កេតបឋម។

៥.	សហព្រះរាជអាជ្ញាត្រូវធ្វើបញ្ជីសារពើភ័ណ្ឌលើសម្ភារៈទាំងអស់ ដែលបានចាប់យកក្នុងពេលស៊ើប-អង្កេតបឋមដូចជាឯកសារ សៀវភៅ ក្រដាស និងវត្ថុតាងដទៃទៀត ហើយត្រូវប្រគល់បញ្ជីថតចម្លងមួយច្បាប់ទៅឲ្យបុគ្គលដែលត្រូវបានគេចាប់យកសម្ភារៈទាំងអស់នោះ ។ សម្ភារៈទាំងឡាយណាដែលមិនមានតម្លៃជាភស្តុតាងត្រូវ ប្រគល់ទៅឲ្យម្ចាស់ដើមវិញដោយគ្មានពន្យាពេល ក្រោយពេលបញ្ចប់ការស៊ើបអង្កេតបឋម។

**វិធាន ៥១: ការឃាត់ខ្លួន**

១.	ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការអង្កេត សហព្រះរាជអាជ្ញាអាចបង្គាប់ឲ្យនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ ដែលសង្ស័យថាបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងឋានៈជាចារី ឬ អ្នកសមគំនិត ។ បុគ្គលនោះ ត្រូវតែបានប្រាប់ពីហេតុផលនៃការឃាត់ខ្លួន និងសិទ្ធិទាំងឡាយរបស់បុគ្គលនោះ ដូចមានចែងក្នុងវិធាន ២១-១(ឃ) ។ បុគ្គលនោះ ត្រូវឃាត់ខ្លួនទុកនៅមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ តាមដែលអាចធ្វើទៅបាន។

២.	ដីកាឃាត់ខ្លួន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ចុះហត្ថលេខាដោយសហព្រះរាជអាជ្ញា និងប្រគល់ទៅឲ្យជនសង្ស័យទៅតាមពេលវេលាសមស្រប ។ ក្នុងស្ថានភាពបន្ទាន់ដែលមិនអាចសរសេរជាលាយលក្ខណ៍អក្សរបាន សហព្រះរាជអាជ្ញាអាចចេញដីកានេះដោយផ្ទាល់មាត់ ប៉ុន្តែត្រូវសរសេរតាមក្រោយឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន។

៣.	ការឃាត់ខ្លួនអាចធ្វើឡើងតាមបង្គាប់របស់សហព្រះរាជអាជ្ញា សម្រាប់រយៈពេលមិនលើសពី៤៨ (សែសិបប្រាំបី)ម៉ោង គិតចាប់ពីពេលឃាត់ខ្លួនជនសង្ស័យ។ នៅផុតបញ្ចប់រយៈពេលនេះ សហព្រះរាជអាជ្ញាអាចពន្យាពេលការឃាត់ខ្លួនបាន ២៤(ម្ភៃបួន) ម៉ោងទៀត ដោយមានបញ្ជាក់មូលហេតុជាលាយលក្ខណ៍អក្សរ។

៤.	ជនសង្ស័យត្រូវតែបញ្ជូនមកឲ្យសហព្រះរាជអាជ្ញា ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។ កាលណា បើមធ្យោបាយដឹកជញ្ជូនជួបការលំបាកឬ កន្លែងចាប់ខ្លួននៅឆ្ងាយពីអង្គជំនុំជម្រះវិសាមញ្ញ សហ-ព្រះរាជអាជ្ញាអាចផ្តល់ឲ្យពេលវេលាបន្ថែមសម្រាប់បញ្ជូនខ្លួនជនសង្ស័យ ។ មូលហេតុនៃការពន្យាពេល

ត្រូវសរសេរចូលក្នុងរបាយការណ៍ចុងក្រោយ ។

៥. ជនសង្ស័យអាចសុំជួបមេធាវី ដែលខ្លួនបានជ្រើសរើសហើយ ត្រូវជូនព័ត៌មាននេះជាបន្ទាន់ទៅដល់មេធាវីរូបនោះ តាមមធ្យោបាយទាំងអស់ដែលមាន ។ ជនសង្ស័យអាចជួបមេធាវីនោះ ឬ ប្រសិនបើមិនអាចធ្វើបានទេ គឺអាចជួបជាមួយមេធាវី ដែលផ្តល់ឲ្យដោយអង្គភាពគាំពារការការពារក្តីយ៉ាងយូរបំផុតក្នុងរយៈពេល៣០(សាមសិប)នាទី មុនពេលជនសង្ស័យបង្ហាញខ្លួននៅចំពោះមុខសហព្រះរាជអាជ្ញា ។ មេធាវីនោះត្រូវមានសិទ្ធិមានវត្តមាន ក្នុងអំឡុងពេលឃាត់ខ្លួន ដោយគោរពទៅតាមបទបញ្ជារដ្ឋបាលរបស់មន្ទីរឃុំឃាំង។

៦. សហព្រះរាជអាជ្ញាអាចស្នើសុំឲ្យវេជ្ជបណ្ឌិត ត្រួតពិនិត្យមើលជនសង្ស័យគ្រប់ពេលវេលាបាន ។ វេជ្ជបណ្ឌិត ត្រូវផ្ទៀងផ្ទាត់មើលថា តើលក្ខខណ្ឌសុខភាពរបស់ជនសង្ស័យសមស្របនឹងការឃុំខ្លួនបន្តទៀតឬទេ និង ត្រូវបញ្ជាក់អំពីលទ្ធផលដែលបានរកឃើញ។

៧. នៅពេលបញ្ចប់រយៈពេលឃាត់ខ្លួន ជនសង្ស័យត្រូវបានដោះលែង ឬ បញ្ជូនទៅសហចៅក្រម-ស៊ើបអង្កេត ដោយយោងតាមវិធាន ៥៧។

៨. សហព្រះរាជអាជ្ញា ត្រូវធ្វើរបាយការណ៍ចុងក្រោយមួយសម្រាប់រាល់ការឃាត់ខ្លួន និង ត្រូវមានព័ត៌មាន ដូចខាងក្រោមៈ

ក-ឈ្មោះ និងមុខងាររបស់មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាឃាត់ខ្លួន។
ខ-អត្តសញ្ញាណរបស់ជនសង្ស័យ។
គ-មូលហេតុនៃការឃាត់ខ្លួន។
ឃ-ពេលវេលា និងថ្ងៃឃាត់ខ្លួន។
ង-ឈ្មោះរបស់វេជ្ជបណ្ឌិតដែលបានពិនិត្យជនសង្ស័យ បើអាចធ្វើទៅបាន។
ច-អត្តសញ្ញាណរបស់មេធាវីដែលបានជួបជនសង្ស័យ។
ឆ-រយៈពេលសម្ភាសន៍ និង រយៈពេលសម្រាកចន្លោះពេលសម្ភាសន៍។
ជ- ពេលវេលា និងថ្ងៃបញ្ចប់នៃការឃាត់ខ្លួន។
ឈ-ឧប្បត្តិហេតុណាមួយដែលកើតមានក្នុងអំឡុងពេលឃាត់ខ្លួន។

ញ-សេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា នៅពេលផុតកំណត់រយៈពេលឃាត់ខ្លួន។

៩. របាយការណ៍ចុងក្រោយនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយនឹងសំណុំរឿង ហើយបញ្ជីនៃការឃាត់ខ្លួនត្រូវរក្សាទុកដោយការិយាល័យរដ្ឋបាល។

**វិធាន ៥២: ការហាមឃាត់មិនឲ្យស្តាប់ព័ត៌មានក្នុងពេលទំនាក់ទំនង**

សហព្រះរាជអាជ្ញាមិនមានសិទ្ធិអំណាចលួចស្តាប់ការសន្ទនា ឬ ចាប់យកព័ត៌មាន ឬ ថតយកនូវទំនាក់ទំនងតាមរយៈទូរស័ព្ទ ឬ អេឡិចត្រូនិច ដូចជាទូរសារ ឬ សារអេឡិចត្រូនិចបានឡើយ។

**វិធាន ៥៣: ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

១. ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតមានពិត សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងបុគ្គលមួយ ឬ ច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន។ ដីកានេះ ត្រូវមានព័ត៌មានដូចខាងក្រោមៈ

ក-សេចក្តីសង្ខេបអំពីអង្គហេតុ

ខ-ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់

គ-បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ

ឃ-ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន

ង-កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ។

២. ដីកានេះត្រូវអមដោយសំណុំរឿង និង សម្ភារៈដទៃទៀតដែលបានចាត់ទុកជាភស្តុតាង ដែលសហព្រះរាជអាជ្ញាមាន រួមទាំងអ្វីៗទាំងអស់ដែលសហព្រះរាជអាជ្ញាបានដឹងថា អាចជាភស្តុតាងដោះបន្ទុកផងដែរ។

៣. អវត្តមានផ្នែកណាមួយនៃទម្រង់ការខាងលើនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដូចមានចែងក្នុងអនុវិធាន ១ ត្រូវចាត់ទុកជាមោឃៈ។

៤.	ក្នុងរយៈពេលឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើប-អង្កេត នូវសម្ភារៈទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាចនាំឲ្យគ្មានពិរុទ្ធភាព ឬ សម្រាលពិរុទ្ធភាពនៃជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឲ្យប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុ-តាងក្នុងការចោទប្រកាន់។

៥.	ការិយាល័យរដ្ឋបាលត្រូវរៀបចំ និង ចុះលេខរៀងឯកសារថតចម្លងនៃព័ត៌មានទាំងនេះ ដោយប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមកុំព្យូទ័រ។

៦.	នៅពេលមានការសម្រេចតម្កល់ទុកឥតចាត់ការចំពោះពាក្យបណ្ដឹងណាមួយ ក្នុងពេលបញ្ចប់ការស៊ើបអង្កេតបឋម គ្រប់អ្នកប្ដឹងទាំងអស់ត្រូវបានជូនដំណឹងអំពីសេចក្ដីសម្រេចនេះក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតពីថ្ងៃចេញសេចក្ដីសម្រេច។

### វិធាន ៥៤: ការផ្ដល់ព័ត៌មានដល់សាធារណៈជនដោយសហព្រះរាជអាជ្ញា

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានស្ដាពរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា គឺជាឯកសារសម្ងាត់។ ប៉ុន្តែដោយគិតដល់តម្រូវការក្នុងការផ្ដល់ព័ត៌មាន ដល់សាធារណៈជនអំពីវិវឌ្ឍនភាពនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ សហព្រះរាជអាជ្ញាអាចផ្ដល់ឲ្យសាធារណៈជននូវព័ត៌មានសង្ខេប ដែលមាននៅក្នុងដីកាទាំងនេះ ដោយគិតពិចារណាដល់សិទ្ធិក្នុងការការពារខ្លួន ផលប្រយោជន៍របស់ជនរងគ្រោះ សាក្សី និង ជនដទៃទៀតដែលមានឈ្មោះក្នុងដីកានោះ និង តម្រូវការផ្នែកស៊ើបអង្កេត។ លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអាចកែតម្រូវរួមគ្នាដោយផ្ទាល់ ឬ តាមរយៈផ្នែកកិច្ចការសាធារណៈនូវព័ត៌មានមិនពិត ឬព័ត៌មាននាំឲ្យមានការភ័ន្តច្រឡំនៅពេលដែលសំណុំរឿងនោះ ស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម។

## <u>គ-ការស៊ើបសួរ</u>

### វិធាន ៥៥: បទប្បញ្ញត្តិទូទៅទាក់ទងទៅនឹងការស៊ើបសួរ

១.	ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំ-ជម្រះវិសាមញ្ញ។

២.	សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា	ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម។

៣.	ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី	សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មាន ដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំនត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់ ។ កាលណាអង្គហេតុថ្មីនេះ ត្រូវបានបញ្ជូនទៅឲ្យសហព្រះរាជ-អាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា។

៤.	សហចៅក្រមស៊ើបអង្កេត មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ	សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញាមុនពេលដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យ។

៥.	ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ។ ដើម្បីបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចៈ

ក-កោះហៅ និង សួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ស្តាប់ចម្លើយជនរងគ្រោះ និងសាក្សី និង កត់ត្រាទុកនូវចម្លើយរបស់ពួកគេ ប្រមូលវត្ថុតាង ស្វែងរកមតិយោបល់ពីអ្នកជំនាញ និង ដឹកនាំការស៊ើបសួរ ចុះដល់ទីកន្លែងកើតហេតុ។

ខ-ចាត់វិធានការសមស្របដើម្បីផ្តល់សុវត្ថិភាព និងគាំទ្រដល់សាក្សីសំខាន់ៗ និងប្រភពដទៃទៀត។

គ-ស្វែងរកព័ត៌មាន និងជំនួយពីបរទេស អង្គការសហប្រជាជាតិ ឬអង្គការអន្តររដ្ឋាភិបាល ឬ អង្គការក្រៅរដ្ឋាភិបាល ឬប្រភពសមស្របដទៃទៀត និង

ឃ-តាមការចាំបាច់ ចេញដីកានានាដើម្បីបំពេញកិច្ចស៊ើបសួរ ដូចជាដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន។

៦. ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍នៃការស៊ើបសួរ ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហ-ចៅក្រមស៊ើបអង្កេតក្នុងពេលម៉ោងធ្វើការ និងគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។

៧. រាល់ការស្តាប់ចម្លើយ ឬ សួរយកចម្លើយទាំងអស់របស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុ។ គ្រប់ទំព័រទាំងអស់នៃកំណត់ហេតុត្រូវមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃក្រោយពេលអ្នកដែលឆ្លើយនោះអាន រួចហើយ។ ក្នុងករណីចាំបាច់ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដោយមានជំនួយពីអ្នកបកប្រែ ត្រូវអានកំណត់ហេតុនេះឡើងវិញ។ ប្រសិនបើអ្នកដែលឆ្លើយនោះមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

៨. សហចៅក្រមស៊ើបអង្កេត អាចចុះដល់ទីកន្លែងដើម្បីបំពេញកិច្ចស៊ើបសួរ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ សហចៅក្រមស៊ើបអង្កេត ត្រូវអមដោយក្រឡាបញ្ជីរបស់ខ្លួន ដែលជាអ្នកធ្វើកំណត់ហេតុសម្រាប់ដាក់ក្នុងសំណុំរឿង។ សហចៅក្រមស៊ើបអង្កេត អាចជូនដំណឹងដល់ភាគីអំពីការចុះទៅដល់ទីកន្លែងកើតហេតុ នៅពេលដែលវត្តមានរបស់ខ្លួនអាចជាការចាំបាច់។ ក្នុងករណីនេះភាគីអាចស្នើសុំទៅចូលរួមជាមួយសហចៅក្រមស៊ើបអង្កេតបាន។

៩. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឲ្យស៊ើបសួរជំនួសបង្គាប់ឲ្យ នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ ឲ្យបំពេញកិច្ចការទាំងនេះដែលមានសារៈប្រយោជន៍ដល់ការស៊ើបសួររបស់ខ្លួន ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

១០. នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា

មានប្រយោជន៍ដល់ការស៊ើបសួរ ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រម-ស៊ើបអង្កេតត្រូវចេញដីកា បដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឲ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍។

១១. សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីពាក់ព័ន្ធមានសិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម ប៉ុន្តែត្រូវគោរព ទៅតាមពេលវេលាកំណត់ ដើម្បីធានាដល់និរន្តរភាពនៃកិច្ចដំណើរការនីតិវិធី។

## វិធាន ៥៦: ការផ្តល់ព័ត៌មានដល់សាធារណៈដោយសហចៅក្រមស៊ើបអង្កេត

១. ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់។

២. ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចៈ

ក-តាមរយៈផ្នែកកិច្ចការសាធារណៈ ផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឲ្យសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬ ដើម្បីកែតម្រូវព័ត៌មានមិនពិត ឬ ព័ត៌មាននាំឲ្យមានការភ័ន្តច្រឡំ។

ខ-ក្នុងកាលៈទេសៈពិសេស ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬ អ្នកដទៃទៀតដែលមិនមែនជាភាគីឲ្យចូលរួមដោយមានកំរិតនៅក្នុងកិច្ចស៊ើបសួរ ដោយការចូលរួមនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងរបស់ខ្លួន និង បន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ក្នុងករណីមិនគោរពទៅតាមល័ក្ខខ័ណ្ឌណាមួយដែលសហចៅក្រមស៊ើបអង្កេតតម្រូវ វិធាន ៣៥ ដល់ ៣៨ ត្រូវយកមកអនុវត្ត។

៣. ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងបញ្ហាដែលមានយោងនៅក្នុងអនុវិធាន ២ ខាងលើមិនត្រូវស្ថិតនៅក្រោមនីតិវិធីនៃការដោះស្រាយការខ្វែងយោបល់គ្នា ដូចមានចែងនៅក្នុងវិធាន ៧២ ឡើយ។

## វិធាន ៥៧: ការជូនដំណឹងអំពីបទចោទប្រកាន់

១. នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហ-

ចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និង ប្រាប់ជននោះអំពីបទចោទប្រកាន់ និង អំពីសិទ្ធិមាន មេធាវី និង សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ព្រម ឆ្លើយនោះសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការសួរចម្លើយនោះភ្លាម។ កំណត់ហេតុសួរចម្លើយត្រូវដាក់ចូលក្នុងសំណុំរឿង។

២. នៅពេលដែលជនត្រូវចោទត្រូវបានឃុំខ្លួន ជននោះត្រូវមានសិទ្ធិលើកឡើងនូវបញ្ហាពាក់ព័ន្ធទៅនឹងការអនុវត្តបទប្បញ្ញត្តិ ឬនីតិវិធីឲ្យបានត្រឹមត្រូវពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន។

៣. កាលណាជនត្រូវចោទមិនត្រូវបានឃុំខ្លួនក្រោយពេលចូលបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអំពីអាស័យដ្ឋានរបស់ខ្លួន។ ជនត្រូវចោទ ត្រូវទទួលការជូនដំណឹងដូចខាងក្រោមថា:

ក-ខ្លួនត្រូវជូនព័ត៌មានដល់សហចៅក្រមស៊ើបអង្កេត នៅពេលណាមានការផ្លាស់ប្តូរអាស័យដ្ឋាន។
ខ-រាល់ការបញ្ជូនដីកា ឬ ការជូនដំណឹងទាំងអស់ដែលធ្វើឡើងចំពោះអាសយដ្ឋានចុងក្រោយដែលត្រូវបានផ្តល់ឲ្យ ត្រូវចាត់ទុកថាមានសុពលភាព។

៤. ការជូនដំណឹងនេះត្រូវកត់ត្រាទុកនៅក្នុងសំណុំរឿង។

**វិធាន ៥៨: ការសួរចម្លើយជនត្រូវចោទ**

១. នៅពេលជនត្រូវចោទមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ)ថ្ងៃមុនពេលធ្វើការសួរចម្លើយ។ ក្នុងអំឡុងពេលនេះ មេធាវីអាចពិនិត្យមើលសំណុំរឿងបាន។

២. ការសួរចម្លើយជនត្រូវចោទ ត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែជនត្រូវចោទ យល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន និងត្រូវសរសេរចូលក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយដោយឡែកដោយមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនត្រូវចោទ ហើយត្រូវដាក់ចូលទៅក្នុងសំណុំរឿង។ ការយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ជនត្រូវចោទ ត្រូវថតទុកដូចមានចែងក្នុងវិធាន ២៥។ ប្រសិនបើមេធាវីបានទទួលដីកាកោះហៅត្រឹមត្រូវហើយ តែខកខានមិនបានចូលមកបង្ហាញ ខ្លួនតាមពេលវេលា និង ថ្ងៃកំណត់ សហចៅក្រមស៊ើបអង្កេតអាចស្នើសុំ

ឲ្យអង្គភាពគាំពារការការពារក្តីចាត់តាំងមេធាវីមួយរូប មកជំនួសបណ្តោះអាសន្នចេញពីបញ្ជីមេធាវីដូចមានចែងក្នុងវិធាន ១១។ នៅពេលនោះ មេធាវីដែលចាត់តាំងថ្មី អាចមានសិទ្ធិត្រួតពិនិត្យមើលសំណុំរឿង ក្នុងរយៈពេលណាមួយសមស្រប ហើយសហចៅក្រមស៊ើបអង្កេត អាចសួរយកចម្លើយជនត្រូវចោទ ដោយមានវត្តមានរបស់មេធាវីនោះ។ វត្តមានរបស់មេធាវីដែលចាត់តាំងថ្មីត្រូវសរសេរចូលក្នុងកំណត់ហេតុនៃការសួរយកចម្លើយជាមួយនឹងមូលហេតុ ប្រសិនបើដឹងអំពីអវត្តមានរបស់មេធាវីដែលជនត្រូវចោទបានជ្រើសរើស។

៣. ក្នុងករណីបន្ទាន់ ដោយមានការយល់ព្រមពីជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតអាចសួរចម្លើយជនត្រូវចោទដោយមិនចាំបាច់មានវត្តមានរបស់មេធាវី។ ស្ថានភាពបន្ទាន់កើតមានឡើងនៅពេលណាដែលមាន ការជឿជាក់យ៉ាងច្បាស់ថាអាចបាត់បង់ជារៀងរហូតនូវភស្តុតាង នៅខណៈពេលរង់ចាំមេធាវីមកដល់ ដូចជាជនត្រូវចោទជិតដល់ពេលស្លាប់ជាដើម។ មូលហេតុនៃស្ថានភាពបន្ទាន់នេះ ត្រូវសរសេរចូលឲ្យបានច្បាស់លាស់ នៅក្នុងកំណត់ហេតុនៃការសួរយកចម្លើយ។

៤. នៅពេលកំពុងសួរចម្លើយជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងអំពីការសួរចម្លើយនេះទៅសហព្រះរាជអាជ្ញាក្នុងថេរៈវេលាមួយដែលសមរម្យ។ សហព្រះរាជអាជ្ញាអាចចូលរួមនៅពេលសួរចម្លើយ និងអាចលើកសំនួរបានដែរ ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ ក្នុងករណីមិនអនុញ្ញាត ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ភាគីដទៃទៀត មិនត្រូវមានវត្តមានទេ លើកលែងតែករណីសហចៅក្រមស៊ើបអង្កេតសម្រេចឲ្យធ្វើការតទល់គ្នាដោយផ្ទាល់រវាងជនត្រូវចោទ និង ភាគី ឬសាក្សីដទៃទៀត។ អនុលោម ទៅតាមវិធានការការពារណាមួយ ខ្លឹមសារនៃអនុវិធាន ១ ដល់អនុវិធាន ៣ នៃវិធាននេះ ត្រូវអនុវត្តចំពោះ ការតទល់គ្នា។

៥. ក្នុងករណីតទល់គ្នា សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀតអាចសួរសំណួរបានដោយមាន ការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឲ្យសួរសំណួរ ការបដិសេធនេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុនៃការសួរចម្លើយ។

៦. ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឲ្យធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងដទៃទៀត ។ សំណើនេះត្រូវធ្វើជាលាយល័ក្ខអក្សរដោយមានបញ្ជាក់មូលហាតុពិតប្រាកដ។ ប្រសិនបើសហចៅក្រម

ស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឲ្យបានឆាប់បំផុតតាម ដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនេះនៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុ។ ជនត្រូវចោទ ត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ។ ជនត្រូវចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ។

## វិធាន ៥៩: ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

(វិសោធនកម្មថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨)

១. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ បើដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ)ថ្ងៃមុនពេលធ្វើការស្តាប់ចម្លើយ ។ ក្នុងអំឡុងពេលនេះ មេធាវីអាចពិនិត្យមើលសំណុំរឿងបាន។

២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយសហចៅក្រមស៊ើបអង្កេត ត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែដើមបណ្តឹងរដ្ឋប្បវេណីយល់ព្រមឆ្លើយ ដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន ហើយត្រូវសរសេរចូលក្នុងកំណត់ ហេតុជាលាយល័ក្ខអក្សរមួយដោយឡែកដោយមានហត្ថលេខារបស់ដើមបណ្តឹងរដ្ឋប្បវេណី រួចត្រូវដាក់ចូលទៅក្នុងសំណុំរឿង ហើយត្រូវបានថតទុកដូចមានចែងនៅក្នុងវិធាន ២៥។ ប្រសិនបើមេធាវីដែលត្រូវបានកោះ ហៅដោយត្រឹមត្រូវតែខកខានមិនបានចូលខ្លួនតាមកាលបរិច្ឆេទ និង ពេលវេលាកំណត់ ការស្តាប់ចម្លើយអាចដំណើរការបាន។ និទ្ទេសស្តីពីអវត្តមានត្រូវចុះក្នុងកំណាត់ហេតុស្តាប់ចម្លើយ។

៣. នៅពេលកំពុងស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ភាគីដទៃទៀតមិនត្រូវមានវត្តមានទេលើកលែងតែករណីសហចៅក្រមស៊ើបអង្កេតសម្រេចឱ្យធ្វើការតទល់គ្នាដោយផ្ទាល់រវាងដើមបណ្តឹងរដ្ឋប្បវេណី និងភាគី ឬសាក្សីដទៃទៀត។ ខ្លឹមសារនៃអនុវិធាន ១ ដល់អនុវិធាន ២ នៃវិធាននេះត្រូវអនុវត្តចំពោះការតទល់គ្នា អនុលោមទៅតាមវិធានការកាពារ។

៤. ក្នុងករណីតទល់គ្នា សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀតអាចសួរសំណួរបានដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត មិនអនុញ្ញាតអោយសួរសំណួរ ការបដិសេធនេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ។

៥. ក្នុងអំឡុងពេលស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឲ្យធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងដទៃទៀត។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានមូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិន យល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនៅមុនពេលបញ្ចប់ការស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ។ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ និង អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ ។

៦. តាមរយៈដីកាចាត់អោយស៊ើបសួរជំនួស ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេត នៃ អ.វ.ត.ក ទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

ក. ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវផ្តល់ការយល់ព្រមរបស់ខ្លួនយ៉ាងច្បាស់ ហើយការយល់ព្រមនេះត្រូវមានចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ។

ខ. នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីនោះ ត្រូវលះបង់ការមានវត្តមាននៃមេធាវីរបស់ខ្លួនដោយធ្វើជាលាយលក្ខ័អក្សរ នៅក្នុងកំណត់ហេតុមួយដោយឡែកស្របតាមអនុវិធាន ២ ខាងលើ។

គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយមិនមានវត្តមានរបស់ភាគីដទៃទៀតទេ។

**វិធាន ៦០: ការស្តាប់ចម្លើយសាក្សី**

១. សហចៅក្រមស៊ើបអង្កេតអាចស្តាប់ចម្លើយពីជនណា ដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍ក្នុងការសំដែងឲ្យឃើញការពិតដោយយោងទៅលើវិធាន ២៨។

២. លើកលែងតែការធ្វើការតទល់គ្នា សហចៅក្រមស៊ើបអង្កេត ឬ អ្នកទទួលសិទ្ធិត្រូវស្តាប់ចម្លើយសាក្សី ដោយគ្មានវត្តមានជនត្រូវចោទ ភាគីដទៃទៀត ឬមេធាវី នៅទីកន្លែងណាដែលអាចរក្សាការសម្ងាត់បាន។

៣. បុគ្គលទាំងឡាយណា ដែលត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួន ដោយសហចៅក្រមស៊ើបអង្កេត

ក្នុងនាមជា សាក្សីត្រូវតែមកបង្ហាញខ្លួន ។ ក្នុងករណីបដិសេធមិនព្រមចូលមកបង្ហាញខ្លួន សហចៅក្រមស៊ើបអង្កេតអាចចេញ ដីកាអោយនគរបាលយុត្តិធម៌បង្ខំសាក្សីនោះមកបង្ហាញខ្លួន ដោយស្នើសុំឲ្យនគរបាលយុត្តិធម៌បង្ខំសាក្សីនោះឲ្យមកបង្ហាញខ្លួន ។ ដីកានេះត្រូវមាន អត្តសញ្ញាណរបស់សាក្សី និងមានចុះកាលបរិច្ឆេទ និងហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេត។

## វិធាន ៦១: ការឆែកឆេរ និងការចាប់យកវត្ថុតាង

១. សហចៅក្រមស៊ើបអង្កេត ឬ អ្នកទទួលការចាត់តាំង ត្រូវឆែកឆេរលំនៅដ្ឋានណាមួយ ដោយមានវត្តមាន របស់អ្នកកាន់កាប់ បើពុំនោះទេត្រូវធ្វើឡើងដោយមានវត្តមានសាក្សី២(ពីរ)រូប ដែលជ្រើសតាំងដោយ សហចៅក្រមស៊ើបអង្កេត ឬ អ្នកទទួលការចាត់តាំង ។ សាក្សីទាំងពីរខាងលើនេះមិនត្រូវជាមន្ត្រីនគរបាលឡើយ។

២. គ្រប់ការឆែកឆេរត្រូវកត់ត្រាទុកជាលាយល័ក្ខអក្សរ និងត្រូវរៀបរាប់អំពីទីតាំងលំនៅដ្ឋាន អត្តសញ្ញាណរបស់អ្នកកាន់កាប់ ឬ សាក្សី តាមករណីសមស្រប។ សហចៅក្រមស៊ើបអង្កេត ឬអ្នកទទួលការចាត់តាំង និងអ្នកកាន់កាប់ ឬសាក្សី ត្រូវចុះហត្ថលេខាលើកំណត់ហេតុ។

៣. សហចៅក្រមស៊ើបអង្កេត ឬ អ្នកទទួលការចាត់តាំង ត្រូវបង្ហាញភស្តុតាងដែលរឹបអូសបានទៅឲ្យអ្នកកាន់ កាប់ ឬ សាក្សីពិនិត្យមើលមុននឹងបិទស្លាកបោះត្រាលើភស្តុតាង។ កំណត់ហេតុនៃភស្តុតាងដែលរឹបអូសបាន ត្រូវមានភ្ជាប់នូវបញ្ជីសារពើភ័ណ្ឌលម្អិតផង។

៤. បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគី សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឲ្យប្រគល់វត្ថុទៅឲ្យបុគ្គល ដែលត្រូវបានចាប់យកវិញនៅពេលណាក៏បាន ប៉ុន្តែការប្រគល់នេះមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ដំណើការនីតិវិធីឡើយ។ ដីកានេះត្រូវជូនដំណឹងភ្លាមទៅដល់បុគ្គលនោះ។

## វិធាន ៦២: ដីកាចាត់ឲ្យស៊ើបសួរជំនួស

(វិសោធនកម្មថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨)

១. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឲ្យស៊ើបសួរជំនួសទៅឲ្យអ្នកស៊ើបអង្កេតនៃការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែមានតែនគរបាលយុត្តិធម៌ទេ ដែលមាន

អំណាចក្នុងការអនុវត្តន៍វិធានការចាប់បង្ខំ។

២. ដីកាចាត់ឲ្យស៊ើបសួរជំនួស មិនត្រូវសរសេរជាទម្រង់ទូទៅឡើយ តែត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើការស៊ើបសួរ និងដែលមានជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងបទល្មើសណាមួយ ឬជាមួយនឹងបទល្មើសដែលកំពុងស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតត្រូវកំណត់ពេលវេលាដែលត្រូវអនុវត្តក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស។ ដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវមានចុះហត្ថលេខា និងកាលបរិច្ឆេទដោយសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតអាចដកនូវដីកាចាត់ឲ្យស៊ើបសួរជំនួសនេះមកវិញនៅពេលណាក៏បាន។

៣. អ្នកទទួលការចាត់តាំងត្រូវធ្វើការងារក្រោមការដឹកនាំរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវរាយការណ៍ជូនទៅសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ អំពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស។ នៅពេលដែលដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឲ្យទៅអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬនគរបាលយុត្តិធម៌ ជននោះត្រូវអនុវត្តដូចខាងក្រោម៖

- ក- នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេត ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួររបស់ខ្លួន ដោយអនុលោមតាមបញ្ញត្តិនៃវិធាន ៥១-៨ តាមករណីសមស្រប។
- ខ- នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតមិនត្រូវសួរចម្លើយជនត្រូវចោទឡើយ។ អ្នកស៊ើបអង្កេតអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមអនុវិធាន ៥៩(៦)។
- គ- នគរបាលយុត្តិធម៌ អាចឆែកឆេរ និងចាប់យកវត្ថុតាងបាន ដោយមានការអនុញ្ញាតពីសហ-ចៅក្រមស៊ើបអង្កេត។

៤. បទប្បញ្ញត្តិនៃវិធាន ៥១ ស្តីពីការឃាត់ខ្លួន ត្រូវអនុវត្តចំពោះការស៊ើបសួរតាមដីកាចាត់ឲ្យស៊ើបសួរជំនួស។ ក្នុងករណីនេះ អំណាចរបស់សហព្រះរាជអាជ្ញាត្រូវបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត។

## **វិធាន ៦៣: ការឃុំខ្លួនបណ្តោះអាសន្ន**

(វិសោធនកម្មថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨)

១. ក- សហចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ក្រោយពេលមាន

សវនាការតទល់គ្នា។ ប្រសិនបើជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីណាមួយនៅឡើយទេ សហចៅក្រមស៊ើបអង្កេត ត្រូវប្រាប់ជនត្រូវចោទអំពីសិទ្ធិមានមេធាវីការពារ ដូចមានចែងក្នុងវិធាន ២១-១(ឃ)។ ជនត្រូវចោទមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន។ ក្នុងពេលសវនាការតទល់គ្នានេះ សហចៅក្រមស៊ើបអង្កេត ត្រូវស្តាប់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទ។ នៅពេលបញ្ចប់សវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេត ត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវបានដោះលែងឲ្យមានសេរីភាព។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើប-អង្កេតត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួន។

ខ- ប៉ុន្តែនៅពេលដែលជនត្រូវចោទ ឬមេធាវីរបស់ជនត្រូវចោទ ស្នើសុំពេលវេលាសម្រាប់រៀបចំការការពារក្តី សហចៅក្រមស៊ើបអង្កេតមិនត្រូវសម្រេចឃុំខ្លួនបណ្តោះអាសន្នភ្លាមនោះទេ។ ក្នុងករណីនេះសហចៅក្រមស៊ើបអង្កេតអាចចេញដីកា ដោយមានសំអាងហេតុសំរេចឃាត់ខ្លួនជនត្រូវចោទ សម្រាប់រយៈពេលមួយមានកំណត់ដែលមិនត្រូវលើសពី ៧ ថ្ងៃ។ នៅក្នុងរយៈពេលនេះ ជនត្រូវចោទ ត្រូវនាំមកបង្ហាញខ្លួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតម្តងទៀតដោយអនុវត្តទៅតាមនីតិវិធីដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ទោះបីជាជនត្រូវចោទនេះ មានមេធាវី ឬមិនមានមេធាវីការពារក៏ដោយ។ រយៈពេលនៃការឃាត់ខ្លួនបណ្តោះអាសន្នដែលធ្វើឡើង ដោយស្របតាមអនុវិធាននេះ នឹងត្រូវរាប់បញ្ចូលដើម្បីគិតថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ធ្វើឡើងស្របតាមអនុវិធាន ៦ អនុវិធាន ៧ និង អនុវិធាន ៨ នៃវិធាននេះ។

គ- នៅពេលមិនមានមេធាវីរបស់ជនត្រូវចោទ ឬបើសិនជាមេធាវីរបស់ជនត្រូវចោទអវត្តមាននៅក្នុងសវនាការដែលបានកំណត់កាលបរិច្ឆេទ និងម៉ោង ហើយក្នុងករណីដែលជនត្រូវចោទស្នើសុំអោយមានជំនួយពីមេធាវី សហចៅក្រមស៊ើបអង្កេត ត្រូវស្នើសុំទៅអង្គភាពគាំពារការការពារក្តី ដើម្បីចាត់តាំងមេធាវី ជូនជនជាប់ចោទនោះជាបណ្តោះអាសន្នពីបញ្ជីដូចដែលមានចែងនៅក្នុងវិធាន ១១។

២. ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវតាក់តែងឡើងដូចខាងក្រោម:

ក- បញ្ជាក់អំពីអង្គហេតុ និងអង្គច្បាប់ដែលនាំឲ្យមានការឃុំខ្លួន ដោយផ្អែកទៅលើអនុវិធាន ៣ ខាងក្រោម។

ខ- បញ្ជាក់ឲ្យច្បាស់អំពីរយៈពេលអតិប្បរមាដំបូងនៃការឃុំខ្លួនបណ្តោះអាសន្ន និង

គ-នៅពេលជូនដីកាដល់ជនត្រូវចោទត្រូវអមទៅជាមួយនូវឯកសារបញ្ជាក់ប្រាប់អំពីសិទ្ធិរបស់គាត់។

៣. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម:

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី:

(១) រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

៤. ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅអង្គបុរេជំនុំជម្រះ។

៥. ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត ត្រូវប្រគល់ជាបន្ទាន់នូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នថតចម្លងមួយច្បាប់ទៅឲ្យជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ និងទៅឲ្យសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល។

៦. ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងដូចខាងក្រោម:

ក- ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋសង្គ្រាម និងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបាន ១ (មួយ) ឆ្នាំ។

ខ- ចំពោះបទឧក្រិដ្ឋផ្សេងទៀតដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ការឃុំខ្លួន

បណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នបន្ថែមម្ដងបាន ៦ (ប្រាំមួយ) ខែ។

៧. ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមានសំអាងហេតុ ចំពោះការពន្យាពេលនៃការបន្តឃុំខ្លួនបណ្ដោះអាសន្ន។ ការពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើបានតែក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ ហើយត្រូវផ្ដល់រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីទុកពេលឲ្យប្ដឹងតវ៉ាទៅសហចៅក្រមស៊ើប-អង្កេត។ ទោះជាយ៉ាងណាក៏ដោយ ការពន្យាពេលមិនត្រូវឲ្យលើសពី ២ (ពីរ) ដងបានឡើយ។ ដីកាសម្រេចនេះបើកផ្លូវប្ដឹងឧទ្ធរណ៍។

៨. នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទដែលត្រូវឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេតយ៉ាងហោចណាស់រៀងរាល់ ៤ (បួន) ខែម្ដង។ សហចៅក្រមស៊ើបអង្កេតត្រូវផ្ដល់ឱកាសដល់ជនសង្ស័យ ដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និងល័ក្ខខ័ណ្ឌនៃការឃុំខ្លួន។ បើយល់ឃើញថាកាលៈទេសៈតម្រូវឲ្យចាត់វិធានការ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាបង្គាប់សមស្របណាមួយបាន។ កំណត់ហេតុនៃការសាកសួរនេះ ត្រូវដាក់ចូលទៅក្នុងសំណុំរឿង។

## វិធាន ៦៤: ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ

១. តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ឬតាមសំណើរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាបង្គាប់ឲ្យដោះលែងជនត្រូវចោទ ដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ននៅពេលណាក៏បាន ប្រសិនបើល័ក្ខខ័ណ្ឌតម្រូវនៃការឃុំខ្លួនបណ្ដោះអាសន្នដូចមានចែងក្នុងវិធាន ៦៣ ខាងលើនេះលែងមានទៀតហើយ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតកំពុងពិចារណាធ្វើការដោះលែងជនត្រូវចោទ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតត្រូវសុំយោបល់ពីសហព្រះរាជអាជ្ញាមុននឹងចេញដីកា។ ដីកាសម្រេចនេះបើកផ្លូវប្ដឹងឧទ្ធរណ៍។

២. ក្នុងអំឡុងពេលឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទ ឬ មេធាវីរបស់គាត់ អាចធ្វើសំណើសុំឲ្យដោះលែងទៅ សហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា។ បន្ទាប់ពីទទួលបានសំណើនេះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណើនេះឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ទៅសហព្រះរាជអាជ្ញាដែលត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ដោយយោងទៅលើបទប្បញ្ញត្តិនៃវិធាន ៧២-២ សហ

ចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ក្រោយពេលទទួលបានយោបល់ពីសហព្រះរាជអាជ្ញា។ ដីកាសម្រេចនេះ បើកផ្លូវប្តឹងឧទ្ធរណ៍។

៣. ប្រសិនបើស្ថានភាពផ្លាស់ប្តូរ ចាប់ពីពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំជាថ្មីម្តងទៀត ក្នុងរយៈពេលមិនតិចជាង ៣(បី)ខែ បន្ទាប់ពីមានសេចក្តីសម្រេចចុងក្រោយដែលបដិសេធពាក្យសុំដោះលែងឲ្យនៅក្រៅឃុំ។

៤. ដីកាបង្គាប់ឲ្យដោះលែងជនត្រូវចោទនៅក្រៅឃុំត្រូវ ជូនដំណឹងភ្លាមទៅដល់សហព្រះរាជអាជ្ញា និង ជនត្រូវចោទ។ ដីកាមិនព្រមដោះលែងឲ្យនៅក្រៅឃុំ ក៏ត្រូវជូនដំណឹងភ្លាមផងដែរទៅដល់សហព្រះរាជអាជ្ញា និង ជនត្រូវចោទ។ ដីកាបង្គាប់ឲ្យដោះលែងជនត្រូវចោទពីមន្ទីរឃុំឃាំង ត្រូវតែជូនដំណឹងភ្លាមដល់ប្រធានការិយាល័យរដ្ឋបាល និងប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញបន្ទាប់ពីដីកានោះចាប់ផ្តើមមានអនុភាពអនុវត្ត។

### វិធាន ៦៥: ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

១. តាមការយល់ឃើញរបស់ខ្លួន ឬ តាមសំណើរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតអាចចេញបង្គាប់ឲ្យជនត្រូវចោទមានសេរីភាពឡើងវិញ ឬ ត្រូវដោះលែងពីការឃុំខ្លួន ។ ជនជាប់ចោទអាចដាក់អោយនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ ដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេតនេះត្រូវមានបញ្ជាក់ឲ្យច្បាស់លាស់អំពីប្រាក់ធានា និង លក្ខខណ្ឌមួយចំនួន ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និង ដើម្បីការពារអ្នកដទៃទៀត។ ដីកាសម្រេចនេះបើកផ្លូវប្តឹងឧទ្ធរណ៍។

២. ជនត្រូវចោទត្រូវទទួលនូវបង្កាន់ដៃពីក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ចំពោះទ្រព្យសម្បត្តិ ឬ ថវិកាដែលបានប្រគល់មកឲ្យ។

៣. ជនត្រូវចោទ និង សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងភ្លាម អំពីដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

៤. តាមសំណើរបស់សហព្រះរាជអាជ្ញា ឬ តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន សហចៅក្រមស៊ើបអង្កេតអាចផ្លាស់ ប្តូរ ព្យួរ ឬ បន្ថែមលក្ខខណ្ឌ ឬបញ្ចប់ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ពេលណាក៏បាន។ ជនត្រូវចោទ និង សហព្រះរាជអាជ្ញាត្រូវជូនដំណឹងភ្លាមអំពីដីកានេះ។ ដីកា

សម្រេចនេះបើកផ្លូវប្ដឹងឧទ្ធរណ៍។

៥. ជនត្រូវចោទ អាចស្នើសុំឲ្យមានការផ្លាស់ប្ដូរ ឬ ព្យួរ ឬ បញ្ចប់នូវល័ក្ខខ័ណ្ឌនៃដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណើនេះទៅសហព្រះរាជអាជ្ញាភ្លាមដើម្បីសុំយោបល់ហើយសហព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ដោយយោងទៅលើបទប្បញ្ញត្តិនៃវិធាន ៧២-២ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាក្នុងរយៈពេល១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានយោបល់ពីសហព្រះរាជអាជ្ញា។ ដីកានេះ ត្រូវជូនដំណឹងភ្លាមដល់ជនត្រូវចោទ និង សហព្រះរាជអាជ្ញា។

៦. បើជនត្រូវចោទរំលោភលក្ខខណ្ឌដែលមានចែងក្នុងដីកានេះ សហចៅក្រមស៊ើបអង្កេតអាចចេញសេចក្ដីព្រមាន ឬ ចេញដីកាឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទនោះបាន ។ ដីកាសម្រេចនេះបើកផ្លូវប្ដឹងឧទ្ធរណ៍។

## វិធាន ៦៦: ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា

(វិសោធនកម្ម ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩)

១. នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់គ្រប់ភាគី និង មេធាវីរបស់ភាគី ។ សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរនេះត្រូវប្រកាសជាសាធារណៈ។ ភាគីទាំងអស់មានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម។ ភាគីទាំងអស់អាចលះបង់ថិរៈវេលានេះបាន។

២. នៅពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើទាំងនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធដោយមានសំអាងហេតុ។ ដីកានេះត្រូវបដិសេធផងដែរនូវរាល់សំណើទាំងអស់ដែលបានដាក់ជូនតាំងពីពេលដំបូងនៃការស៊ើបសួរ ដែលខ្លួនមិនទាន់បានសម្រេចនៅឡើយ។

៣. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពីបានទទួលដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ។ ភាគីទាំងអស់អាចបោះបង់ចោលសិទ្ធិប្ដឹងឧទ្ធរណ៍នេះបាន ទោះបីជាមានវត្តមាន របស់មេធាវី ឬ ក្នុងករណីដែលមេធាវីត្រូវបានកោះហៅដោយត្រឹមត្រូវ ប៉ុន្តែមិនបានចូលបង្ហាញខ្លួន។

៤. នៅពេលដែលថិរៈវេលាកន្លងផុត ឬ ត្រូវបានបោះបង់ ឬ បណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងពីខាងលើត្រូវបានជម្រះហើយ សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅសហព្រះរាជ-អាជ្ញា។

៥. នៅពេលដែលសហព្រះរាជអាជ្ញាយល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា ការស៊ើបសួរត្រូវបានចប់សព្វគ្រប់ហើយ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរមួយជាលាយល័ក្ខអក្សរ និង មានសំអាងហេតុ ហើយត្រូវបញ្ជូនសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញក្នុង ថិរៈវេលា៤៥ (សែសិបប្រាំ)ថ្ងៃ ក្នុងករណីដែលជនត្រូវចោទជាប់ក្នុងឃុំ ហើយថិរៈវេលានេះត្រូវពន្យារដល់៣(បី)ខែ ក្នុងករណីផ្សេងទៀត គិតចាប់ពីថ្ងៃដែលសហព្រះរាជអាជ្ញាបានទទួលសំណុំរឿង ។សហព្រះរាជអាជ្ញាអាចសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ និង បញ្ជូនជនត្រូវចោទនេះទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។

## វិធាន ៦៧: ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត

(វិសោធនកម្មថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និង ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និង បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហ-ព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ។

២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី។

៣. សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម:

ក-អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះ-វិសាមញ្ញ។

ខ-ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ

គ-ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ

៤. ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬ ប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត។

៥. សហព្រះរាជអាជ្ញា ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជូនដំណឹងជាបន្ទាន់អំពីការចេញដីកាដំណោះស្រាយនេះ និង ទទួលបានច្បាប់ចម្លងនៃដីកានេះនៅពេលបន្ទាប់។ ដីកាដំណោះស្រាយនេះបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤។ ដើមបណ្តឹងរដ្ឋប្បវេណីដែលបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងការបដិសេធមិនទទួលយកពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានទទួលជោគជ័យស្របតាមវិធាន ២៣(៥) នៃវិធានផ្ទៃក្នុង ត្រូវចូលរួមជាមួយនឹងក្រុមនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នាតែមួយនោះ ហើយដើមបណ្តឹងរដ្ឋប្បវេណីណាដែលបណ្តឹងឧទ្ធរណ៍របស់ពួកគាត់លើដីកាលើកលែងចោទប្រកាន់ កំពុងរង់ចាំសេចក្តីសម្រេច ក៏ត្រូវចូលរួមជាមួយនឹងក្រុមនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នាតែមួយនោះ ដែរ។

៦. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត ត្រូវចេញសេចក្តីសម្រេចចាំបាច់ណាមួយទាក់ទងនឹងវត្ថុតាងដែលបិទស្លាកបោះត្រា សហចៅក្រមស៊ើបអង្កេតអាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យមានការដាក់ជូនសារណាពីសំណាក់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី។

## វិធាន ៦៨: អានុភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និង ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

(វិសោធនកម្ម ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៨)

១. ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននិងដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ឬ ឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥នៅតែតម្រូវ សហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬ រក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុដាក់លាក់មួយដោយឡែក នៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះត្រូវនាំខ្លួន

ទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង។

២. នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អានុភាពនៃសេចក្តីសម្រេចរក្សាជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តមានអានុភាពអនុវត្តរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ ។ អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងអំឡុងពេល ៤ខែ ។

៣. ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬ រក្សាលក្ខខណ្ឌ នៃការដាក់អោយនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ ត្រូវអស់អានុភាពក្នុងរយៈពេល ៤(បួន)ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ ។

៤. ប្រសិនបើក្នុងកាលៈទេសៈពិសេស រួមទាំងមូលហេតុនៃស្ថានភាពសុខភាព ដែលជនជាប់ចោទមិនអាចបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នបន្ទាប់ពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទដែលត្រូវបានរៀបចំឡើងតាមរយៈមធ្យោបាយពីចំងាយដោយប្រើប្រាស់ឧបករណ៍សំលេង-រូបភាពដែលសមស្រប ឬ ដោយចុះទៅដល់ទីកន្លែងនៃការឃុំខ្លួន។

### វិធាន ៦៩: ការបញ្ជូនសំណុំរឿងក្រោយពេលមានដីកាដំណោះស្រាយ

(វិសោធនកម្ម ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ និង ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០ និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)

១. នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងវិធាន ៧៧។

២. នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង ៖

ក) ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់កាលបរិច្ឆេទសវនាការ។

ខ) ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយពី

ផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍។

៣. ការដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ។

**វិធាន ៧០: ការបើកការស៊ើបសួរឡើងវិញ**

នៅពេលដែលមានបន្ទុកថ្មីលេចឡើង បន្ទាប់ពីដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើប-អង្កេតបានចូលជាស្ថាពរ ការស៊ើបសួរអាចនឹងត្រូវចាប់ផ្តើមឡើងវិញដោយសហចៅក្រមស៊ើបអង្កេត តាមគំនិតផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា។

**<u>ឃ-នីតិវិធីចំពោះអង្គបុរេជំនុំជម្រះ</u>**

**វិធាន ៧១: ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា**

១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាណាមួយ ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ហើយត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា។

២. ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ សហព្រះរាជអាជ្ញាណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈការបញ្ជូនឯកសារអំណះអំណាងជាលាយល័ក្ខអក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល។ ការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅឲ្យចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅឲ្យសហព្រះរាជអាជ្ញាម្ខាងទៀត។ ក្នុងករណីនេះ សហព្រះរាជអាជ្ញាម្ខាងទៀតអាចដាក់ជូនឯកសារឆ្លើយតបក្នុងរយៈពេល ១០(ដប់)ថ្ងៃ។ ឯកសារអំណះអំណាងជាលាយល័ក្ខអក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងឡើយ។ ក្រឡាបញ្ជីរបស់សហ-ព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅឲ្យអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហព្រះរាជអាជ្ញាត្រូវប្រឹងប្រែង

ស្វែងរកការឯកភាពគ្នា ។ កិច្ច ឬ សេចក្ដីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែយកទៅអនុវត្ត លើកលែងតែបញ្ហានៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ខ-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋថ្មី

គ-ដីកាសន្និដ្ឋានស្ថាពរ ឬ

ឃ-សេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងការប្ដឹងឧទ្ធរណ៍

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅនឹងការខ្វែងគំនិតគ្នាត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានសម្រេចឡើង ឬ រយៈពេល ៣០(សាមសិប)ថ្ងៃ ត្រូវបានកន្លងផុត ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ ដូចខាងក្រោម ៖

ក-សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវរៀបចំធ្វើឡើង និង ប្រកាសសាលក្រមជាសម្ងាត់ ។ ការចូលរួមពីចម្ងាយអាចធ្វើទៅបានតាមការចាំបាច់។

ខ-អង្គបុរេជំនុំជម្រះដោយអំណាចឆន្ទានុសិទ្ធិ អាចបង្គាប់ឲ្យសហព្រះរាជអាជ្ញាចូលមកបង្ហាញខ្លួនដោយផ្ទាល់ រួមទាំងការបង្ហាញវត្ថុតាង។

គ-សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច ។ សេចក្ដីសម្រេចនេះបិទផ្លូវប្ដឹងឧទ្ធរណ៍ ។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរកបានសម្លេងគាំទ្រភាគច្រើនតាមការតម្រូវទេ ដោយអនុលោមតាមមាត្រា ២០ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រភាគច្រើនមានន័យថាកិច្ច ឬ សេចក្ដីសម្រេចដែលបានធ្វើដោយសហព្រះរាជអាជ្ញាណាម្នាក់ត្រូវមានសុពលភាព ឬ មានន័យថាកិច្ច ឬ សេចក្ដីសម្រេច ដែលបម្រុងនឹងធ្វើដោយសហព្រះរាជអាជ្ញាម្នាក់ត្រូវតែយកមកអនុវត្ត។

ឃ-រាល់សេចក្ដីសម្រេចទាំងអស់ ដែលមានចែងក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានបញ្ជាក់ មូលហេតុ និង ចុះហត្ថលេខាដោយសាម៉ីខ្លួន ។ ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសេចក្ដី សម្រេចនេះទៅឲ្យប្រធានការិយាល័យរដ្ឋបាល ដែលត្រូវជូនដំណឹងដល់សហ-ព្រះរាជអាជ្ញា។សហព្រះរាជអាជ្ញាត្រូវបន្តកិច្ចដំណើរការនីតិវិធីជាបន្ទាន់ ស្របតាម

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

**វិធាន ៧២: ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត**

១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត ។ ប្រសិនបើការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ រយៈពេលនេះត្រូវបន្ថយ មកត្រឹម ៥(ប្រាំ)ថ្ងៃ វិញ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតម្ខាងទៀត អាចដាក់ជូនឯកសារឆ្លើយតបក្នុង រយៈពេល ១០(ដប់)ថ្ងៃ។ ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណីដែលមានចែងក្នុងអនុវិធាន ៤ (ខ) ខាងក្រោម។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូន សំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬ សេចក្តីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែអនុវត្ត លើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក-សេចក្តីសម្រេចណាមួយដែលអាចនាំឲ្យជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

ខ-ការជូនដំណឹងអំពីបទចោទប្រកាន់ ។ ឬ

គ-ដីកាបង្គាប់ឲ្យចាប់ខ្លួន។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬ រយៈពេល ៣០(សាមសិប)ថ្ងៃ បាន

កន្លងហួស ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម ៖

ក-សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវរៀបចំធ្វើឡើង និង ប្រកាសសាលក្រមជាសម្ងាត់។

ខ-នៅពេលមានការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការសម្រេចសេចក្តី ដែលភាគីនៃសំណុំរឿងមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះតាមវិធានផ្ទៃក្នុងនេះ ត្រូវអនុវត្តដូចខាងក្រោម ៖

(១) ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវជូនព័ត៌មានជាបន្ទាន់ទៅភាគីពាក់ព័ន្ធនឹងរឿងក្តី និង មេធាវីរបស់ពួកគេអំពីថ្ងៃសវនាការ។

(២) សហព្រះរាជអាជ្ញា និងអ្នកតំណាងស្របច្បាប់របស់ភាគីដទៃទៀត ដែលពាក់ព័ន្ធ អាចពិនិត្យ មើលសំណុំរឿងនេះរហូតដល់ថ្ងៃសវនាការ។

(៣) សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀតដែលពាក់ព័ន្ធ អាចដាក់សារណាជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ។ សារណានេះត្រូវ ដាក់បញ្ចូលភ្លាមទៅក្នុងសំណុំរឿងដោយក្រឡាបញ្ជីរបស់អង្គបុរេ-ជំនុំជម្រះ។

(៤) ដោយផ្អែកតាមសំណើរបស់ចៅក្រម ឬ ភាគីណាមួយ អង្គបុរេជំនុំជម្រះអាចសម្រេចថា ផ្នែកទាំងមូល ឬ ផ្នែកណាមួយនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេសក្នុងករណី ដែលរឿងក្តីអាចត្រូវបញ្ចប់ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជាក្នុងករណីបណ្តឹងឧទ្ធរណ៍ ឬ ពាក្យស្នើសុំដែលពាក់ព័ន្ធនឹងយុត្តាធិការ ឬ ការរលត់បណ្តឹងអាជ្ញា ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា សវនាការបែបនេះគឺធ្វើឡើងក្នុងប្រយោជន៍ដើម្បីយុត្តិធម៌ និងមិនប៉ះពាល់ សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការណ៍ការពារណាមួយដែលអនុញ្ញាតដោយតុលាការ។

(៥) ក្នុងពេលសវនាការ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីដទៃទៀតដែលពាក់ព័ន្ធ

អាចធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបបាន ។

គ-នៅក្នុងគ្រប់ករណីទាំងអស់ អង្គបុរេជំនុំជម្រះដោយអំណាចឆន្ទានុសិទ្ធិអាចបង្គាប់ឲ្យភាគី ឬ អ្នកជំនាញ ចូលមកបង្ហាញខ្លួនដោយផ្ទាល់ រួមទាំងការបង្ហាញវត្ថុតាងផង ។

ឃ-សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូប យ៉ាងតិច ។ សេចក្ដីសម្រេចនេះបិទផ្លូវប្ដឹងឧទ្ធរណ៍ ។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសម្លេងគាំទ្រភាគ ច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រមានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ត្រូវមានសុពលភាព ឬ មានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលបម្រុងនឹង ធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត ។ប៉ុន្តែនៅពេលដែលការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន ហើយបើអង្គបុរេជំនុំជម្រះ មិនអាចរកសម្លេងគាំទ្រភាគច្រើនតាមការតម្រូវបានទេ នោះជនត្រូវចោទត្រូវសន្មតថាមានសេរីភាព។

ង-រាល់សេចក្ដីសម្រេចទាំងអស់ដែលមានចែងក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផង ត្រូវមានបញ្ជាក់ពីមូលហេតុ និង ចុះហត្ថលេខាដោយសាមីខ្លួន ។ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសេចក្ដីសម្រេចនេះទៅប្រធានការិយាល័យរដ្ឋបាល ដែលត្រូវជូនដំណឹងដល់សហ-ចៅក្រមស៊ើបអង្កេត ។ លើសពីនេះសេចក្ដីសម្រេច ដែលពាក់ព័ន្ធទៅនឹងករណីដូចមានក្នុងអនុ-វិធាន៤ (ខ) ត្រូវជូនដំណឹងដល់ភាគី។ សហចៅក្រមស៊ើបអង្កេតត្រូវដាក់បញ្ចូលសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅក្នុងសំណុំរឿង និង ត្រូវបន្តកិច្ចដំណើរការនីតិវិធីជាបន្ទាន់ ស្របតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

## វិធាន ៧៣: យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

បន្ថែមពីលើអំណាចវិនិច្ឆ័យសេចក្ដី លើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ រវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្ដីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ច ដើម្បីពិនិត្យលើ៖

ក-បណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងទៅនឹងសេចក្ដីសម្រេច និងកិច្ចស៊ើបសួររបស់សហចៅក្រម

ស៊ើបអង្កេតដូចមានចែងនៅក្នុងវិធាន ៧៤ ។

ខ-ពាក្យសុំមោឃៈភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន ៧៦ និង

គ-បណ្តឹងឧទ្ធរណ៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងវិធាន ១១(៥) និង (៦) វិធាន ៣៥(៦) វិធាន ៣៨(៣) និង វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុងនេះ។

**វិធាន ៧៤: មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ**

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និង ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. គ្មានបណ្តឹងឧទ្ធរណ៍ណាមួយត្រូវធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបានឡើយ ប្រសិនបើបណ្តឹងនេះត្រូវបានពិនិត្យ និង សម្រេចរួចហើយដោយអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមការដោះស្រាយភាពខ្វែងយោបល់គ្នាដែលមានចែងនៅក្នុងវិធាន ៧២។

២. សហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត។

៣. ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេច របស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម ៖

ក-ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ខ-ការបដិសេធពាក្យសុំឲ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

គ-ការបដិសេធពាក្យសុំឲ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក។

ឃ-ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

ង-ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាននេះ។

ច-ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ឆ-ការបដិសេធពាក្យសុំឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃៈភាពកិច្ចស៊ើបសួរណាមួយ ។

ជ- ទាក់ទងទៅនឹងវិធានការការពារ ឬ

ឈ- ការប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៤. ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម ៖

ក-ការបដិសេធពាក្យសុំឲ្យមានកិច្ចស៊ើបសួរណាមួយ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។
ខ-ការមិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
គ-ការបដិសេធពាក្យសុំឲ្យប្រគល់មកវិញនូវទ្រព្យសម្បត្តិដែលចាប់យក។
ឃ-ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។
ង-ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាននេះ ។
ច-ដីកាលើកលែងការចោទប្រកាន់ ក្នុងករណីដែលសហព្រះរាជអាជ្ញាធ្វើបណ្តឹងឧទ្ធរណ៍ដែរ ។
ឆ-ការបដិសេធពាក្យសុំឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះ ដើម្បីមោឃៈភាពកិច្ចស៊ើបសួរណាមួយ។ ឬ
ជ- ទាក់ទងទៅនឹងវិធានការការពារ។

៥. ជនដែលមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីស៊ើបសួរ ដែលបានស្នើសុំឲ្យប្រគល់មកវិញនូវវត្ថុទាំងឡាយណាដែលបានចាប់យក ត្រូវមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធរបស់សហចៅក្រមស៊ើបអង្កេត។

## វិធាន ៧៥: ការដាក់បណ្តឹងឧទ្ធរណ៍ និង សារណាអំពីការធ្វើបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨)

១. លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ គ្រប់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងក្នុងអំឡុងពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬ ដីកា។ មេធាវីរបស់ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ក្នុងនាមជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីបាន។

២. ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប្រគល់ជូនទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវជូនដំណឹងភ្លាមដល់សហចៅក្រមស៊ើបអង្កេត និងត្រូវរក្សាទុកសំណុំឯកសារទាំងអស់នៃបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ ។ ក្រោយពេលទទួលបានបណ្តឹងឧទ្ធរណ៍នេះ ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវទទួលបានការជូនដំណឹងភ្លាម។

៣. ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ទៅក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃគិតពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អំពីសេចក្តីសម្រេច ឬ

ដីកា។ ក្នុងកាលៈទេសៈពិសេស រយៈពេលកំណត់នេះអាចពន្យារបាន ។ ក្រឡាបញ្ជីត្រូវចុះកាលបរិច្ឆេទនៃការទទួលសារណាបណ្តឹងឧទ្ធរណ៍ និង ដាក់សារណាបណ្តឹងឧទ្ធរណ៍ទាំងនោះទៅក្នុងសំណុំរឿងភ្លាម ។ ក្រឡាបញ្ជីត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីផ្សេងៗ និងបញ្ជូនច្បាប់ចម្លងនៃសារណាបណ្តឹងឧទ្ធរណ៍នោះទៅឲ្យពួកគេ។

៤. ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុ និង អង្គច្បាប់ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដោយមានភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងនោះ ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចលើកក្នុងពេលសវនាការ បញ្ហាអង្គហេតុឬអង្គច្បាប់ដែលមិនមានចែងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ឡើយ ។

## វិធាន ៧៦: បណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ

១. ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានផ្នែកណាមួយ ត្រូវបានចាត់ទុកជាមោឃៈ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងឡាយអំពីបញ្ហានេះ ។ ដោយផ្អែកតាមអនុវិធាន ៦ ខាងក្រោមនេះ សហចៅក្រមស៊ើបអង្កេតត្រូវដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅ អង្គបុរេជំនុំជម្រះស្នើសុំឲ្យធ្វើមោឃភាព ។ កិច្ចស៊ើបសួរអាចបន្តនៅក្នុងអំឡុងពេលនេះ។

២. ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយ ត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេតដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឲ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬ បដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ។

៣. ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវចុះបញ្ជីពាក្យសុំភ្លាម ។ នៅពេលដែលសហចៅក្រម-ស៊ើបអង្កេតសម្រេចទទួលពាក្យសុំសហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងទៅឲ្យអង្គបុរេជំនុំជម្រះ។

៤. អង្គបុរេជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពនេះមិនអាចទទួលយកបាន ប្រសិនបើពាក្យសុំមិនបានបង្ហាញហេតុផលគ្រប់គ្រាន់ ពាក្យសុំនេះមានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ

នេះគ្មានមូលដ្ឋានច្បាស់លាស់។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្តឹងឧទ្ធរណ៍។ នៅពេលដែលអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងសុំមោឃៈភាពសំណុំរឿង ត្រូវបញ្ជូនត្រឡប់ទៅឲ្យសហចៅក្រមស៊ើប-អង្កេតវិញ។

៥. នៅពេលអង្គបុរេជំនុំជម្រះសម្រេចទុកជាមោឃៈកិច្ចស៊ើបសួរណាមួយ អង្គបុរេជំនុំជម្រះត្រូវសម្រេចថា តើមោឃភាពនោះមានប៉ះពាល់ដល់កិច្ច ឬដីកាដទៃទៀតដែរឬទេ។ នៅពេលដែលផ្នែកណាមួយនៃកិច្ច ឬ ដីកា ត្រូវបានចាត់ទុកជាមោឃៈ ផ្នែកនោះត្រូវតែលុបចោលបន្ទាប់ពីបានធ្វើច្បាប់ចម្លងមួយច្បាប់ដែលមានការបញ្ជាក់ថា បានចម្លងតាមច្បាប់ដើម ។ កិច្ច ឬ ដីកាដែលត្រូវបានចាត់ទុកជាមោឃៈទាំងអស់ និង ឯកសារដែលមានបញ្ជាក់ថា បានចម្លងតាមច្បាប់ដើម ត្រូវតែដកចេញពីសំណុំរឿង និងត្រូវតម្កល់ទុកដោយក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ។ បន្ទាប់ពីប្រកាសមោឃៈភាព ឬ ការលុបចោលនេះ អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសំណុំរឿងត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ។ ការដកយកព័ត៌មានណាមួយប្រឆាំងនឹងភាគីចេញពីកិច្ច ឬ ដីកាដែលត្រូវចាត់ទុកជា មោឃៈបែបនេះ ឬ ពីផ្នែកទាំងឡាយដែលត្រូវបានលុបចោលនោះ ត្រូវបានហាមឃាត់។ ស្របតាមវិធាន ៦ និងវិធាន ៣៥ នៃវិធានផ្ទៃក្នុងនេះ ចៅក្រមសហ-ព្រះរាជអាជ្ញា ឬ មេធាវី ដែលរកឃើញថាមានកំហុសពាក់ព័ន្ធ ទៅនឹងអំពើទាំងនេះត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ។

៦. ភាគីណាមួយដែលផលប្រយោជន៍របស់ខ្លួន ត្រូវបានប៉ះពាល់ដោយកិច្ចស៊ើបសួរដែលគ្មានសុពលភាពអាចលះបង់សិទ្ធិស្នើសុំមោឃភាពបាន ។ ការធ្វើដូចនេះ ផ្តល់និយតភាពដល់កិច្ចដំណើរការនីតិវិធី ។ សហចៅក្រមស៊ើបអង្កេតត្រូវដាក់ពាក្យលះបង់សិទ្ធិបែបនេះទៅក្នុងសំណុំរឿង។ នៅពេលដែលភាគីដែលស្នើសុំនោះមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវកោះហៅមេធាវីនោះយ៉ាងហោចណាស់ ៥(ប្រាំ)ថ្ងៃមុនថ្ងៃកត់ត្រាទុកពាក្យលះបង់សិទ្ធិនេះ ដើម្បីឲ្យមេធាវីអាចពិនិត្យសំណុំរឿងបាន។

៧. លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលឡើយ។

## វិធាន ៧៧: នីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ និងពាក្យសុំនៅអង្គបុរេជំនុំជម្រះ

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០០៨ និងធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០)

១. ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវរក្សាទុកសៀវភៅចុះបណ្តឹងឧទ្ធរណ៍ និង ពាក្យសុំ

ទាំងអស់ ដែលមានចែងនៅក្នុងអនុវិធាន ៧៣ ចំណុច ក និង ខ និងវិធាន៧៧*ស្ទួន*។ បណ្តឹងឧទ្ធរណ៍ដែលមានចែងនៅក្នុងចំណុច គ នៃវិធាន ៧៣ ត្រូវដាក់ទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះដែលត្រូវរក្សានូវសៀវភៅចុះបណ្តឹងឧទ្ធរណ៍ ហើយត្រូវជូនដំណឹងដល់ស្ថាប័នដែលចេញសេចក្តីសម្រេច និង ស្នើសុំស្ថាប័ននេះផ្តល់រាល់ឯកសារពាក់ព័ន្ធ ប្រសិនបើចាំបាច់។

២. ក្រោយពេលទទួលបាននូវបណ្តឹងឧទ្ធរណ៍ ឬ សេចក្តីសម្រេចដែលមានចែងនៅក្នុងវិធាន ៧៦-៣ ក្រឡាបញ្ជី របស់សហចៅក្រមស៊ើបអង្កេត ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត និងបញ្ជូនសំណុំរឿង ឬ ច្បាប់ចម្លង ត្រឹមត្រូវទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ។ នៅពេលច្បាប់ចម្លងត្រឹមត្រូវនៃសំណុំរឿងត្រូវបានធ្វើឡើងដើម្បីបញ្ជូនទៅអង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវរក្សាសំណុំរឿងច្បាប់ដើម។

៣. (ក) ប្រធានអង្គបុរេជំនុំជម្រះ ត្រូវផ្ទៀងផ្ទាត់ថាសំណុំរឿងនោះ មានភាពពេញលេញ និងកំណត់កាលបរិច្ឆេទសវនាការ ។

(ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាន នៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

(គ) ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ភាគី និងមេធាវីរបស់ពួកគេ អំពីកាលបរិច្ឆេទនៃសវនាការ ឬ ការសម្រេចអំពីដំណើរការនីតិវិធីដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលដាក់ដោយភាគីតែប៉ុណ្ណោះ ។

៤. សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីអាចសុំមើលសំណុំរឿងរហូតដល់ថ្ងៃសវនាការ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីត្រូវដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ។ ក្រឡាបញ្ជីត្រូវចុះកាលបរិច្ឆេទនៃការទទួលយកឯកសារ និង ដាក់ឯកសារទាំងនោះចូលទៅក្នុងសំណុំរឿងភ្លាម។

៥. សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវធ្វើឡើងជាអសាធារណៈ លើកលែងតែមានចែងផ្សេងក្នុងអនុ-វិធាន ៦។ ការចូលរួមរបស់ចៅក្រមពីចម្ងាយអាចត្រូវបានរៀបចំធ្វើឡើង តាមការចាំបាច់។

៦. តាមសំណើរបស់ចៅក្រមណាម្នាក់ ឬរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬ មួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេសនៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្ដីសម្រេចរបស់ខ្លួន ដូចជាពាក្យបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ ឬ មូលហេតុដែលនាំឲ្យរលត់បណ្ដឹងអាជ្ញា បើអង្គបុរេជំនុំជម្រះយល់ឃើញថាដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ។

៧. ចៅក្រមបម្រុងនៃអង្គបុរេជំនុំជម្រះត្រូវមានវត្តមាននៅគ្រប់ដំណាក់កាលនៃសវនាការ នៅពេលដែលប្រធានអង្គបុរេជំនុំជម្រះពិចារណាឃើញថា សវនាការនោះអាចត្រូវប្រើប្រាស់ពេលវេលាយូរ ជាពិសេសនៅក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ ចៅក្រមបម្រុងនេះ មិនមានសិទ្ធិក្នុងការបញ្ចេញទស្សនៈ ឬ ធ្វើការសម្រេចសេចក្ដីណាមួយឡើយ លើកលែងតែ និង រហូតដល់ចៅក្រមបម្រុងនេះត្រូវបានតែងតាំងឲ្យជំនួសចៅក្រមពេញសិទ្ធិ។

៨. ក្នុងករណីអវត្តមានចៅក្រមពេញសិទ្ធិណាម្នាក់ ប្រធាននៃអង្គបុរេជំនុំជម្រះ បន្ទាប់ពីបានពិគ្រោះ-យោបល់ជាមួយចៅក្រមដទៃទៀត អាចសម្រេចអោយលើកពេលសវនាការ ឬ តែងតាំងចៅក្រមបម្រុងអោយជំនួសកន្លែងរបស់ចៅក្រមដែលអវត្តមាន ដើម្បីអោយនីតិវិធីអាចបន្តទៅបាន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលចៅក្រមពេញសិទ្ធិដែលអវត្តមាន មានលទ្ធភាពបំពេញការងារវិញ អង្គបុរេជំនុំ-ជម្រះអាចសម្រេចជំនួសចៅក្រមបម្រុង ដោយចៅក្រមពេញសិទ្ធិវិញ បន្ទាប់ពីបានពិចារណាលើកត្តាទាំងអស់ ដែលពាក់ពន្ធ័ទៅនឹងរឿងក្ដី និង បន្ទាប់ពីខ្លួនយល់ឃើញថា ចៅក្រមពេញសិទ្ធិ បានទទួលដំណឹងយ៉ាងពេញលេញអំពីការវិវត្តនៃរឿងក្ដីនោះ ក្នុងអំឡុងពេលអវត្តមានរបស់ខ្លួន។

៩. ក្នុងករណីអវត្តមានប្រធានអង្គបុរេជំនុំជម្រះ និង ក្នុងស្ថានភាពដែលសវនាការអាចបន្តនីតិវិធីបាន ចៅក្រម ជាតិដែលមានអាយុចំណាស់ជាងគេ ត្រូវធ្វើជាប្រធានដឹកនាំសវនាការដោយស្វ័យប្រវត្តិ ។ នៅក្នុងករណីនេះ ចៅក្រមបម្រុងជាតិត្រូវចូលជំនួសតំណែងដែលនៅទំនេររហូតដល់ចប់សវនាការនៃរឿងក្ដីនោះ លើកលែងតែករណីដែលចែងក្នុងអនុវិធាន ៨ ខាងលើ។

១០. ប្រធានអង្គបុរេជំនុំជម្រះ ត្រូវចាត់តាំងចៅក្រមជាតិមួយរូប និង ចៅក្រមអន្តរជាតិមួយរូបជាសហចៅក្រមរបាយការណ៍។ សហចៅក្រមរបាយការណ៍ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរដែលត្រូវបង្ហាញអង្គហេតុ ដែលមានបញ្ហា និង ការលម្អិតនៃសេចក្ដីសម្រេចដែលត្រូវប្ដឹងឧទ្ធរណ៍ ហើយ

របាយការណ៍នេះត្រូវដាក់ចូលនៅក្នុងសំណុំរឿង ។ បន្ទាប់ពីសហចៅក្រមរបាយការណ៍បានអានរបាយការណ៍ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគី អាចធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយសង្ខេប។ អង្គជំនុំជម្រះអាចបង្គាប់ឲ្យបុគ្គលទាំងឡាយចូលរួមដោយផ្ទាល់ ក៏ដូចជាការផ្តល់នូវវត្ថុតាង។

១១. ដោយរង់ចាំលទ្ធផលនៃនីតិវិធីរបស់អង្គបុរេជំនុំជម្រះក្រោមវិធាននេះ និង លើកលែងតែអង្គបុរេជំនុំជម្រះ បង្គាប់ផ្សេងពីនេះ សហចៅក្រមស៊ើបអង្កេត អាចបន្តការស៊ើបសួររបស់ខ្លួននៅពេលណាដែលអាចធ្វើទៅបាន។

១២. នៅពេលដែលសវនាការត្រូវបានបញ្ចប់ អង្គបុរេជំនុំជម្រះត្រូវពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្តី។ អ្នកបកប្រែអាចត្រូវបានអនុញ្ញាតឲ្យចូលរួម ដើម្បីជួយសម្របសម្រួលដល់ការពិភាក្សា។

១៣. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម ៖

ក-ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះត្រូវតម្កល់ទុកជាបានការ។

ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតប្រសិន បើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

១៤. សេចក្តីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង ភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធី ជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

១៥. នៅពេលដែលសហចៅក្រមស៊ើបអង្កេត បង្គាប់ឲ្យដោះលែងជនត្រូវចោទដែលស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ឬ សម្រេចលើកលែងការចោទប្រកាន់ ជនត្រូវចោទត្រូវដោះលែង លើកលែងតែប្រធាន

អង្គបុរេជំនុំជម្រះ សម្រេចផ្សេងពីនេះ តាមសំណើរបស់សហព្រះរាជអាជ្ញា ។ សំណើសុំផ្អាកការដោះលែងជនជាប់ឃុំរបស់សហព្រះរាជអាជ្ញា ត្រូវដាក់ទៅប្រធានអង្គបុរេជំនុំជម្រះក្នុងអំឡុងពេល២៤(ម្ភៃបួន)ម៉ោង គិតពីពេលទទួលដំណឹងនេះ ដោយភ្ជាប់ជាមួយឯកសារថតចម្លង នៃពាក្យបណ្ដឹងប្រឆាំងនឹងដីកាដោះលែងជនត្រូវចោទ។ សហព្រះរាជអាជ្ញា ត្រូវដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដោះលែងជនត្រូវចោទ ដោយភ្ជាប់ជាមួយនឹងឯកសារចម្លងនៃសំណើសុំផ្អាកការដោះលែងទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើប-អង្កេត ។ចំពោះសំណើសុំនេះប្រធានអង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងកំឡុងពេល ៤៨(សែសិបប្រាំបី)ម៉ោង ដែលក្នុងកំឡុងពេលនេះ ដីការបស់សហចៅក្រមស៊ើបអង្កេតត្រូវផ្អាកការអនុវត្តសិន។ ប្រសិនបើប្រធានអង្គបុរេជំនុំជម្រះខកខានមិនបានសម្រេចចំពោះសំណើសុំនេះ ក្នុងរយៈពេលកំណត់នេះទេ ឬ បដិសេធសំណើសុំផ្អាកដីការបស់សហចៅក្រមស៊ើបអង្កេត នោះជនត្រូវចោទត្រូវតែដោះលែងឲ្យមានសេរីភាពភ្លាម។ នៅពេលដែលប្រធានអង្គបុរេជំនុំជម្រះសម្រេចឲ្យផ្អាកដីការបស់សហចៅក្រមស៊ើបអង្កេត ជនត្រូវចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ អង្គបុរេជំនុំជម្រះសម្រេចសេចក្ដីលើពាក្យបណ្ដឹងឧទ្ធរណ៍ ។ អង្គបុរេជំនុំជម្រះត្រូវសម្រេចលើពាក្យបណ្ដឹងឧទ្ធរណ៍នេះក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីក្រឡាបញ្ជីរបស់អង្គ-បុរេជំនុំជម្រះទទួលបានសំណុំរឿង ។ ប្រសិនបើហួសរយៈពេលដែលបានកំណត់ ជនត្រូវចោទត្រូវតែដោះលែងឲ្យមានសេរីភាពលើកលែងតែមានកាលៈទេសៈដែលមិនអាចជៀសវាងបាន។

## វិធាន ៧៧ ស្ទួន: នីតិវិធីបណ្ដឹងឧទ្ធរណ៍សង្ខេប

(ធ្វើវិសោធនកម្មថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១០)

១. បណ្ដឹងឧទ្ធរណ៍ទាក់ទងទៅនឹងភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៧៤.(២) ៧៤(៣)(ឈ) និង៧៤ (៤)(ខ) ត្រូវតែពិចារណាឲ្យបានឆាប់រហ័ស ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ដូចមានចែងក្នុងអនុវិធាន ២ នៃវិធាននេះ។

២. ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសេចក្ដីសំរេចអំពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ម្ចាស់បណ្ដឹងឧទ្ធរណ៍ ត្រូវដាក់បណ្ដឹងឧទ្ធរណ៍នេះដោយមានបញ្ជាក់អំពីមូលហេតុដែលថា សហចៅក្រមស៊ើបអង្កេតមានការភន្ដ័ច្រលំលើអង្គហេតុ និង / ឬ អង្គច្បាប់ក្នុងការសម្រេចអំពី ភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះដោយអនុលោមតាមវិធាន ២៣ស្ទួន។ ម្ចាស់បណ្ដឹងឧទ្ធរណ៍អាចភ្ជាប់ជាមួយនូវឯកសារដែលគាំទ្របណ្ដឹងឧទ្ធរណ៍នោះ។ ការពន្យាពេលពុំត្រូវបានអនុញ្ញាតឡើយ។ សារណាតបត្រូវដាក់ក្នុងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ទៅភាគីដ៏ទៃទៀត។ ការឆ្លើយតបទៅនឹងសារណាតបពុំត្រូវបានអនុញ្ញាតឡើយ។ សេចក្ដីសំរេចរបស់អង្គបុរេជំនុំជម្រះ ត្រូវបិទផ្លូវតវ៉ា។

**វិធាន ៧៨: ការបោះពុម្ពផ្សាយសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ**

រាល់សេចក្ដីសម្រេចដែលមានសំលេងគាំទ្រគ្រប់គ្រាន់ និង រាល់សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ រួមទាំងមតិជំទាស់ផងត្រូវបោះពុម្ពផ្សាយទាំងស្រុង លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬ ការស៊ើបសួរ។

**ខ-នីតិវិធីនៅអង្គជំនុំជម្រះសាលាដំបូង**

**វិធាន ៧៩: បទប្បញ្ញត្តិទូទៅ**

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ និង ថ្ងៃ០៥ ខែកញ្ញា ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១. អង្គជំនុំជម្រះសាលាដំបូងទទួលបណ្ដឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រម-ស៊ើបអង្កេត ឬ តាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

២. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្ដឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះច្រើន ដែលមានការជាប់ពាក់ព័ន្ធគ្នា អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាមួយឲ្យដាក់បញ្ចូលគ្នានូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាំងអស់នោះ។

៣. ចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូងត្រូវមានវត្តមាននៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។ ចៅក្រមបម្រុងនេះមិនមានសិទ្ធិក្នុងការបញ្ចេញទស្សនៈ ឬ សម្រេចអ្វីមួយឡើយ លើកលែងតែ និងរហូតដល់ពេល ដែលត្រូវបានតែងតាំងឲ្យជំនួសចៅក្រមពេញសិទ្ធិណាម្នាក់ ។ ប្រសិនបើចៅក្រមបម្រុងមិនអាចចូលរួមផ្នែកណាមួយនៃដំណើរការនីតិវិធី រួមទាំងផ្នែកណាមួយនៃការជំនុំជម្រះ ដោយសារមូលហេតុជម្ងឺ ឬ មូលហេតុបន្ទាន់ផ្ទាល់ខ្លួន អង្គជំនុំជម្រះអាចបន្តនីតិវិធីបាន ។

៤. ក្នុងករណីអវត្តមានចៅក្រមពេញសិទ្ធិណាម្នាក់ ប្រធានរបស់អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រមដទៃទៀត អាចសម្រេចឲ្យលើកពេលសវនាការ ឬ តែងតាំងចៅក្រមបម្រុងឲ្យជំនួសកន្លែងរបស់ចៅក្រមដែលអវត្តមានសំរាប់កិច្ចបន្តនៃនីតិវិធី។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលចៅក្រមពេញសិទ្ធិដែលអវត្តមាន មានលទ្ធភាពអាចត្រឡប់មកបំពេញការងារវិញ អង្គ-ជំនុំជម្រះសាលាដំបូងអាចសម្រេចជំនួសចៅក្រមបម្រុងដោយចៅក្រមពេញសិទ្ធិវិញ បន្ទាប់ពីបានពិចារណាលើកត្តាទាំងអស់ដែលពាក់ពន្ធ័ ទៅនឹងរឿងក្ដី និងបន្ទាប់ពីយល់ឃើញថា ចៅក្រមពេញសិទ្ធិដែលត្រលប់មកវិញបានទទួលដំណឹងយ៉ាងពេញលេញ អំពីការវិវត្តនៃរឿងក្ដីនោះក្នុងអំឡុងពេលដែលខ្លួនអវត្តមាន។

៥. ក្នុងករណីអវត្តមានប្រធានអង្គជំនុំជម្រះសាលាដំបូង និងនៅក្នុងស្ថានភាពដែលសវនាការអាចបន្ត ធ្វើបាន ចៅក្រមជាតិដែលមានអាយុចំណាស់ជាងគេ ត្រូវធ្វើជាប្រធានដឹកនាំសវនាការដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ចៅក្រមបម្រុងជាតិត្រូវចូលជំនួសតំណែងដែលនៅទំនេររហូតដល់ចប់សវនាការនៃរឿងក្តី នោះ អនុលោមតាមខ្លឹមសារ ដូចមានចែងក្នុងអនុវិធាន ៤ ខាងលើ។

៦. ការពិភាក្សាដេញដោលរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវប្រព្រឹត្តិទៅជាសាធារណៈ។

ក. ការិយាល័យរដ្ឋបាលត្រូវធានាការផ្សព្វផ្សាយជាសាធារណៈនៃសវនាការ តែត្រូវគោរពដល់វិធានការការពារនានា ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។

ខ. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាភាពជាសាធារណៈនោះអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់វិធានការការពារ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសម្រេចដោយមានសំអាងហេតុបង្គាប់ថាផ្នែកណាមួយ ឬ ទាំងស្រុងនៃសវនាការត្រូវធ្វើជាសម្ងាត់។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវប្តឹងសាទុក្ខ។

គ.នៅពេលដែលគោលបំណងនៃដំណើរការនីតិវិធីជាសម្ងាត់អាចត្រូវបានបង្កឲ្យមានផលប៉ះពាល់ដោយការចូលរួមរបស់ភាគី អង្គជំនុំជម្រះ បន្ទាប់ពីពិគ្រោះយោបល់ជាមួយភាគីតាមសេចក្តីសម្រេចដោយមានសំអាងហេតុ អាចកម្រិតការចូលរួមរបស់ភាគីត្រឹមតែភាគីណាដែលចាំបាច់ដល់ដំណើរការនីតិវិធី និងអ្នកតំណាងចាំបាច់របស់ពួកគេប៉ុណ្ណោះ។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវប្តឹងសាទុក្ខ។

ឃ.នៅក្នុងគ្រប់ករណីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រកាសសាលក្រមរបស់ខ្លួននៅក្នុងសវនាការជាសាធារណៈ។

៧. ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការប្រជុំរៀបចំសវនាការ ប្រសិនបើយល់ឃើញថាចាំបាច់។ កិច្ចប្រជុំនោះ ត្រូវធ្វើឡើងជាសម្ងាត់លើកលែងតែអង្គជំនុំជម្រះសាលាដំបូង សម្រេចផ្សេងពីនេះ ។ គោលបំណងនៃការប្រជុំនេះ នឹងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរមតិយោបល់គ្នារវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការបឋមសវនាការនៃអង្គសេចក្តី និងពិនិត្យឡើងវិញនូវរឿងក្តី ដោយអនុញ្ញាតឲ្យជនជាប់ចោទ លើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងរឿងក្តីនោះ រួមទាំងស្ថានភាពរូបកាយ និងស្មារតី ។

៨. ក្នុងករណីចាំបាច់ ការប្រជុំនេះអាចប្រព្រឹត្តទៅដោយមានការចូលរួមពីមេធាវី តាមរយៈទូរគមនាគមន៍ និង វីដេអូ។ អង្គជំនុំជម្រះ ក៏អាចអញ្ជើញអ្នកតំណាងការិយាល័យរដ្ឋបាល ដែលក្នុងនោះរួមទាំងតំណាងមកពីផ្នែកផ្សេងៗ ឬ អង្គភាពផ្សេងៗ របស់តុលាការឲ្យចូលរួមផងដែរ។

## វិធាន៨០: ការរៀបចំសវនាការ

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០០៨ **និងវិសោធនកម្មនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. សហព្រះរាជអាជ្ញាត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីឈ្មោះសាក្សី រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិណាមួយដែលមានចែងក្នុងវិធាន២៤(២) និងអ្នកជំនាញដែលខ្លួនមានបំណងកោះហៅ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនឯកសារថតចម្លងមួយច្បាប់ទៅឲ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ ។

២. នៅពេលដែលជនជាប់ចោទ និង/ឬ ក្រុមរួមគ្នានៃដើមបណ្តឹងរដ្ឋប្បវេណី មានបំណងកោះហៅសាក្សីណាម្នាក់ ដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា ជនជាប់ចោទ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែម រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិដែលមានចែងក្នុងវិធាន២៤(២) ដល់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សី។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនបញ្ជីឈ្មោះថតចម្លងទៅឲ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ ។

៣. អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យភាគីទាំងឡាយដាក់ឯកសារតាមពេលកំណត់មុនពេលសវនាការបឋម រួមទាំងឯកសារខាងក្រោម៖

ក. បន្ថែមទៅនឹងបញ្ជីឈ្មោះសាក្សី ដែលមានយោងក្នុងវិធាន៨០ នៃវិធានផ្ទៃក្នុង៖

១.សេចក្តីសង្ខេបអង្គហេតុ ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្ម។ អនុលោមតាមវិធានការការពារណាមួយ ដែលអាចត្រូវចេញ សេចក្តីសង្ខេបគួរមានលក្ខណៈរៀបរាប់គ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតវាយតម្លៃខ្លស់ និងយល់បាននូវលក្ខណៈ និងខ្លឹមសារនៃការធ្វើសក្ខីកម្ម ដែលបានស្នើសុំធ្វើនោះ។

២.ចំណុចនានានៃការចោទប្រកាន់ ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្មរួមទាំងកថាខណ្ឌ និងបទចោទជាក់លាក់។ និង

៣.ការប៉ាន់ស្មានអំពីរយៈពេល ដែលតម្រូវឲ្យសាក្សីម្នាក់ៗធ្វើសក្ខីកម្ម។

ខ. បញ្ជីវត្ថុតាង ដែលភាគីទាំងឡាយមានបំណងប្រគល់ឲ្យសម្រាប់រឿងក្តីនោះដោយមានពិពណ៌នាត្រួសៗអំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាំងទាំងនោះ ។

គ. ការបង្ហាញអំពីអង្គច្បាប់ ដែលភាគីទាំងឡាយមានបំណងលើកឡើងនៅក្នុងសវនាការបឋម ប្រសិនបើមាន។

ឃ.បញ្ជីឯកសារថ្មីដោយមានភ្ជាប់សេចក្តីសង្ខេបពីខ្លឹមសារនៃឯកសារទាំងនោះ ដែលភាគីមានបំណងចង់ដាក់ចំពោះមុខអង្គជំនុំជម្រះ និងបញ្ជីឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿងដែលបានកំណត់អត្តសញ្ញាណសមស្រប និង

ង. បញ្ជីនៃអង្គហេតុដែលមិនមានការជំទាស់ ដោយយោងទៅភស្តុតាងដែលពាក់ព័ន្ធផង។

៤ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ថា ការជំទាស់ណាមួយទៅនឹងការទទួលយកវត្ថុតាង ឬឯកសារដូចបានកំណត់អត្តសញ្ញាណដោយភាគី អនុលោមតាមវិធាននេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរបន្ទាប់ពីសវនាការបឋម ដោយស្ថិតក្នុងរយៈពេលមួយដែលបានកំណត់។ រយៈពេលនេះ ត្រូវអនុញ្ញាតផ្តល់ពេលវេលាសមស្រប សម្រាប់ភាគីដើម្បីពិនិត្យបញ្ជីនេះ ដោយអនុលោមទៅតាមវិធាននេះ។

៥. កាលបរិច្ឆេទនៃសវនាការត្រូវកំណត់ដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ដោយគិតពិចារណាអំពីរយៈពេលកំណត់សម្រាប់ការជូនដំណឹង និងដីកាបង្គាប់ឲ្យចូលខ្លួន ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។

៦. ភាគីត្រូវតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីកាលបរិច្ឆេទនៃសវនាការ ដោយក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យបានឆាប់ដែលអាចធ្វើទៅបាន។ ការជូនដំណឹងនេះត្រូវចាត់ទុកជាការបង្គាប់ឲ្យចូលខ្លួន ដែលមានសុពលភាព។

**វិធាន ៨០ស្ទួន: សវនាការបឋម**

(អនុម័តថ្ងៃទី ០១ ខែកុម្ភៈ និងវិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ **និងវិសោធនកម្មនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. ការជម្រះសេចក្តីចាប់ផ្តើមជាមួយនឹងសវនាការបឋម ។ ប្រធានត្រូវធ្វើការប្រកាសបើកសវនាការបឋម ។

២. នៅក្នុងពេលសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាអំពីបញ្ជីឈ្មោះសាក្សី និង

អ្នកជំនាញដែលដាក់ជូនដោយភាគី ស្របតាមវិធានផ្ទៃក្នុងនេះ ។ នៅពេលអង្គជំនុំជម្រះសាលាដំបូង ពិចារណា ឃើញថាការស្តាប់សាក្សី ឬ អ្នកជំនាញដែលត្រូវបានស្នើសុំនឹងមិននាំមកនូវដំណើរការល្អនៃការ ស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឱ្យកោះហៅបុគ្គលនោះ។

៣. អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាបញ្ហាទាក់ទងទៅនឹងវិធាន៨៩។

៤. អង្គជំនុំជម្រះសាលាដំបូង អាចណែនាំសហមេធាវីនាំមុខឱ្យផ្តល់ខ្លឹមសារជាក់លាក់ស្តីពីសំណាង ដែលខ្លួនមានបំណងស្នើសុំនៅក្នុងបណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសម្ភារភាព ក្នុង អំឡុងពេលមួយជាក់លាក់ដែលបានកំណត់ដោយអង្គជំនុំជម្រះដោយអនុលោមតាមវិធាន២៣ស្ទួនបួន (៣)(ខ)។ នៅដំណាក់កាលក្រោយមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ សហមេធាវីនាំមុខក្នុងការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសម្ភារភាព។

៥. ការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសម្ភារភាព អាចមានភាពខុសគ្នាពី ការទាមទារលើកដំបូង តាមភាពចាំបាច់ ប៉ុន្តែគ្រប់ករណីទាំងអស់ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីខ្លឹមសារនៃ ការទាមទារ និងរបៀបនៃការអនុវត្តសំណងនីមួយៗ។

### វិធាន ៨១: ការចូលខ្លួនរបស់ជនជាប់ចោទ និងមេធាវីការពារក្តី

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ និងថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ **និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១**)

១. ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ លើកលែងតែមានបញ្ញត្តិផ្សេង ចែងក្នុងវិធាននេះ។

២. ប្រសិនបើជនជាប់ចោទដែលស្ថិតនៅក្រៅឃុំមិនព្រមចូលរួមក្នុងសវនាការ ដែលរៀបចំដោយអង្គ-ជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាសម្រេចពន្យាពេលសវនាការជាបណ្តោះ អាសន្ន ហើយចេញដីកាបង្គាប់ឱ្យនាំខ្លួន ឬ ដីកាបង្គាប់ឱ្យចាប់ខ្លួន តាមករណីសមស្រប ដោយអនុលោម តាមវិធានផ្ទៃក្នុងនេះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់កាលបរិច្ឆេទសវនាការជាថ្មី។ ជនជាប់ចោទត្រូវ នាំមកកាន់មន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញ រហូតដល់ពេលជនជាប់ចោទរូបនេះត្រូវបាននាំមកបង្ហាញ ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើការឃុំខ្លួនជនជាប់ចោទនោះ ស្របតាម វិធាន ៦៣។

៣. នៅពេលដែលជនជាប់ចោទបដិសេធមិនចូលរួមក្នុងនីតិវិធី ជនជាប់ចោទនឹងត្រូវនាំខ្លួនមកកាន់អង្គ-ជំនុំជម្រះសាលាដំបូងដោយកំលាំងសារធារណៈប្រសិនបើចាំបាច់ នៅពេលនោះជនជាប់ចោទត្រូវតែបានជូនដំណឹងអំពីសិទ្ធិ ដែលត្រូវមានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ សិទ្ធិទទួលបានការចាត់តាំងមេធាវីដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ឬ សិទ្ធិការពារក្តីដោយខ្លួនឯង។

៤. ក្រោយពេលបង្ហាញខ្លួនជាលើកដំបូង និង បានទទួលដីកាកោះដោយត្រឹមត្រូវសម្រាប់ចូលរួមក្នុងសវនាការជាបន្តបន្ទាប់ ប្រសិនបើជនជាប់ចោទនៅតែបន្តបដិសេធ ឬ ខកខានមិនបានចូលរួម ឬ ត្រូវបានបណ្តេញចេញពីកិច្ចដំណើរការនីតិវិធីដោយស្របទៅតាមវិធានផ្ទៃក្នុងនេះ កិច្ចដំណើរការនីតិវិធីអាចបន្តទៅបានដោយអវត្តមានរបស់ជនជាប់ចោទរូបនោះ។ ក្នុងករណីនេះ ជនជាប់ចោទអាចត្រូវបានការពារនៅក្នុងកិច្ចដំណើរការនីតិវិធីដោយមេធាវីរបស់ខ្លួន។ នៅពេលដែលជនជាប់ចោទបដិសេធមិនធ្វើការជ្រើសរើសមេធាវី អង្គជំនុំជម្រះសាលាដំបូង ត្រូវបង្គាប់អោយមានមេធាវីការពារជនជាប់ចោទ និងស្នើអោយអង្គភាពគាំពារការការពារក្តី ធ្វើការចាត់តាំងមេធាវីសម្រាប់ជនជាប់ចោទពីបញ្ជីដែលមានចែងនៅក្នុងវិធាន ១១។

៥. នៅពេលដែលមានមូលហេតុសុខភាព ឬ មូលហេតុធ្ងន់ធ្ងរដ៏ទៃទៀត ជនជាប់ចោទ មិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែ រូបកាយនិងស្មារតីសមស្រប អាចចូលរួមក្នុងដំណើរការនីតិវិធីបាន អង្គជំនុំជម្រះ អាចបន្តនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ ឬ នៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយ ដែលបណ្តាលឲ្យមានការពន្យាពេលយ៉ាងយូរ ហើយ នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ អង្គជំនុំជម្រះបង្គាប់ថា ការចូលរួមរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែធ្វើឡើងតាមមធ្យោបាយសោតទស្សន៍សមស្រប។ ក្នុងករណីទាំងនេះ ជនជាប់ចោទអាចត្រូវបានការពារនៅក្នុងកិច្ចដំណើរការនីតិវិធីដោយមេធាវីរបស់ខ្លួន។ នៅពេលដែលជនជាប់ចោទ បដិសេធមិនធ្វើការជ្រើសរើសមេធាវី អង្គជំនុំជម្រះសាលាដំបូង ត្រូវបង្គាប់អោយមានមេធាវីការពារជនជាប់ចោទ និងស្នើអោយអង្គភាពគាំពារការការពារក្តីធ្វើការចាត់តាំងមេធាវី សម្រាប់ជនជាប់ចោទពីបញ្ជីដែលមានចែងនៅក្នុងវិធាន ១១ នៃវិធានផ្ទៃក្នុងនេះ ។

៦. ក្នុងករណីដែលជនជាប់ចោទមិនអាចបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវការចាំបាច់សួរចម្លើយជនជាប់ចោទ អង្គជំនុំជម្រះ អាចបង្គាប់ឲ្យជនជាប់ចោទផ្តល់ចម្លើយនៅនឹងកន្លែងដែលជនជាប់ចោទស្ថិតនៅ។ ការសួរចម្លើយនៅទីកន្លែងនោះ ត្រូវប្រព្រឹត្តទៅដោយមានវត្តមានសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រឡាបញ្ជី និងមេធាវីរបស់ជនជាប់ចោទ

លើកលែងតែជនជាប់ចោទបោះបង់សិទ្ធិដែលត្រូវមានជំនួយពីមេធាវី។ ការសាកសួរយកចម្លើយ ត្រូវតែកត់ត្រាចូលក្នុងកំណត់ហេតុសវនាការ។

៧. នៅពេលមេធាវីរបស់ជនជាប់ចោទមិនមានវត្តមាន ក្នុងអំឡុងពេលសវនាការ ដោយគ្មានការបញ្ជាក់អំពីមូលហេតុ អង្គជំនុំជម្រះសាលាដំបូង អាចពន្យារពេលសវនាការ ឬ បើសិនជាជនជាប់ចោទស្នើសុំជំនួយមេធាវី អាចស្នើសុំឲ្យអង្គភាពគាំទ្រការការពារក្តី ចាត់តាំងជាបណ្តោះអាសន្នជូនជនជាប់ចោទនោះនូវមេធាវីដែលមានឈ្មោះក្នុងបញ្ជីដែលមានចែងក្នុងវិធាន១១ ។ នៅពេលមេធាវីនោះមានពេលគ្រប់គ្រាន់ដើម្បីសិក្សាសំណុំរឿងរួចហើយ អង្គជំនុំជម្រះសាលាដំបូងបន្តសវនាការរបស់ខ្លួន។

## វិធាន ៨២: ការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន និង ការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ

(វិសោធនកម្មថ្ងៃទី ០១ខែកុម្ភៈ ២០០៨ និង ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨)

១. ជនជាប់ចោទត្រូវមានសេរីភាពរហូតដល់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើកលែងតែមានការបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។ ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី លើកលែងតែករណីដែលមានចែងក្នុងអនុវិធាន ២ ខាងក្រោម។

២. គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬ បង្គាប់ឲ្យឃុំខ្លួន ជនជាប់ចោទបានស្របតាមវិធានផ្ទៃក្នុងនេះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីបញ្ហានេះ បន្ទាប់ពីបានស្តាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ និងសហព្រះរាជអាជ្ញា។

៣. ជនជាប់ចោទ ឬ ធាវីជនជាប់ចោទអាចស្នើសុំដោយផ្ទាល់មាត់ក្នុងពេលសវនាការ ឬ ដោយលិខិតជាលាយលក្ខណ៍អក្សរ ដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ។ ប្រសិនបើសំណើសុំដោះលែងត្រូវបានធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែកត់ត្រាទុកសំណើនេះនៅក្នុងកំណត់ហេតុសវនាការ ។ ប្រសិនបើសំណើនេះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវបញ្ជាក់អំពីកាលបរិច្ឆេទទទួលពាក្យសុំ និងបញ្ជូនពាក្យសុំនេះភ្លាមទៅប្រធានអង្គ-

ជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចសេចក្តី បន្ទាប់ពីបានស្តាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ និង សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចឲ្យបានឆាប់ដែលអាចធ្វើទៅបាន និង នៅក្នុងគ្រប់ករណីទាំងអស់ត្រូវសម្រេច ក្នុងរយៈពេលមិនឲ្យលើសពី ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ លើកលែងតែមានកាលៈទេសៈពិសេស ដែលតម្រូវឲ្យមានរយៈពេលយូរជាងនេះ។

៤. បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធដោះលែងជនជាប់ចោទ ជនជាប់ចោទអាចដាក់ពាក្យសុំជាថ្មីម្តងទៀតតែនៅពេលណាដែលស្ថានភាពរបស់ខ្លួនមានការប្រែប្រួលប៉ុណ្ណោះ ចាប់តាំងពីពេលដែលពាក្យសុំមុន ត្រូវបានបដិសេធ។

៥. រាល់សេចក្តីសម្រេចទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបើកផ្លូវប្តឹងសាទុក្ខ ដែលធ្វើឡើងដោយជនជាប់ចោទ ឬ សហព្រះរាជអាជ្ញា តាមករណីសមស្រប។

៦. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យដោះលែងជនជាប់ចោទ ជនជាប់ចោទត្រូវទទួលការដោះលែង លើកលែងតែប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្សេងពីនេះ តាមសំណើររបស់សហព្រះរាជអាជ្ញា។សំណើសុំផ្អាកសេចក្តីសម្រេចការដោះលែងនេះ សហព្រះរាជអាជ្ញាត្រូវដាក់ទៅប្រធានអង្គជំនុំជម្រះតុលាការកំពូល ក្នុងអំឡុងពេល ២៤(ម្ភៃបួន)ម៉ោង គិតពីពេលទទួលដំណឹងនេះ ដោយភ្ជាប់ជាមួយនូវឯកសារថតចម្លង នៃការដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹង សេចក្តីសម្រេចដោះលែងជនជាប់ចោទ។ សហព្រះរាជអាជ្ញា ត្រូវដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដោះលែងជនជាប់ចោទ ដោយភ្ជាប់ជាមួយនឹងឯកសារថតចម្លងនៃសំណើសុំផ្អាកការដោះលែងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង។ ចំពោះសំណើសុំនេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចក្នុងកំឡុងពេល៤៨(សែសិបប្រាំបី) ម៉ោង ដែលក្នុងអំឡុងពេលនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អាកការអនុវត្តសិន។ ប្រសិនបើប្រធានអង្គជំនុំជម្រះតុលាការកំពូល ខកខានមិនបានសម្រេចចំពោះសំណើសុំនេះ ក្នុងរយៈពេលកំណត់នេះទេ ឬ បដិសេធសំណើសុំផ្អាកការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវតែដោះលែងឲ្យមានសេរីភាពភ្លាម។ នៅពេលដែលប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចឲ្យផ្អាកការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនដដែលរហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលសម្រេចសេចក្តីលើពាក្យបណ្តឹងសាទុក្ខនេះ ។

លើកលែងតែនៅក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើពាក្យបណ្តឹងសាទុក្ខនេះ ក្នុង រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលទទួលបានសំណុំរឿង។ការចូលរួមសវនាការតាមមធ្យោបាយពីចម្ងាយ អាចត្រូវបានរៀបចំឡើងតាមការចាំបាច់។

## វិធាន ៨៣: ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី

(លុបចោលថ្ងៃទី ១០ ខែមិនា ឆ្នាំ ២០១០)

## វិធាន ៨៤: ការចូលខ្លួនរបស់សាក្សី និង អ្នកជំនាញ

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១. ជនជាប់ចោទមានសិទ្ធិស្នើសុំឲ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទ មិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ។

២. ក្រោយពីកាលបរិច្ឆេទត្រូវបានកំណត់ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវកោះហៅជាបន្ទាន់នូវសាក្សី និង អ្នកជំនាញដែលបានទទួលការយល់ព្រមរួចហើយ។ សាក្សី និង អ្នកជំនាញនោះត្រូវឆ្លើយតបទៅនឹងការកោះហៅ និង មកបង្ហាញខ្លួនក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងស្របតាមវិធានផ្ទៃក្នុង។

៣. ក្នុងពេលសវនាការ ភាគីនីមួយៗអាចស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងស្តាប់សាក្សីណាម្នាក់ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការដែលសាក្សីនោះមិនធ្លាប់ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅឡើយ។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយល់ព្រម ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវស្រង់អត្តសញ្ញាណរបស់សាក្សី និងអញ្ជើញសាក្សីនោះទៅកាន់បន្ទប់រង់ចាំ។

៤. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការកោះហៅសាក្សី អាចត្រូវប្តឹងសាទុក្ខបានដោយរួមគ្នាជាមួយ និង ការប្តឹងសាទុក្ខពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គសេចក្តីតែប៉ុណ្ណោះ។

## វិធាន ៨៥: ការដឹកនាំសវនាការ

១. ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី និង ជួយសម្រួលដល់ការធ្វើអន្តរាគមន៍របស់ថៅក្រមផ្សេងទៀត ។ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារ

ខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី។ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យាពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត។

២. ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការត្រូវធានារ៉ាប់រងឲ្យមានសណ្ដាប់ធ្នាប់ល្អក្នុងពេលសវនាការ ស្របទៅតាមវិធានផ្ទៃក្នុងនេះ។

## វិធាន ៨៦: ការមើលសំណុំរឿង

នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីទាំងអស់ ត្រូវមានសិទ្ធិពិនិត្យមើល និង ថតចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលម៉ោងធ្វើការ និង ត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## វិធាន ៨៧: វិធាននៃភស្តុតាង

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ និង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩)

១. លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

២. សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល ។

៣. អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬ ប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬ ភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬ ត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖

ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា

ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ-ច្បាប់មិនអនុញ្ញាត ឬ

ង-មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

៤. ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។

៥. អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងពិចារណានូវចម្លើយសារភាព ដូចគ្នានឹងប្រភេទនៃភស្តុតាងដទៃទៀតដែរ។

៦. ក្នុងករណីដែលសហព្រះរាជអាជ្ញា និងជនជាប់ចោទព្រមព្រៀងគ្នាថា អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានជំទាស់ទេ នោះអង្គជំនុំជម្រះអាចចាត់ទុកថាអង្គហេតុនោះត្រូវបានបញ្ជាក់ដោយភស្តុតាង ។

៧. ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវី គឺជាបុព្វសិទ្ធិពិសេស និង មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ។

៨. ប្រធានអង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យនាំយកវត្ថុតាងមកបង្ហាញ នៅចំពោះអង្គជំនុំជម្រះបាន។

## វិធាន ៨៨: ការបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩)

១. ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនទាំងនោះ ។ ភាគីនីមួយៗត្រូវអង្គុយទៅតាមកន្លែងដែលបម្រុងទុកនៅក្នុងបន្ទប់សវនាការ។

២. ជនជាប់ចោទមិនត្រូវប្រាស្រ័យទាក់ទងនឹងគ្នាទេ។ ប្រសិនបើអាចធ្វើទៅបាន អ្នកជំនាញ និង សាក្សីត្រូវស្ថិតនៅក្នុងបន្ទប់ផ្សេងដែលមិនអាចមើលឃើញ ឬ ឮពីអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ។ នៅពេលស្ថិតក្នុងបន្ទប់នោះ សាក្សីមិនត្រូវប្រាស្រ័យទាក់ទងនឹងគ្នាទេ។

៣. ការជំទាស់ប្រឆាំងនឹងនិយ័តភាពនៃការកោះហៅដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ ត្រូវតែលើកឡើង នៅមុនពេលសួរចម្លើយជនជាប់ចោទលើអង្គសេចក្តី។ បើពុំដូច្នោះទេ ការជំទាស់នេះមិនអាចទទួលបានឡើយ។

## វិធាន ៨៩: អញ្ញត្រកម្ម

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ និងថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១)

១. អញ្ញត្រកម្មទាក់ទងទៅនឹង:

ក- យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

ខ- ការរលត់បណ្តឹងអាជ្ញា

គ- មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ

ត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ ។

២. អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្តល់ឱ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបទៅនឹងអញ្ញត្រកម្ម។

៣. អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចជាបន្ទាន់អំពីអញ្ញត្រកម្មតាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ឬ នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ ដំណើរការនីតិវិធីត្រូវបន្តលើកលែងតែអង្គជំនុំជម្រះចេញសេចក្តីសម្រេចភ្លាម ដែលមានអានុភាពបញ្ចប់កិច្ច ដំណើការនីតិវិធី។

## វិធាន ៨៩ ស្ទួន: សវនាការលើអង្គសេចក្ដី

(អនុម័តថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និងវិសោធនកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១ )

១. ប្រធានអង្គជំនុំជម្រះសាលាដំបូង ប្រកាសបើកសវនាការលើអង្គសេចក្ដី ។ ប្រធានអង្គជំនុំជម្រះសាលាដំបូង បង្គាប់អោយក្រឡាបញ្ជីអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និង អាចបង្គាប់ អោយក្រឡាបញ្ជី អាននូវការវិភាគអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

២. នៅមុនពេលសួរចម្លើយជនជាប់ចោទ សហព្រះរាជអាជ្ញា អាចធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬ មេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន។

## វិធាន ៨៩ស្ទួនពីរ: ការបំបែកកិច្ចដំណើរការនីតិវិធី

**(វិសោធនកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១)**

នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬ ច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្ដីដែលត្រូវបានបំបែកត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប។

## វិធាន ៩០: ការសួរចម្លើយជនជាប់ចោទ

១. ប្រធានអង្គជំនុំជម្រះត្រូវប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងវិធាន ២១-១ (ឃ) និងដឹកនាំសវនាការ។ ចៅក្រម មានករណីយកិច្ចសួរសំណួរដែលពាក់ព័ន្ធទាំងអស់ ទោះបីជាសំណួរទាំងនោះមានបំណងដើម្បីដាក់បន្ទុក ឬ ដោះបន្ទុកចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទក៏ដោយ។

២. សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី ក៏មានសិទ្ធិសួរជនជាប់ចោទផងដែរ។ គ្រប់សំណួរទាំងអស់អាចសួរទៅបានដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង។ លើកលែងតែការសាកសួររបស់សហព្រះរាជអាជ្ញានិងមេធាវី រាល់សំណួរទាំងអស់ត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះ និងតាមលំដាប់លំដោយដែលបានកំណត់ដោយប្រធាន។

## វិធាន ៩១: ការស្តាប់ចម្លើយរបស់ភាគី និង សាក្សី

**(វិសោធនកម្មនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១០)**

១.	អង្គជំនុំជម្រះសាលាដំបូងត្រូវស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ទៅតាមលំដាប់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍។

២.	ចៅក្រម អាចសួរសំណួរ ហើយសហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី ក៏ត្រូវបានអនុញ្ញាតឲ្យសួរសំណួរ ដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង ។ សំណួរទាំងអស់ត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះសាលាដំបូង លើកលែងតែការសាកសួររបស់ចៅក្រម សហព្រះរាជអាជ្ញា និង មេធាវី។

៣.	សហព្រះរាជអាជ្ញា ភាគីទាំងអស់ និង មេធាវីអាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សី ដែលកំពុងដំណើរការ ប្រសិនបើខ្លួនយល់ថា ចម្លើយរបស់សាក្សីនោះមិនសម្តែងឲ្យឃើញការពិត ។ នៅក្នុងករណីនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា តើត្រូវស្តាប់ ឬ មិនត្រូវស្តាប់ចម្លើយសាក្សីនេះ។

៤.	បន្ទាប់ពីស្តាប់ចម្លើយរួច សាក្សីនីមួយៗត្រូវតែនៅបម្រុងខ្លួនសម្រាប់សេចក្តីត្រូវការ របស់អង្គជំនុំជម្រះសាលាដំបូងរហូតដល់ពេលអង្គជំនុំជម្រះសាលាដំបូងសម្រេចថា វត្តមានរបស់សាក្សីនោះលែងចាំបាច់ទៀតហើយ។

## វិធាន ៩១*ស្ទួន:* លំដាប់លំដោយនៃដំណើរការនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះ

ប្រធានអង្គជំនុំជម្រះសាលាដំបូង ត្រូវកំណត់លំដាប់លំដោយ ដែលចៅក្រម សហព្រះរាជអាជ្ញា មេធាវី និងភាគីនានាដទៃទៀត មានសិទ្ធិសួរសំណួរទៅកាន់ជនជាប់ចោទ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី។

## វិធាន ៩២: ការដាក់សេចក្តីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះត្រូវចុះ

ហត្ថលេខា និង ចុះកាលបរិច្ឆេទទទួលសេចក្តីសន្និដ្ឋាននេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

**វិធាន ៩៣: ការស៊ើបសួរបន្ថែមដោយអង្គជំនុំជម្រះសាលាដំបូង**

១. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា ។ សាលក្រមមុនអង្គសេចក្តីនេះ ត្រូវកំណត់បង្ហាញអំពី ចៅក្រមមួយរូប ឬ ច្រើនរូប ដែលត្រូវជាអ្នកដឹកនាំការស៊ើបសួរថ្មីនេះ។

២. ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែម ក៏ត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតដែរ ហើយអាច ៖

ក-ចុះទៅដល់ទីកន្លែងណាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច នៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា៖

ខ-ស្តាប់ចម្លើយសាក្សី

គ-ដឹកនាំការឆែកឆេរ

ឃ-ចាប់យកវត្ថុតាង ឬ

ង-បង្គាប់ឲ្យធ្វើកោសលវិច័យ។

៣. ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឲ្យសួរជំនួសទៅមន្ត្រីនគរបាលយុត្តិធម៌បានដែរ។

**វិធាន ៩៤: សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល**

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ **និងវិសោធនកម្មនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. ក្រោយពេលពិនិត្យលើភស្តុតាងទាំងអស់រួចហើយ ប្រធានអង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យជនដូចខាងក្រោមនេះ ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាបន្តបន្ទាប់គ្នា ៖

ក-សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ខ-សហព្រះរាជអាជ្ញា ដើម្បីធ្វើការសន្និដ្ឋានប្តឹងសុំដោយផ្ទាល់មាត់ដែលខ្លួនយល់ឃើញថាសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ ។

គ-មេធាវីរបស់ជនជាប់ចោទ ។

ឃ-ជនជាប់ចោទ ។

២.	សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី	និងសហព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបវិញបាន។

៣.	នៅគ្រប់ករណីទាំងអស់	ជនជាប់ចោទ	និងមេធាវីរបស់ជនជាប់ចោទត្រូវតែមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានចុងក្រោយជានិច្ច។

### វិធាន ៩៥: ការបន្តកិច្ចដំណើរការនីតិវិធី

ប្រសិនបើការពិភាក្សាដេញដោលមិនបានបញ្ចប់នៅក្នុងពេលសវនាការនោះទេ ប្រធានអង្គជំនុំជម្រះត្រូវបន្តសវនាការទៅថ្ងៃក្រោយទៀត តាមកាលបរិច្ឆេទដែលបានកំណត់។

### វិធាន ៩៦: ការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨)

១.	ចៅក្រមទាំងអស់ត្រូវពិភាក្សាគ្នាដោយសម្ងាត់ ដើម្បីសម្រេចសេចក្តីចេញសាលក្រម ។ អ្នកបកប្រែអាចត្រូវហៅឲ្យជួយសម្រួលដល់ការពិភាក្សាសម្រេចសេចក្តី។

២.	នៅក្នុងដំណាក់កាលនេះ គ្មានពាក្យសុំណាមួយអាចត្រូវបានលើកយកមកសំអាងទៀតទេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង គ្មានសេចក្តីសន្និដ្ឋានណាមួយ អាចទទួលយកបានទៀតឡើយ ។ អំឡុងពេលពិភាក្សាសម្រេច ចៅក្រមអាចបើកនីតិវិធីឡើងវិញបាន ។

### វិធាន ៩៧: កំណត់ហេតុរបស់អង្គសវនាការ

(វិសោធនកម្មថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និងថ្ងៃទី ០៥ ខែកញ្ញា ២០០៨)

១.	នៅក្នុងអំឡុងពេលសវនាការ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ត្រូវសរសេរកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសវនាការប្រចាំថ្ងៃ ដោយយកចិត្តទុកដាក់បំផុត ។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះត្រូវចុះហត្ថលេខាលើកំណត់ហេតុជាលាយលក្ខណ៍អក្សរប្រចាំថ្ងៃ ក្នុងរយៈពេល១០(ដប់)ថ្ងៃ ។ នៅពេលកាលៈទេសៈពិសេសតម្រូវ អង្គជំនុំជម្រះសាលាដំបូងអាចពន្យាររយៈពេលនេះបាន ។

២.	ការប្រព្រឹត្តទៅនៃសវនាការ ត្រូវបានធ្វើប្រតិចារឹក និងថតទុកយ៉ាងត្រឹមត្រូវ ដោយប្រើប្រាស់នូវឧបករណ៍សោតទស្សន៍ដែលសមស្រប ក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។

៣.	កំណត់ហេតុជាលាយលក្ខណ៏អក្សរប្រចាំថ្ងៃនៃដំណើរការនីតិវិធី ដែលធ្វើឡើងដោយក្រឡាបញ្ជី ត្រូវចាត់ទុកថាមានភាពត្រឹមត្រូវ ឆ្លុះបញ្ចាំងអំពីការប្រព្រឹត្តទៅពិតប្រាកដនៃសវនាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រតិចារិក និងខ្សែអាត់សម្លេង ក្នុងករណីចាំបាច់ ត្រូវបានអនុញ្ញាតអោយយកមកប្រើប្រាស់ ដើម្បីបំពេញបន្ថែម ឬ កែតម្រូវនូវកំណត់ហេតុជាលាយលក្ខណ៏ប្រចាំថ្ងៃនោះ នៅពេលណាក៏បាន។

៤.	ពាក្យសុំអោយកែតម្រូវលើប្រតិចារិក ត្រូវធ្វើជាលាយលក្ខណ៏អក្សរមកអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើពាក្យសុំនោះ ក្នុងពេលណាមួយក្រោយរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដាក់ពាក្យសុំ ។

### វិធាន ៩៨: សាលក្រម

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១.	នៅពេលដែលសាលក្រមមិនត្រូវបានប្រកាសក្នុងពេលសវនាការចុងក្រោយទេ ប្រធានអង្គជំនុំជម្រះត្រូវ ជូនដំណឹងដល់ភាគីអំពីការកំណត់កាលបរិច្ឆេទ ដើម្បីប្រកាសសាលក្រម ។

២.	សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ-ជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ ។ អង្គជំនុំជម្រះត្រូវធ្វើការវិនិច្ឆ័យតែចំពោះជនជាប់ចោទប៉ុណ្ណោះ។ ប្រសិនបើបុគ្គលណាមួយ ដែលមកបង្ហាញខ្លួនក្នុងពេលជំនុំជម្រះក្នុងឋានៈជាសាក្សី ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬ បានសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ អង្គជំនុំជម្រះនឹងធ្វើការជំនុំជម្រះលើបុគ្គលនោះបាន លុះត្រាតែនៅក្រោយពេលដែលជននោះត្រូវបានចោទប្រកាន់ និងមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចចែងនៅក្នុងវិធានផ្ទៃក្នុងនេះប៉ុណ្ណោះ។

៣.	អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថា តើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ។

៤.	អនុលោមតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះត្រូវព្យាយាមសម្រេចជាឯកច្ឆ័ន្ទ។ បើមិនអាចសម្រេចជាឯកច្ឆ័នបានទេ ការសម្រេចផ្តន្ទាទោសទាមទារឲ្យមាន

សម្លេងគាំទ្រពីចៅក្រមយ៉ាងតិច ៤(បួន)សម្លេង ។ ប្រសិនបើរកសម្លេងភាគច្រើនតាមតម្រូវការមិនបានទេនោះមានន័យថា ជនជាប់ចោទត្រូវរួចផុតពីបទចោទ។

៥. ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានទោស អង្គជំនុំជម្រះត្រូវផ្តន្ទាទោសជនជាប់ចោទនោះ ឲ្យស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង វិធានផ្ទៃក្នុងនេះ។

៦. នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា អំពើដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនមានភស្តុតាងបង្ហាញពិតប្រាកដ ឬ យល់ឃើញថា ជនជាប់ចោទមិនមានពិរុទ្ធភាពក្នុងអំពើទាំងនោះទេ ជនជាប់ចោទត្រូវបានរួចផុតពីបទចោទ។

៧. នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះអង្គជំនុំជម្រះត្រូវសម្រេចថា គ្មានសមត្ថកិច្ចទៅលើករណីនោះទេ។

### ***វិធាន ៩៩: អានុភាពនៃសាលក្រម***

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨)

១. នៅក្នុងករណីសម្រេចឲ្យរួចផុតពីបទចោទ ឬ នៅពេលដែលទោសដែលបានដាក់តិចជាង ឬ ស្មើទៅនឹង រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានជាប់រួចមកហើយ ជនជាប់ចោទត្រូវបានដោះលែងភ្លាម លើកលែងតែជនជាប់ចោទនោះ ត្រូវបានជាប់ក្នុងការឃុំខ្លួនអំពីបទចោទប្រកាន់ផ្សេងទៀត។

២. នៅពេលដែលជនជាប់ចោទដែលស្ថិតនៅក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវបានប្រកាសថាមានទោសនោះអង្គជំនុំជម្រះត្រូវសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្នជាបន្តទៀត។ ប្រសិនបើជនជាប់ចោទមានវត្តមាន នៅពេលប្រកាសសាលក្រមប៉ុន្តែមិនជាប់ក្នុងការឃុំខ្លួនទេ អង្គជំនុំជម្រះអាចសម្រេចបង្គាប់ឲ្យឃុំខ្លួន ដោយមានសំអាងហេតុ។ នៅពេលដែលជនជាប់ចោទអវត្តមាន អង្គជំនុំជម្រះអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន។ ដីកាទាំងនេះត្រូវមានអានុភាពអនុវត្តភ្លាមៗ។

៣. នៅពេលប្រកាសសាលក្រមការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវអស់

អានុភាព ។ អង្គជំនុំជម្រះត្រូវធ្វើសេចក្តីសម្រេចចាំបាច់នានាទាក់ទងនឹងវត្ថុតាង ដែលបិទស្លាកបោះត្រា ហើយក្នុងគោលបំណងនេះអាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យមានការដាក់សារណាពីសំណាក់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី។

## វិធាន ១០០: ការសម្រេចលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ **និងវិសោធនកម្មនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១០**)

អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ អង្គជំនុំជម្រះមិនត្រូវចេញសាលក្រមសម្រេចអំពីបណ្តឹងរដ្ឋប្បវេណី ដែលផ្ទុយទៅនឹងសាលក្រមសម្រេចអំពីបណ្តឹងអាជ្ញាក្នុងរឿងក្តីតែមួយឡើយ។ នៅពេលដែលសមស្រប អង្គជំនុំជម្រះអាចបន្តការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី នៅក្នុងសវនាការដោយឡែកមួយទៀតបាន។

## វិធាន ១០១: ទម្រង់ការនៃសាលក្រម

១. សាលក្រមត្រូវចែកជាពីរផ្នែក:

ក-ផ្នែកសំអាងហេតុ គឺជាការយល់ឃើញអំពីមូលហេតុខាងអង្គហេតុ និង អង្គច្បាប់ដែលនាំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច

ខ-ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះ

២. ប្រសិនបើមិនមានសម្លេងជាឯកច្ឆ័ន្ទទេ ចៅក្រមអាចសរសេរយោបល់ដោយឡែកមួយផ្សេង ឬ យោបល់ ជំទាស់នៅក្នុងករណីនេះ ហើយត្រូវភ្ជាប់ទៅនឹងសាលក្រម។

៣. អង្គជំនុំជម្រះត្រូវពិនិត្យលើរាល់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ពិចារណាលើលទ្ធផល នៃកិច្ចពិភាក្សាដេញដោលដែលបានលើកឡើងក្នុងពេលជំនុំជម្រះ។

៤. ផ្នែកសំអាងហេតុនៅក្នុងសាលក្រម ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរដែលបានធ្វើឡើងដោយភាគីទាំងអស់។

៥. ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបញ្ជាក់ពីបទល្មើសនីមួយៗដែលប្រព្រឹត្តដោយជនជាប់ចោទ ច្បាប់ជាធរមាន ការផ្តន្ទាទោស និងសំណង។

៦.	សាលក្រមត្រូវតែចុះហត្ថលេខាដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនិង ក្រឡាបញ្ជីផងដែរ។ ចៅក្រមដែលមានយោបល់ជំទាស់ត្រូវចុះហត្ថលេខាតែនៅលើឯកសារផ្តល់យោបល់ដោយឡែក ឬ យោបល់ជំទាស់របស់ខ្លួនតែប៉ុណ្ណោះ។ សាលក្រមត្រូវមានចុះសេចក្តីដូចខាងក្រោម៖

ក-កាលបរិច្ឆេទនៃសវនាការ

ខ-កាលបរិច្ឆេទនៃការប្រកាសសាលក្រម

គ-ឈ្មោះរបស់ចៅក្រមដែលជំនុំជម្រះ

ឃ-ឈ្មោះរបស់សហព្រះរាជអាជ្ញា

ង-ឈ្មោះរបស់ក្រឡាបញ្ជី

ច-ឈ្មោះពេញ អាស័យដ្ឋាន ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និង មុខរបររបស់ជនជាប់ចោទ

ឆ-ឈ្មោះពេញរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអាស័យដ្ឋានបច្ចុប្បន្ន ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងមុខរបរ នៅពេលដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ

ជ-ឈ្មោះពេញរបស់មេធាវី និង

ឈ-សិទ្ធិប្តឹងសាទុក្ខរបស់ភាគី និង លក្ខខណ្ឌ និង ពេលវេលាកំណត់សម្រាប់ប្តឹងសាទុក្ខ។

៧.សាលក្រមដើមដែលមានទម្រង់ដូចខាងលើត្រូវចុះហត្ថលេខាយ៉ាងយូរបំផុតនៅថ្ងៃចេញសាលក្រម។

**វិធាន ១០២: ការប្រកាសសាលក្រមនៅសវនាការសាធារណ:**

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨)

១.	គ្រប់សាលក្រមទាំងអស់ត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ។ ផ្នែកសង្ខេបនៃសំអាងហេតុ និងផ្នែកសម្រេចសេចក្តីត្រូវតែអានខ្លាំងៗ ដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ឬ សមាជិកនៃអង្គជំនុំជម្រះណាម្នាក់។ ចៅក្រមដែលមានយោបល់ផ្ទុយ អាចអានដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបគំនិតផ្ទុយរបស់ខ្លួន ។ ក្រឡាបញ្ជីត្រូវផ្តល់សាលក្រមចម្លងមួយច្បាប់ទៅឱ្យភាគីទាំងឡាយ និង ត្រូវធានាថាសាលក្រមត្រូវបានផ្សព្វផ្សាយដោយការិយាល័យរដ្ឋបាល តាមមធ្យោបាយសមស្រប។

២.	បើសិនជាជនជាប់ចោទអវត្តមាននៅពេលប្រកាសសាលក្រម ជនជាប់ចោទនឹងត្រូវបានជូនដំណឹងតាមរយៈមេធាវីរបស់ខ្លួន ឬ តាមរយៈមេធាវីដែលត្រូវបានចាត់តាំង ដោយអង្គជំនុំជម្រះសាលាដំបូង ។ រយៈពេលដាក់បណ្តឹងសារទុក្ខគិតចាប់ពីថ្ងៃជូនដំណឹង។

**វិធាន១០៣: សាលក្រមពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី**

(ត្រូវបានធ្វើនិរាករណ៍ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)

## ច-នីតិវិធីនៃបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង

### វិធាន ១០៤: យុត្តាធិការនៃអង្គជំនុំជម្រះតុលាការកំពូល

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ និងថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០)

១. អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖

ក. កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈ សាលក្រមលើអង្គសេចក្តឬ សេចក្តីសម្រេចនោះ។ ឬ

ខ. កំហុសនៃអង្គហេតុ ដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។

បន្ថែមពីនេះ បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងទៅនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ-សាលាដំបូងដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

ក្នុងគោលបំណងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ។

២. អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចតម្កល់ ឬ ទុកជាមោឃៈ ឬ កែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មួយផ្នែក ឬ ទាំងស្រុងបាន ដូចមានចែងក្នុងវិធាន ១១០។

៣. សេចក្តីសម្រេចនៃអង្គជំនុំជម្រះតុលាការកំពូល គឺជាសេចក្តីសម្រេចចុងក្រោយ និង មិនត្រូវបង្វិលឲ្យអង្គជំនុំជម្រះសាលាដំបូងវិញឡើយ។

៤. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោមត្រូវបានបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ៖

ក-សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ។

ខ-សេចក្តីសម្រេចអំពីការឃុំខ្លួននិងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោម

តាមវិធាន ៨២ ។

គ-សេចក្តីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) និង

ឃ-សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦) ។

សេចក្តីសម្រេចផ្សេងទៀត អាចប្តឹងសាទុក្ខបានតែក្នុងករណី ដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខ ពីសាលក្រមលើអង្គសេចក្តី។

លើកលែងតែមានចែងក្នុងវិធានផ្ទៃក្នុង ឬ ការសម្រេចផ្សេងដោយអង្គជំនុំជម្រះសាលាដំបូងបណ្តឹងសាទុក្ខភ្លាមៗមិនមានអនុភាពបង្អង់នីតិវិធីមុខអង្គជំនុំជម្រះសាលាដំបូងទេ។

## វិធាន ១០៤ *ស្ទួន:* វិធានអនុវត្តជាធរមាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

(អនុម័តថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ **និងវិសោធនកម្មនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១០**)

រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីសមស្រប ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ។

## វិធាន ១០៥: ការទទួលបណ្តឹងសាទុក្ខ

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១- បណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជនុំជម្រះសាលាដំបូង អាចធ្វើឡើងដោយ:

ក-សហព្រះរាជអាជ្ញា

ខ-ជនជាប់ចោទ

គ- ដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹង សេចក្តីសម្រេចស្តីពីសំណង។ នៅពេលដែលសហព្រះរាជអាជ្ញា បានធ្វើបណ្តឹងសាទុក្ខរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ ដើមបណ្តឹងរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យធ្វើបណ្តឹងសាទុក្ខលើសេចក្តីសម្រេចផ្តន្ទាទោសបានឡើយ។

២. ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបើកផ្លូវសាទុក្ខភ្លាម អនុលោមតាមវិធាន ១០៤(៤) ត្រូវដាក់បណ្តឹងសាទុក្ខនោះ ដោយបញ្ជាក់ពីមូលដ្ឋានគាំទ្របណ្តឹងសាទុក្ខ និងទឡ្ហីករណ៍នានា។ មូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខត្រូវ៖

ក. បញ្ជាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថាកំហុសនោះបណ្តាលឲ្យសេចក្តីសម្រេចមានមោឃៈភាព។ឬ

ខ.បញ្ជាក់អំពីកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំអោយមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ឬ

គ. បញ្ជាក់អំពីកំហុសអង្គហេតុ និងត្រូវបង្ហាញថាកំហុសនេះ នាំអោយមានការភ័ន្តច្រឡំក្នុងការសំរេចសេចក្តីរបស់តុលាការ។

៣. ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវដាក់សេចក្តីជូនដំណឹង អំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ ដែលនាំឲ្យសេចក្តីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មកម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់សារណាបណ្តឹងសាទុក្ខដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ អនុលោមតាមលក្ខខណ្ឌនៅក្នុងវាក្យខណ្ឌទី ២ (ក) និង (គ) នៃវិធាននេះ។

៤. រាល់បណ្តឹងសាទុក្ខត្រូវបង្ហាញផងដែរអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្តីសម្រេច ដែលខ្លួនជំទាស់ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

### វិធាន ១០៦: ការជូនដំណឹងអំពីបណ្តឹងសាទុក្ខ និង ការដាក់សារណា

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១. បើមានការដាក់ពាក្យសុំប្តឹងសាទុក្ខ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងត្រូវជូនដំណឹងជាបន្ទាន់ដល់គ្រប់ភាគី និងមេធាវីទាំងអស់របស់ពួកគេ។

២. បណ្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខភ្លាមៗត្រូវដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនិង ត្រូវចុះក្នុងបញ្ជីបណ្តឹងសាទុក្ខនៃអង្គជំនុំជម្រះសាលាដំបូង។

៣.	ជនជាប់ចោទ អាចត្រូវបានតំណាងដោយមេធាវីតំណាង តាមការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ដើម្បីដាក់ពាក្យបណ្តឹងសាទុក្ខ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែតំណាងដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។

៤. ការជូនដំណឹងអំពីបណ្តឹងសាទុក្ខ ឬ បណ្តឹងសាទុក្ខភ្លាមៗ ត្រូវចុះហត្ថលេខាដោយដើមបណ្តឹងសាទុក្ខ ឬ មេធាវីដើមបណ្តឹងសាទុក្ខ និងចុះហត្ថលេខាសង្ខេបដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។ លិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរក៏ត្រូវជូនភ្ជាប់ជាមួយនឹងពាក្យបណ្តឹងនេះ។

៥. សារណាបណ្តឹងសាទុក្ខប្រឆាំងទៅនឹងសាលក្រម រួមទាំងការដាក់ឯកសារផ្សេងៗបន្ទាប់ទៀត ត្រូវប្រគល់ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល។

៦.	ក្នុងករណីដែលជនជាប់ចោទកំពុងស្ថិតនៅក្នុងការឃុំខ្លួន ជននោះត្រូវដាក់ពាក្យបណ្តឹងសាទុក្ខនេះតាមរយៈប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញ ហើយប្រធានមន្ទីរឃុំឃាំងត្រូវបញ្ជូនពាក្យបណ្តឹងនេះមក ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងភ្លាម។ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីបណ្តឹងសាទុក្ខ។

**វិធាន ១០៧: រយៈពេលនៃបណ្តឹងសាទុក្ខ**

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១.	ក្នុងករណីដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បើកឲ្យមានបណ្តឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន១០៤ (៤) (ក) និង(ឃ) បណ្តឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្តីសំរេចនោះ ។

២. ក្នុងករណីដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការឃុំខ្លួន ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ វិធានការការពារ ដែលបើកឲ្យមានបណ្តឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន ១០៤(៤)(ខ) និង (គ) និងលើកលែងតែប្រការដែលមានចែងក្នុងអនុវិធាន៣ ខាងក្រោម បណ្តឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬការជូនដំណឹងពីសេចក្តីសម្រេចនោះ ទៅតាមករណីសមស្រប។

៣.	ក្នុងករណីដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ដែលបើកឲ្យមានប្តឹងសាទុក្ខភ្លាម ដូចមានចែងក្នុងវិធាន ១០៤ អនុវិធាន ៤ វាក្យខណ្ឌ ខ

បណ្តឹង សាទុក្ខត្រូវធ្វើឡើងដោយអនុលោមទៅតាមនីតិវិធី ដូចមានចែងក្នុងវិធាន ៨២(៦) និងក្នុងរយៈពេល ២៤ ម៉ោង គិតចាប់ ពីពេលជូនដំណឹងអំពីសេចក្តីសម្រេចដោះលែងឲ្យនៅក្រៅឃុំ។

៤. សេចក្តីសុំប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដូចមានកំណត់នៅក្នុងវិធាន ១០៥(៣) ត្រូវធ្វើក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងពីសាលក្រមនោះ តាមករណីសមស្រប ។ ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពី កាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ។ ក្នុងករណីដែលមានបណ្តឹងសាទុក្ខ ដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ (ដប់ប្រាំ) ថ្ងៃទៀត ដើម្បីដាក់សេចក្តីសុំប្តឹងសាទុក្ខ។ រយៈពេល បន្ថែមនេះត្រូវគិតចាប់ពីថ្ងៃផុតរលត់រយៈពេលនៃបណ្តឹងសាទុក្ខលើកដំបូង។

## វិធាន ១០៨: នីតិវិធីនៃបណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ និង ថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩ **និងវិសោធនកម្មថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០**)

១. ក្នុងករណីមានបណ្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្រឡាបញ្ជីនៃអង្គ-ជំនុំជម្រះសាលាដំបូងត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជី នៃអង្គជំនុំជម្រះតុលាការកំពូលដោយភ្ជាប់ជាមួយ នូវឯកសារថតចម្លងនៃសាលក្រម និង សេចក្តីជូនដំណឹងនីមួយៗនៃបណ្តឹងសាទុក្ខនេះដែលមានសេចក្តី បញ្ជាក់ថាបានថតចម្លងត្រឹមត្រូវ។

២. ក្នុងករណីមានបណ្តឹងសាទុក្ខចំពោះសាលក្រមដែលសម្រេចឲ្យឃុំខ្លួនជនជាប់ចោទ ឯកសារដូច ដែលមានរៀបរាប់ខាងលើ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះតុលាការកំពូលក្នុងរយៈពេល ១០(ដប់)ថ្ងៃ គិតពីថ្ងៃ ដាក់បណ្តឹងសាទុក្ខ លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន ។ កាលៈទេសៈមិនអាចជំនះបាន នេះ ត្រូវមានបញ្ជាក់ឲ្យបានច្បាស់លាស់ក្នុងពេលធ្វើការបញ្ជូនសំណុំឯកសារនេះទៅ អង្គជំនុំជម្រះ-តុលាការ កំពូល។

៣. កាលបរិច្ឆេទនៃសវនាការជំនុំជម្រះលើបណ្តឹងសាទុក្ខ ត្រូវកំណត់ដោយប្រធានអង្គជំនុំជម្រះ-តុលាការកំពូល ក្រោយពីបានពិនិត្យថា សំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ហើយ ។ ក្រឡាបញ្ជីនៃអង្គ ជំនុំជម្រះតុលាការកំពូល ត្រូវជូនដំណឹងដល់គ្រប់ភាគីអំពីកាលបរិច្ឆេទនៃសវនាការ។ ប្រធានអង្គជំនុំជម្រះ តុលាការកំពូលអាចសម្រេចថា ចៅក្រមបម្រុងម្នាក់ឬទាំងពីរ ត្រូវមានវត្តមានក្នុងអំឡុងពេលសវនាការលើ បណ្តឹងសាទុក្ខ។

៤.	អង្គជំនុំជម្រះតុលាការកំពូល ត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនក្នុងអំឡុងពេលមួយសមរម្យ។ ក្នុងករណីមានបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេច ដែលសម្រេចឃុំខ្លួនជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចឲ្យបានឆាប់ដែលអាចធ្វើទៅបាន និង នៅក្នុងគ្រប់ករណីទាំងអស់ត្រូវសម្រេច ក្នុងរយៈពេលមិនឲ្យលើសពីរយៈពេលបីខែប្រតិទិន បន្ទាប់ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលទទួលបានសំណុំរឿង។

៥.	ប្រធានអង្គជំនុំជម្រះតុលាការកំពូលត្រូវចាត់តាំងចៅក្រមអន្តរជាតិមួយរូប និងចៅក្រមជាតិមួយរូបអោយធ្វើជាសហចៅក្រមរបាយការណ៍សម្រាប់បណ្តឹងសាទុក្ខនោះ ។ សហចៅក្រមរបាយការណ៍ត្រូវធ្វើរបាយការណ៍ជាលាយលក្ខអក្សរដែលត្រូវចង្អុលអំពីអង្គហេតុ និង សេចក្តីសំរេចលំអិត នៃសេចក្តីសំរេចដែលត្រូវបានប្តឹងសាទុក្ខ។ របាយការណ៍ត្រូវតែផ្តល់ព័ត៌មានអោយបានលំអិតគ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះបានទទួលព័ត៌មានពេញលេញអំពីបណ្តឹងសាទុក្ខ ។ របាយការណ៍នេះត្រូវបញ្ចូលទៅក្នុងសំណុំរឿង។

៦.	សហព្រះរាជអាជ្ញា និង មេធាវីភាគីដទៃទៀត អាចមើលសំណុំរឿងបាននៅគ្រប់ពេលមុនកាលបរិច្ឆេទនៃសវនាការ ។ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគី អាចដាក់សារណាអំពីបណ្តឹងសាទុក្ខទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ក្រឡាបញ្ជីត្រូវចុះកាលបរិច្ឆេទទទួលសារណា និង ដាក់បញ្ចូលសារណានោះទៅក្នុងសំណុំរឿង។

៧.	ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក ។ ភាគីផ្សេងទៀតដែលរងការប៉ះពាល់ដោយសេចក្តីស្នើសុំនេះ អាចធ្វើការឆ្លើយតបក្នុងរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីស្នើសុំនោះ។

### វិធាន ១០៩: អំពីសវនាការលើបណ្តឹងសាទុក្ខ

(វិសោធនកម្មថ្ងៃទី ០៦ ខែមិនា ឆ្នាំ ២០០៩)

១.	សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូល

អាចធ្វើសេចក្តីសម្រេចពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍ដែលដាក់ដោយភាគីតែប៉ុណ្ណោះ ។

២. ការិយាល័យរដ្ឋបាលត្រូវធានាអំពីការផ្សព្វផ្សាយជាសាធារណៈអំពីសវនាការលើបណ្តឹងសាទុក្ខនេះដោយ អនុលោមតាមវិធានការការពារ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

៣. ក្នុងករណីដែលអង្គជំនុំជម្រះពិចារណាឃើញថា សវនាការជាសាធារណៈធ្វើឲ្យខូចខាតដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ប៉ះពាល់ដល់វិធានការការពារ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ អង្គជំនុំ-ជម្រះតាមរយៈសេចក្តីសម្រេចដែលមានសំអាងហេតុ អាចសម្រេចថាការជំនុំជម្រះទាំងមូល ឬ មួយផ្នែកត្រូវធ្វើជាសម្ងាត់បាន ។ សេចក្តីសម្រេចនេះបិតផ្លូវប្តឹងតវ៉ា។

៤. សហចៅក្រមរបាយការណ៍ត្រូវអានរបាយការណ៍ជូនអង្គជំនុំជម្រះ ។ បន្ទាប់មកប្រធានត្រូវប្រាប់ដល់ ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួនដែលមានចែងនៅក្នុងវិធាន ២១.១(ឃ) និងដឹកនាំដំណើរការសវនាការ។ ម្ចាស់បណ្តឹងសាទុក្ខ អាចធ្វើសារណាបញ្ជាក់អំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខ ហើយភាគីដទៃទៀតក៏អាចធ្វើសារណាឆ្លើយតបបានដែរ ។ ចៅក្រមទាំងអស់អាចសួរសំណួរទាំងឡាយដែលខ្លួនយល់ថាអាចឈានទៅដល់ការធ្វើសេចក្តីវិនិច្ឆ័យចំពោះបណ្តឹងសាទុក្ខ។

៥. ភាគីមិនអាចលើកឡើងអំពីបញ្ហាណាមួយនៃអង្គហេតុ ឬ អង្គច្បាប់ ដែលមិនបានសរសេរបង្ហាញមុន នៅក្នុងសារណានៃបណ្តឹងសាទុក្ខ នៅក្នុងអំឡុងពេលនៃសវនាការឡើយ។

៦. គ្រប់ករណីទាំងអស់ ជនជាប់ចោទត្រូវនិយាយក្រោយគេបំផុត ។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានតបដោយសង្ខេប។

### វិធាន ១១០: អានុភាពនៃបណ្តឹងសាទុក្ខ

**(វិសោធនកម្មថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. វិសាលភាពនៃបណ្តឹងសាទុក្ខត្រូវកម្រិតត្រឹមបញ្ហា ដែលលើកឡើងក្នុងលិខិតប្តឹងសាទុក្ខ និង តាមលក្ខណៈ សម្បត្តិរបស់អ្នកប្តឹងសាទុក្ខ។

២. គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែបទចោទប្រកាន់ ដែលអង្គជំនុំជម្រះ

សាលាដំបូងបានកំណត់ ។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបន្ថែមធាតុផ្សំថ្មី នៃបទល្មើសណាមួយ ដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ។

៣. អង្គជំនុំជម្រះតុលាការកំពូល មិនអាចបន្ថែមទម្ងន់ទោសបានឡើយ កាលណាបើមានតែជនជាប់តែប៉ុណ្ណោះដែលធ្វើបណ្តឹងសាទុក្ខ នោះ។ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែសាលក្រមបាននៅក្នុងន័យ ដែលផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទតែប៉ុណ្ណោះ។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូល មិនអាចសម្រេចបង្កើនបន្ទុកនៃការជួសជុល សំណងខូចខាតដល់ដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ។

៤. នៅពេលដែលមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចលើកលែងចោទប្រកាន់ជនជាប់ចោទ ឬ កែប្រែការផ្តន្ទាទោស ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេច ពីអនុទោសចាំបាច់ ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេច។ ប៉ុន្តែក្នុងករណីដែលបណ្តឹងសាទុក្ខធ្វើឡើង ដោយសហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រម ដែលសម្រេចឱ្យរួចផុតពីបទចោទរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលអាចត្រឹមតែធ្វើការកែប្រែនូវផ្នែកសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ប្រសិនបើយល់ឃើញថាសាលក្រមនោះមានការភន្តច្រឡំ ប៉ុន្តែមិនអាចធ្វើការកែប្រែផ្នែកសម្រេចសេចក្តីនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ ។

៥. ក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខ ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចដាក់ការទាមទារថ្មីដែលមិនបានធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះឡើយ។

**វិធាន ១១១: សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល**

១. រាល់វិធានដែលទាក់ទងនឹងទម្រង់ និងការចុះហត្ថលេខាលើសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលដីកា នៃអង្គជំនុំជម្រះតុលាការកំពូល។

២. នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខធ្វើឡើងហួសពេលកំណត់ ឬ ធ្វើឡើងដោយមានកំហុសនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលអាចប្រកាសថា បណ្តឹងសាទុក្ខនោះមិនអាចទទួលយកបាន ។

៣. លើកលែងតែករណី ដែលមានចែងនៅក្នុងវិធាន ១១០-៤ នៅពេល ដែលអង្គជំនុំជម្រះតុលាការ

កំពូលរកឃើញថា សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវទុកជាមោឃៈដោយសារកំហុសនីតិវិធី អង្គជំនុំជម្រះតុលាការ កំពូលអាចសម្រេចលើអង្គសេចក្តីឡើងវិញដូចអង្គជំនុំជម្រះសាលាដំបូង។

៤. ក្នុងករណីបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចឱ្យរួចផុតពីបទចោទ នោះជនជាប់ចោទ ត្រូវបានដោះលែងឱ្យមានសេរីភាពភ្លាម លើកលែងតែជននោះត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត ។

៥. ក្នុងករណីបណ្តឹងសាទុក្ខ ដែលមានជនជាប់ចោទស្ថិតក្នុងការឃុំខ្លួន ត្រូវបានអង្គជំនុំជម្រះតុលាការកំពូល សម្រេចតម្កល់ការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ក៏សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ នោះអង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចអំពីបញ្ហានៃឃុំខ្លួន ។ បើជនជាប់ចោទមានវត្តមាននៅពេលជម្រះក្តី ប៉ុន្តែជននោះស្ថិតនៅក្រៅឃុំ អង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចបង្គាប់ឲ្យឃុំខ្លួន ដោយមានសំអាងហេតុ ។ បើជនជាប់ចោទអវត្តមាន អង្គជំនុំជម្រះអាចចេញដីកាស្វែងរកចាប់ខ្លួនបាន ។ ដីកានេះត្រូវមានអានុភាពអនុវត្តភ្លាមៗ។

៦. ដោយយោងទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលត្រូវព្យាយាម សម្រេចឲ្យបាននូវសម្លេងឯកច្ឆ័ន្ទ ។ ប្រសិនបើមិនអាចរកសម្លេងឯកច្ឆ័ន្ទនេះបានទេ សេចក្តីសម្រេចត្រូវធ្វើឡើង ដោយសម្លេងគាំទ្រយ៉ាងហោចណាស់ដោយចៅក្រម ៥(ប្រាំ) សម្លេង ។ ក្នុងករណីដែលបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និង មិនអាចតវ៉ាបានទៀតឡើយ។

**វិធាន ១១២: បណ្តឹងសើរើ**

១. ទណ្ឌិត ឬ ក្នុងករណីដែលទណ្ឌិតនោះទទួលមរណៈភាព សហព័ទ្ធ កូន ឪពុកម្តាយ ឬ បុគ្គលដទៃទៀតដែលមានជីវិតរស់រាននៅពេលមរណៈភាពរបស់ទណ្ឌិត ហើយបានទទួលនូវបណ្តាំជាលាយលក្ខណ៍អក្សរពីទណ្ឌិតឲ្យធ្វើបណ្តឹងសើរើ ឬ សហព្រះរាជអាជ្ញាធ្វើក្នុងនាមទណ្ឌិតនោះ អាចធ្វើបណ្តឹងសើរើចំពោះសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរ ទៅអង្គជំនុំជម្រះតុលាការកំពូលបាន កាលណាមានមូលហេតុដូចខាងក្រោម ៖

ក-ភស្តុតាងថ្មីត្រូវបានរកឃើញ ដោយហេតុថា ៖

(១)មិនមានភស្តុតាងនោះនៅពេលជម្រះក្តី ហើយការដែលមិនអាចរកបាននៃភស្តុតាងនោះមិនមែនជាកំហុសមួយផ្នែក ឬ ទាំងស្រុងរបស់ភាគីធ្វើពាក្យបណ្តឹង ។

(២) មានលក្ខណៈសំខាន់គ្រប់គ្រាន់ដែលថា បើផ្តល់ភស្តុតាងនេះឱ្យក្នុងពេលជំនុំជម្រះ នោះនឹងនាំ ឲ្យសាលដីកាមានការប្រែប្រួល ។

ខ-មានការរកឃើញថ្មីថា ភស្តុតាងដែលត្រូវបានជំនុំជម្រះ និង យកមកធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោសនោះ មានភាពក្លែងបន្លំ ឬ ខុសការពិត ។

គ-មានចៅក្រមមួយរូប ឬ ច្រើនរូបដែលចូលរួមក្នុងការស៊ើបសួរ ឬ ការផ្តន្ទាទោសបានប្រព្រឹត្ត ខុសឆ្គង យ៉ាងធ្ងន់ធ្ងរនឹងក្រមសីលធម៌ ឬ បំពានលើតួនាទីក្នុងការស្វែងរកយុត្តិធម៌ដែលអាចនាំឱ្យមានបណ្តេញចេញបាន តាមវិធានផ្ទៃក្នុងនេះ។

២. បុគ្គលដែលដាក់ពាក្យបណ្តឹងសើរើត្រូវដាក់បណ្តឹងនោះ ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ហើយត្រូវបញ្ជាក់ឲ្យបានច្បាស់ពីអង្គហេតុ និង អង្គច្បាប់នៅក្នុងបណ្តឹងនោះ ។ បន្ទាប់មកនីតិវិធីដែលអនុវត្ត សម្រាប់ការជំនុំជម្រះលើបណ្តឹងសាទុក្ខត្រូវយកមកអនុវត្តចំពោះបណ្តឹងសើរើ។

៣. ដោយយោងទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលត្រូវព្យាយាមសម្រេចឲ្យបាននូវសម្លេងឯកច្ឆ័ន្ទ ។ប្រសិនបើមិនអាចរកសម្លេងឯកច្ឆ័ន្ទនេះបានទេ សេចក្តីសម្រេចសើរើត្រូវធ្វើឡើងដោយសម្លេងគាំទ្រយ៉ាងហោចណាស់ដោយចៅក្រម ៥ រូបយ៉ាងតិច។ អង្គជំនុំជម្រះតុលាការកំពូល ត្រូវបដិសេធបណ្តឹងចោល កាលបើខ្លួនពិចារណាឃើញថា បណ្តឹងនោះគ្មានមូលដ្ឋានត្រឹមត្រូវ។ កាលបើកំណត់ បានថាពាក្យសុំមានហេតុផលសមស្រប អង្គជំនុំជម្រះតុលាការកំពូលត្រូវមានយុត្តាធិការជំនុំជម្រះលើករណីនេះ ដើម្បីធ្វើសេចក្តីវិនិច្ឆ័យថា តើត្រូវធ្វើការសើរើសាលក្រមនោះ ឬក៏អត់ដោយអនុវត្តតាមនីតិវិធីសម្រាប់បណ្តឹងសាទុក្ខ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ។

## វិធាន ១១៣: ការអនុវត្តទោស និង សំណងរដ្ឋប្បវេណី

**(វិសោធនកម្មថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)**

១. ការអនុវត្តទោសត្រូវធ្វើតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា ។ ការអនុវត្តសំណងដែលអនុលោមតាមវិធាន២៣ស្ទួនបួន(៣)(ក) ត្រូវធ្វើឡើងដោយអាជ្ញាធរជាតិដែលមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់កម្ពុជា តាមការផ្តួចផ្តើមគំនិតរបស់សមាជិកណាម្នាក់នៃក្រុមសមូហភាព លើកលែងតែសាលក្រមបញ្ជាក់ច្បាស់លាស់ថា សំណងនេះត្រូវផ្តល់ទៅឲ្យក្រុមមួយជាក់លាក់។ ក្នុងករណីបែបនេះ សមាជិកណាម្នាក់នៃក្រុមនោះ ត្រូវផ្តួចផ្តើមគំនិតការអនុវត្តសំណងនោះជំនួសវិញ។ ការអនុវត្តសំណងដែលមានចែងក្នុងវិធាន២៣*ស្ទួនបួន* (៣) (ខ) មិនស្ថិតនៅក្រោមវិសាលភាពនៃវិធាននេះទេ។

២. សហព្រះរាជអាជ្ញាធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានចូលជាស្ថាពរ លើកលែងតែបទប្បញ្ញត្តិទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

៣. សហព្រះរាជអាជ្ញាអាចសុំជំនួយពីអាជ្ញាធរអនុវត្តច្បាប់ ដើម្បីធានាដល់ការអនុវត្តទោស។

៤. ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នាត្រូវលើកជាបន្ទាន់ នៅចំពោះមុខអង្គជំនុំជម្រះដែលបានសម្រេចសេចក្តីចុងក្រោយចំពោះជនជាប់ចោទ ក្រោយពេលចេញសេចក្តីសម្រេចនោះ ។ អង្គជំនុំជម្រះអាចទទួលពាក្យសុំរបស់សហព្រះរាជអាជ្ញា និង ភាគីដែលពាក់ព័ន្ធ ។ បន្ទាប់ពីបានស្តាប់សហព្រះរាជអាជ្ញា ភាគីដែលពាក់ព័ន្ធ និង មេធាវី រួចមក អង្គជំនុំជម្រះត្រូវចេញសេចក្តីសម្រេចនៅក្នុងសវនាការជាសាធារណៈ។

## វិធាន ១១៤: អន្តរប្បញ្ញត្តិ

(វិសោធនកម្មថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩ **និងវិសោធនកម្មថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ និង ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១** )

១. ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃវិធាន ៤៨ និងវិធាន ៧៦ រាល់កិច្ចនីតិវិធីដែលធ្វើឡើង ដោយអង្គជំនុំជម្រះវិសាមញ្ញ ដោយយោងទៅលើច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌជាធរមានរបស់កម្ពុជា នៅមុនពេលវិធានផ្ទៃក្នុងនេះចូលជាធរមាន ត្រូវចាត់ទុកថាមានសុពលភាព។

២. ការចូលជាធរមាននៃវិសោធនកម្មណាមួយចំពោះវិធានផ្ទៃក្នុងនេះ នឹងមិនប៉ះពាល់ដល់កិច្ចនីតិវិធីទាំងឡាយដែលបានធ្វើដោយអង្គជំនុំជម្រះវិសាមញ្ញ ស្របតាមវិធានផ្ទៃក្នុងនេះ នាមុនពេលនៃការចូលជាធរមាននៃ វិសោធនកម្មវិធានផ្ទៃក្នុងនេះទេ។

៣. វិសោធនកម្មទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំពេញអង្គលើកទី៧ , ទី៨ និងទី៩ នឹងត្រូវអនុវត្តចំពោះរាល់សំណុំរឿងទាំងអស់ លើកលែងតែសំណុំរឿងលេខ០០១/១៨-០៧-២០០៧/ អ.វ.ត.ក។

-------------------------------

*ត្រូវបានអនុម័តនៅកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ និងត្រូវបានចុះហត្ថលេខាដាក់អោយចូលជាធរមានដោយប្រធាន និង អនុប្រធាននៃកិច្ចប្រជុំពេញអង្គ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧។ ត្រូវបានធ្វើវិសោធនកម្មក្នុងកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨, ថ្ងៃទី០៥ ខែកញ្ញា ២០០៨, ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ , ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៩ , ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ,ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ និងថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១។*



-----------------------------------------

**ចៅក្រម គង់ ស្រ៊ីម**

**ប្រធានកិច្ចប្រជុំពេញអង្គ**



-----------------------------------------

**ចៅក្រម Silvia Cartwright**

**អនុប្រធានកិច្ចប្រជុំពេញអង្គ**

## សន្ទានុក្រម

**នៅក្នុងឯកសារនេះ មាន:**

**ជនជាប់ចោទ** *(Accused = Accusé)* សំដៅទៅលើបុគ្គល ដែលត្រូវចោទប្រកាន់ ដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ។

**កិច្ចព្រមព្រៀង** *(Agreement = Accord)* សំដៅទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋា-ភិបាលកម្ពុជា ស្តីពីការកាត់ទោសឧក្រិដ្ឋកម្មស្ថិតនៅក្រោមច្បាប់កម្ពុជា ដែលប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខា នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងប្រកាសឲ្យប្រើជាផ្លូវការ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤។

**ដីកាបង្គាប់ឲ្យចាប់ខ្លួន** *(Arrest and Detention Order = mandat d'arrêt)* សំដៅទៅលើដីកាដែលចេញទៅ ឱ្យនគរបាលយុត្តិធម៌ដើម្បីស្វែងរកចាប់ខ្លួន និង នាំខ្លួនបុគ្គលណាម្នាក់ មកកាន់មន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ និងទៅឲ្យប្រធានមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ ឲ្យទទួល និង ឃុំខ្លួនជននោះ រង់ចាំការបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

**ដីកាបង្គាប់ឲ្យនាំខ្លួន** *(Arrest Warrant = mandate d'amener)* សំដៅទៅលើដីកាដែលចេញទៅឲ្យនគរបាលយុត្តិធម៌ដើម្បីចាប់ និង នាំខ្លួន បុគ្គលណាម្នាក់មកចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** *(BAKC = OARC)* សំដៅទៅលើគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ដីកាសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ** *(Bail Order = Contrôle Judiciaire)* សំដៅ ទៅលើដីការបស់តុលាការដែលសម្រេចឲ្យជនត្រូវចោទ ឬជនជាប់ចោទ មានសេរីភាព ឬដោះលែងចេញពីមន្ទីរ ឃុំឃាំង ដើម្បីរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដោយមានលក្ខខ័ណ្ឌតម្រូវឲ្យជននោះបង់ប្រាក់ធានា និង/ឬ គោរពតាមលក្ខខ័ណ្ឌមួយចំនួន ដែលមានចែងក្នុងដីកានោះ។

**សំណុំរឿង** *(Case File = Dossier)* សំដៅទៅដល់សំណុំឯកសារដែលរួមមាន កំណត់ហេតុនៃកិច្ចដែលបានបំពេញនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ឬ ការស៊ើបសួរ ក៏ដូចជាពាក្យសុំរបស់ភាគី សេចក្តីសម្រេច ទាំងឡាយដែលបានចេញ និង អ្វីដែលជាឧបសម្ព័ន្ធដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធី រួមទាំងកំណត់ហេតុ សវនាការផង។

**ដើមបណ្តឹងរដ្ឋប្បវេណី** ***(Civil Party = Partie Civile)*** សំដៅទៅលើជនរងគ្រោះ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ ដោយយោងទៅលើវិធានផ្ទៃក្នុងនេះ។

**អង្គជំនុំជម្រះ** ***(Chambers = Les Chambres)*** សំដៅទៅលើអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ជនត្រូវចោទ** ***(Charged Person = Personne mise en examen)*** សំដៅទៅលើបុគ្គលណាម្នាក់ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់។

**ដីកាដំណោះស្រាយ** ***(Closing Order = Décision de clôture)*** សំដៅទៅលើដីកាចុងក្រោយដែលធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់។

**បទចោទ** ***(Count = Chef d'inculpation)***សំដៅទៅលើការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ដែលជនជាប់ចោទ ត្រូវបានដាក់បន្ទុក ឬ ជនជាប់ចោទ ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជម្រះ។

**ដីកាបង្គាប់ឲ្យឃុំខ្លួន** ***(Detention Order = Mandat de dépôt)*** សំដៅទៅលើដីកា ដែលបញ្ជាឲ្យប្រធានមន្ទីរ ឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទទួល និងឃុំជនត្រូវចោទ ឬ ជនជាប់ចោទ។

**ដីកាលើកលែងចោទប្រកាន់** ***(Dismissal Order = Décision de non lieu)*** សំដៅទៅលើដីកាដំណោះស្រាយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទ។

**អង្គជំនុំជម្រះវិសាមញ្ញ** ***(អ.វ.ត.ក = ECCC = CETC)*** សំដៅទៅលើតុលាការពិសេសនៅក្នុងយុត្តាធិការ តុលាការកម្ពុជាដែលបង្កើតឡើង ដោយច្បាប់ស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសឱ្យប្រើជាផ្លូវការ ដោយព្រះរាជក្រឹត្យលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៤។

**ច្បាប់អ.វ.ត.ក** ***(The ECCC Law = La Loi sur les CETC)*** សំដៅទៅលើច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសបទឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិតេយ្យ ដូចដែលបានធ្វើវិសោធនកម្មឱ្យស្របនឹងកិច្ចព្រមព្រៀង និងប្រកាសឱ្យប្រើជាផ្លូវការ ដោយព្រះរាជក្រឹត្យ

លេខ នស/រកម/ ១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។

**វត្ថុតាង**(**Exhibit = Pièce à conviction,** ) សំដៅលើវត្ថុរូបី ដែលត្រូវបានប្រើជាភស្តុតាងក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក.។

**ដីកាសន្និដ្ឋានស្ថាពរ** ***(Final Submission = Réquisitoire Définitif)*** សំដៅទៅលើដីកាជាលាយលក្ខអក្សរដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឱ្យធ្វើដីកាដំណោះស្រាយចំពោះសំណុំរឿងណាមួយ។

**ក្រឡាបញ្ជី** ***(Greffier = Greffier)*** សំដៅទៅលើអ្នកជំនួយការរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ និង ជាអ្នកទទួលខុសត្រូវ ជាពិសេសក្នុងការរក្សាទុកនូវរាល់ឯកសារផ្លូវការនៃការជំនុំជម្រះទទួលយកនូវឯកសារច្បាប់ដើមពីភាគីទាំងអស់ និងធានាដល់ការជូនដំណឹងរាល់សេចក្តីសម្រេច។

**ដីកាបញ្ជូនរឿងទៅជំនុំជម្រះ** ***(Indictment = Décision de renvoi)*** សំដៅទៅលើដីកាដំណោះស្រាយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ បញ្ជូនជនត្រូវចោទទៅជំនុំ ជម្រះ។

**ការចូលបង្ហាញខ្លួនលើកដំបូង** ***(Initial Appearance = Première Comparution)*** សំដៅទៅលើការបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយជននោះត្រូវបានប្រាប់ឱ្យដឹងអំពី បទចោទប្រកាន់។

**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ** ***(Introductory Submission = Réquisitoire Introductif)*** សំដៅទៅលើ ដីកាជាលាយលក្ខអក្សរដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរចំពោះករណីបទល្មើសណាមួយ និង ធ្វើការចោទប្រកាន់។

**អ្នកស៊ើបអង្កេត** ***(Investigator)*** សំដៅដល់មន្ត្រីណាម្នាក់នៃការិយាល័យសហព្រះរាជអាជ្ញា ឬ ការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងជាតិ និងអន្តរជាតិ ដែលត្រូវបានចាត់តាំងយ៉ាងត្រឹមត្រូវ ដោយការិយាល័យរបស់ខ្លួន ឱ្យបំពេញភារកិច្ចជាអ្នកស៊ើបអង្កេត និងត្រូវបានផ្តល់នីតិសម្បទា ស្របតាមនីតិវិធីដូចមាន ចែងក្នុងវិធាន ១៦។

**នគរបាលយុត្តិធម៌** ***(Judicial Police = Police Judiciaire)*** សំដៅទៅលើមន្ត្រីនគរបាលយុត្តិធម៌ និង/ឬ កងរាជអាវុធហត្ថនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានតែងតាំងឱ្យបំពេញការងារក្នុងក្របខ័ណ្ឌយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

**មេធាវី** *(Lawyer = Avocat)* សំដៅទៅលើជនណាម្នាក់ដែលត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈមេធាវី ដោយ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬ ដោយអាជ្ញាធរមានសមត្ថកិច្ចណាមួយផ្សេងទៀតក្នុងរដ្ឋ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ និង ត្រូវបានចុះឈ្មោះដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឱ្យការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដោយយោងទៅលើវិធានផ្ទៃក្នុងនេះ។

**ការជូនដំណឹង** *(Notification = Signification)* សំដៅទៅលើសកម្មភាពដែលយោងទៅលើករណីដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ អំពីសេចក្តីសម្រេចរបស់តុលាការដែល ត្រូវបានជូនដំណឹងដល់ភាគីណាមួយនៃកិច្ចដំណើរការនីតិវិធី។

**ភាគី** *(Party)* សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

**កិច្ចប្រជុំពេញអង្គ** *(Plenary Session = Assemblée Plénière)* សំដៅទៅលើអង្គប្រជុំមួយដែលមានចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា ចូលរួម និង បោះឆ្នោត ដូចមានចែងក្នុងវិធាន ១៨។

**ការឃាត់ខ្លួន** *(Police Custody = Garde à vue)* សំដៅទៅលើការឃាត់ខ្លួនជនសង្ស័យដោយនគរបាលយុត្តិធម៌ តាមការបង្គាប់របស់សហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត។

**សេចក្តីណែនាំអនុវត្ត** *(Practice Direction = Directives Pratiques)* សំដៅទៅលើបទប្បញ្ញត្តិដែលចែងលំអិតអំពីទិដ្ឋភាពក្នុងការអនុវត្តការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយត្រូវអនុម័តដោយគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ដោយស្របទៅតាមច្បាប់ កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុងនេះ។

**ការឃុំខ្លួនបណ្តោះអាសន្ន** *(Provisional Detention = Détention Provisoire)* សំដៅទៅលើការឃុំខ្លួនជនត្រូវចោទតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ឬ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ឬ សំដៅទៅលើការឃុំខ្លួនជនជាប់ចោទ តាមដីការបស់អង្គជំនុំជម្រះ ដើម្បីរង់ចាំសេចក្តីសម្រេចចុងក្រោយ។

**ដីកាចាត់ឱ្យស៊ើបសួរជំនួស** *(Rogatory Letter = Commission Rogatoire)* សំដៅទៅលើការបង្គាប់ជាលាយល័ក្ខអក្សររបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ទៅអ្នកស៊ើបអង្កេត ឬ មន្ត្រីនគរបាលយុត្តិធម៌ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ឱ្យបំពេញកិច្ចស៊ើបសួរជាក់លាក់ណាមួយ។

**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម** *(Supplementary Submission = Réquisitoire Supplétif)* សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរដែលធ្វើដោយសហព្រះរាជអាជ្ញា ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចបន្ថែមទៅលើការស៊ើបសួរដែលកំពុងធ្វើ។

**ជនសង្ស័យ** ***(Suspect)*** សំដៅទៅលើបុគ្គលដែលសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត ចាត់ទុកថាអាចធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ។

ដំណាក់កាលជំនុំជម្រះ *(Trial Stage)* សំដៅទៅលើកាលបរិច្ឆេទ ចាប់ពីពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង ។

**ជនរងគ្រោះ** ***(Victim)*** សំដៅទៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។

**សមាគមជនរងគ្រោះ** ***(Victims' Association = Association des victims)***សំដៅទៅលើសមាគមមួយ ដែលបានបង្កើតឡើង ដោយសមាជិកដែលសុទ្ធតែជាជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ ហើយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងប្រទេសដែលខ្លួនធ្វើសកម្មភាពក្នុងពេល ដែលសមាគមនេះ ធ្វើអន្តរាគមន៍របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ហើយបានទទួលសិទ្ធិត្រឹមត្រូវឱ្យធ្វើ សកម្មភាពក្នុងនាមសមាជិករបស់ខ្លួន។

---